ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- តើយើងកំពុងតែធ្វើការលើបរិបទជាតិសិទ្ធិមនុស្សឬអ្វី?
- ជំនួយរបស់អង្គការសហប្រជាជាតិសម្រាប់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា

រូបថតដោយ : ហេង ស៊ីធៀ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ៧៥ ខែមីនា ឆ្នាំ២០០៦

# ស្វែងរកការពិត

លេខ៧៥ ខែមីនា ឆ្នាំ២០០៦


## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា
## មាតិកា


◆ សំបុត្រ ៖ តើយើងកំពុងតែធ្វើការលើបរិបទជាតិសិទ្ធិមនុស្សឬអ្វី? ........១

**ផ្នែកឯកសារ**

◆ វិយោគកថា ........................................................................៤

◆ ហ៊ីង សុខុម សាស្ត្រាចារ្យមកពីសហរដ្ឋអាមេរិក ...............................៧

◆ បញ្ជីឈ្មោះជនរងគ្រោះដែលកម្ទេចនៅមន្ទីរ ស-២១៦ .....................១០

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ រឿងរ៉ាវដែលមិនចេះសាបសូន្យ ...............................................១២

◆ គ្មានអ្វីអាចសងជីវិតក្រុមគ្រួសារខ្ញុំបានទេ .......................................២៣

**ផ្នែកច្បាប់**

◆ សំណងសម្រាប់ជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្ស ...................២៥

**វេទិកាពិភាក្សាសាធារណៈ**

◆ យុត្តិធម៌និងការផ្សះផ្សាបង្រួបបង្រួមនៅប្រទេសកម្ពុជា .....................៣២

◆ ការបែងចែកអំណាចនិងសារសំខាន់នៃ ........................................៤៣

◆ លោក កូហ្វី អាណាន់ តែងតាំងចៅក្រមអន្តរជាតិ .............................៤៦

◆ ជំនួយរបស់អង្គការសហប្រជាជាតិសម្រាប់អង្គជំនុំជម្រះ .....................៤៧

◆ បទសុន្ទរកថាថ្លែងដោយឯកឧត្តម ស៊ាន វិសុទ្ធ ..................................៤៩

◆ បទសុន្ទរកថាថ្លែងដោយលោកស្រី មីសែល លី ...............................៥១

◆ បទសុន្ទរកថាថ្លែងដោយឯកឧត្តម សុខ អាន ....................................៥២

◆ សុន្ទរកថារបស់លោកឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ...........................៥៤

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ដំណើរស្វែងរកកូនស្រី ............................................................៥៦

◆ រឿងពិតមិនការឡៃ ..............................................................៥៧

◆ សូមសងជីតាខ្ញុំវិញ ................................................................៦០








**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ ៖** ប៊ាង ពីរីន, ស៊ិរិ សារីណា, អេង កុកថាយ, វ៉ាន់ថាន់ ពៅដារ៉ា, អៀ ម៉េងទ្រី, សោម វណ្ណៈ, សូ ហ្វារីណា, ស៊ុន សារឿន **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** លី សុផល, ណយ សុផារី **អ្នកបកប្រែ ៖** បាន់ ចំរើន, ប៉ាន់ ស៊ីម៉ាឡា **និពន្ធនាយករង ៖** សាន់ កល្យាណ **និពន្ធនាយកទូទៅ ៖** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រ ៖** គឹម សុវណ្ណដានី **គ្រប់គ្រងការចែកផ្សាយ ៖** រ័ត្ន គារាពិដោ Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ :*

# តើយើងកំពុងតែធ្វើការលើបរិបទជាតិសិទ្ធិមនុស្សឬអ្វី?

របបកម្ពុជាប្រជាធិបតេយ្យទទួលបរាជ័យ នៅក្នុងឆ្នាំ ១៩៧៩ ។ ភ្លាមៗនោះដែរ រដ្ឋាភិបាលថ្មីមួយត្រូវបានបង្កើតឡើងសម្រាប់កម្ពុជានិងបានកាត់ទោសដោយកំបាំងលើមេដឹកនាំខ្មែរក្រហមចំនួនពីររូបគឺ ប៉ុល ពត និង អៀង សារី ។ ក្នុងពេលនោះដែរ អ្នកស្រុកអ្នកភូមិកម្ពុជាយ៉ាងច្រើនមានគំនិតសងសឹកនឹងកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោម ។ នៅក្នុងឆ្នាំ១៩៩៦ រដ្ឋាភិបាលកម្ពុជាបានផ្តល់ការលើកលែងទោសដល់ អៀង សារី ក្នុងន័យស្ថិរភាពនិងសន្តិភាព ព្រោះរដ្ឋាភិបាលកម្ពុជាយល់ឃើញថាមានការចាំបាច់ ដើម្បី“ជីករណ្តៅកប់រឿងរ៉ាវអតីតកាល” ។

ក្នុងឆ្នាំ១៩៩៧ រាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមកិច្ចចរចាជាមួយនឹងអង្គការសហប្រជាជាតិស្តីអំពីការបង្កើតតុលាការពិសេសដើម្បីនាំអតីតមេដឹកនាំខ្មែរក្រហមមកកាត់ទោស ។ នៅដើមឆ្នាំ២០០៦នេះ ក្រុមការងាររបស់អង្គការសហប្រជាជាតិបានធ្វើដំណើរមកដល់ទីក្រុងភ្នំពេញនិងចាប់ផ្តើមរៀបចំការិយាល័យរដ្ឋបាលរបស់ខ្លួនសម្រាប់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ហើយការជំនុំជម្រះក្តីគ្រោងនឹងចាប់ផ្តើមនៅក្នុងឆ្នាំ២០០៧ ខាងមុខនេះ ។

បញ្ហាការកាត់ទោសមេដឹកនាំខ្មែរក្រហមក្លាយជារឿងនយោបាយអស់រយៈពេលជាច្រើនឆ្នាំ ។ វប្បធម៌លើកលែងទោសនៅតែបន្តមាននៅក្នុងប្រទេសកម្ពុជា ។ ប្រទេសកម្ពុជាដូចនឹងប្រទេសដទៃទៀតដែលប្រព័ន្ធតុលាការមានភាពទន់ខ្សោយ គឺអ្នកមានតែងទិញយកប្រយោជន៍ដែលខ្លួនចង់បាននៅក្នុងតុលាការ រីឯអ្នកក្រវិញជាញឹកញាប់ពុំទទួលបានការការពារអ្វីសោះឡើយ និងមានយល់ដឹងតិចតួចបំផុតអំពីសិទ្ធិរបស់ខ្លួន ។ ភាគច្រើនប្រជាជនកម្ពុជាមិនមានជំនឿថាខ្លួននឹងអាចស្វែងរកយុត្តិធម៌បានឡើយ ដោយសារតែគាត់ជឿថា ទាំងខ្មែរក្រហមនិងជនរងគ្រោះមិនអាចស្វែងរកយុត្តិធម៌ដែលខ្លួនសមនឹងទទួលបាននោះទេ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើកិច្ចការងារលើបញ្ហាបរិបទសិទ្ធិមនុស្ស ពីព្រោះមជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាវិទ្យាស្ថានស្រាវជ្រាវឯករាជ្យមួយដែលទាក់ទងនឹងការស្វែងរកការពិតស្តីអំពីការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរនៃរបបកម្ពុជាប្រជាធិបតេយ្យ និងផលប៉ះទង្គិចក្រោយរបបនេះ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏ជាមជ្ឈមណ្ឌលថែរក្សាឯកសារដំបូងបង្អស់និងធំបំផុតនៅលើពិភពលោកដែលថែរក្សាឯកសារទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ ។ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងបម្រើជាប្រភពដ៏មានតម្លៃមួយសម្រាប់ឯកសារជាភស្តុតាងនៅក្នុងពេលជំនុំជម្រះកាត់សេចក្តីមេដឹកនាំខ្មែរក្រហម ។ គោលបំណងសំខាន់ៗរបស់មជ្ឈមណ្ឌល គឺជំរុញឲ្យមានការចងចាំនិងយុត្តិធម៌ ដោយបានជួយផ្សះផ្សារបួសអតីតកាលជូនដល់ប្រជាជនកម្ពុជា ជួយពង្រឹងនីតិរដ្ឋឲ្យរឹងមាំ និងទប់ស្កាត់ការរំលោភបំពានសិទ្ធិមនុស្សដែលកើតមានទាំងនៅក្នុងប្រទេសកម្ពុជានិងក្រៅប្រទេស ។ យើងសង្ឃឹមថាគោលបំណងសំខាន់ពីរនេះនឹងបម្រើការបង្កើតមូលដ្ឋានគ្រឹះនីតិរដ្ឋនិងការបង្រួបបង្រួមជាតិពិតប្រាកដនៅក្នុងប្រទេសកម្ពុជា ។

នាពេលបច្ចុប្បន្ននេះ ប្រទេសកម្ពុជាគឺជាគ្រឹះស្ថានសម្រាប់អង្គការក្រៅរដ្ឋាភិបាលសិទ្ធិមនុស្សនិងសិទ្ធិពលរដ្ឋសំខាន់ៗចំនួនមិនតិចជាង ១០០០អង្គការឡើយ ។ ជាងនេះទៅទៀត ស្របពេលដែលសាលាជំនុំជម្រះកាត់សេចក្តីមេដឹកនាំខ្មែរក្រហមគ្រោងនឹងចាប់ផ្តើមមានអង្គការក្រៅរដ្ឋាភិបាលផ្សេងៗទៀតក៏កំពុងតែស្វែងរកទីកន្លែងសម្រាប់ខ្លួនឯងផ្ទាល់តាមកិច្ចការដែលត្រូវធ្វើលើបញ្ហាសិទ្ធិមនុស្ស ។ អង្គការក្រៅរដ្ឋាភិបាលទាំងនេះក្លាយជាសំឡេងដ៏ខ្លាំងក្លាមួយក្នុងការគាំទ្រនីតិរដ្ឋនិងលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា ប្រសិនបើអង្គការទាំងនេះគ្រប់គ្រងសកម្មភាពការងាររបស់ខ្លួនបានល្អ ដោយយកចិត្តទុកដាក់ និងគ្មានមតិរិះគន់ណាមួយ ។

បើទោះបីជាមជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយអង្គការក្រៅរដ្ឋាភិបាលជាច្រើនក៏ដោយ ក៏មជ្ឈមណ្ឌលឯកសារកម្ពុជាមាននីតិវិធីដោះស្រាយបញ្ហាតាមវិធីផ្សេងៗខុសពីអង្គការដទៃទៀត ។ ជាជំហានដំបូងយើងមានជំនឿថាបញ្ហាខ្មែរក្រហមមិនគួរប្រែក្លាយឲ្យទៅជារឿងនយោបាយទេ ផ្ទុយទៅវិញ បញ្ហានេះគួរតែត្រូវចាត់ទុកជាបញ្ហាសិទ្ធិមនុស្សនិងយុត្តិធម៌ ។ ដូច្នេះហើយ តួនាទីមួយក្នុងចំណោមតួនាទីសំខាន់របស់យើង គឺផ្ដោតយកចិត្តទុកដាក់ទៅលើជនរងគ្រោះនិងនិយាយក្នុងនាមជាជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា ។

ជំហានទីពីរ យើងខិតខំប្រឹងប្រែងរក្សាគោលបំណងសំខាន់របស់យើងដដែល ។ យើងជឿទុកចិត្តរាជរដ្ឋាភិបាលកម្ពុជានិងស្ថាប័ននានាពាក់ព័ន្ធនឹងការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលយើងអាចជួយដល់រាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធយល់ដឹងអំពីសាធារណជនចំពោះបញ្ហាតុលាការ និងឲ្យមានការជឿទុកចិត្តលើសកម្មភាពការងាររបស់ខ្លួនថែមទៀត ។ យើងក៏បានខិតខំពន្យល់ប្រាប់រាជរដ្ឋាភិបាលកម្ពុជាថា តុលាការនេះនឹងបម្រើផលប្រយោជន៍ប្រទេសជាតិរបស់យើងទាំងអស់គ្នា ។ បន្ថែមពីនេះទៀត យើងក៏បានសហការជាមួយសមាជិកសភានិងក្រុមការងារតុលាការរបស់រាជរដ្ឋាភិបាល ដោយបានផ្ដល់ព័ត៌មានប្រវត្តិរូបនានា ជួយណែនាំឲ្យស្គាល់អ្នកជំនាញនានាដែលអាចពិភាក្សាបាន និងផ្ដល់យោបល់ឲ្យចេះប្រើប្រាស់នូវភាសាតែមួយដូចនឹងភាសារបស់អង្គការសហប្រជាជាតិ ។

ជំហានទីបី យើងបានសហការជាមួយសហគមន៍និងអង្គទូតនានាដើម្បីពន្យល់ប្រាប់រាជរដ្ឋាភិបាលនិងស្ថាប័នពាក់ព័ន្ធនានា ឲ្យយល់ដឹងអំពីការទាមទាររបស់មហាជនដែលចង់ឲ្យនាំមេដឹកនាំខ្មែរក្រហមមកធ្វើការកាត់ទោស ។ ជំហាននេះរួមមានការជូនដំណើរសហគមន៍និងអង្គទូតទៅកាន់ភូមិនានាដើម្បីចូលរួមស្ដាប់អ្នកស្រុកអ្នកភូមិ ការផ្សព្វផ្សាយបទសម្ភាសន៍ជាមួយនឹងជនរងគ្រោះ និងការស្វែងរកអ្នកជំនាញដើម្បីឆ្លើយនឹងសំណួរបច្ចេកទេសនានា ។ អស់រយៈពេលជាច្រើនឆ្នាំ យើងបានពិភាក្សាជាមួយនឹងអង្គការសហប្រជាជាតិស្ដីអំពីថាតើប្រជាជនកម្ពុជាមានការយល់ឃើញយ៉ាងដូចម្ដេចចំពោះការរៀបចំតុលាការនេះ និងថា តើគាត់នឹងមានប្រតិកម្មយ៉ាងដូចម្ដេចចំពោះសំណើណាមួយ ។

ជំហានទីបួន យើងបានបង្កើតគម្រោងជាច្រើនដើម្បីផ្សារភ្ជាប់ទៅនឹងប្រជាជនកម្ពុជា ។ ក្នុងឆ្នាំ១៩៩៥ យើងបានស្នើសុំកាសែតក្នុងស្រុកមួយគឺ កាសែតរស្មីកម្ពុជា ឲ្យជួយផ្ដល់នូវទំព័រពិសេសមួយសម្រាប់អត្ថបទដែលទាក់ទងនឹងប្រធានបទប្រវត្តិសាស្ត្រខ្មែរក្រហម ។ ចាប់តាំងពីឆ្នាំនោះមក កាសែតក្នុងស្រុកមួយនេះ បានបោះពុម្ពផ្សាយអំពីបញ្ហាខ្មែរក្រហមជារៀងរាល់ថ្ងៃដោយពុំមានទាមទារថ្លៃសេវាកម្មផ្សព្វផ្សាយឡើយ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាផ្ដល់រូបថតទាក់ទងនឹងខ្មែរក្រហមយ៉ាងច្រើន និងរឿងរ៉ាវខ្មែរក្រហមប្រហែលពាក់កណ្ដាលក្នុងចំណោមរឿងរ៉ាវខ្មែរក្រហមជាងមួយពាន់រឿងនៅលើគេហទំព័ររបស់យើងដែរ ។

យើងក៏បានចុះទៅធ្វើការងារដល់ថ្នាក់ស្រុកនិងភូមិនានាដើម្បីផ្ដល់ឱកាសដល់ជនរងគ្រោះឲ្យគាត់បានដឹងពុំអំពីជីវិតរបស់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ យើងផ្សព្វផ្សាយរឿងរ៉ាវរបស់ជនរងគ្រោះនិងជនដៃដល់តាមរយៈការបោះពុម្ពផ្សាយទស្សនាវដ្ដីប្រចាំខែ *ស្វែងរកការពិត* និងសៀវភៅផ្សេងៗរបស់មជ្ឈមណ្ឌល កម្មវិធីវិទ្យុនិងភាពយន្ត ។ ថ្មីៗនេះដែរ យើងក៏បានចាប់ផ្ដើមគម្រោងថ្មីមួយទៀតគឺគម្រោងនាំប្រជាជនប្រាំពាន់នាក់ទូទាំងប្រទេសកម្ពុជាឲ្យចូលរួមសវនាការកាត់សេចក្ដីមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ក្នុងរយៈពេលមួយសប្ដាហ៍ ។ បន្ទាប់មក គាត់នឹងវិលត្រឡប់ទៅភូមិស្រុកវិញ និងរៀបចំវេទិកានានាដើម្បីពិភាក្សានូវអ្វីដែលគាត់បានយល់ដឹងបានឃើញផ្ទាល់នឹងភ្នែក និងឮផ្ទាល់នឹងត្រចៀកអំពីសវនាការកាត់សេចក្ដី និងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ។ សកម្មភាពនេះជួយបង្កើតនូវចលនាមហាជនមួយដើម្បីសិទ្ធិមនុស្ស ។

មជ្ឈមណ្ឌលឯកសារកម្ពុជាសហការផ្ទាល់ជាមួយនឹងអង្គការក្រៅរដ្ឋាភិបាលកម្ពុជាជាច្រើនលើបញ្ហាសិទ្ធិមនុស្ស ។ នាពេលថ្មីៗនេះ យើងបានផ្ដល់វគ្គហ្វឹកហ្វឺនដល់អង្គការក្រៅរដ្ឋាភិបាលចំនួនពីរនៅក្នុងខេត្តបាត់ដំបងនិងសៀមរាប ហើយយើងក៏បានសហការជាមួយវិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ លើគម្រោងអប់រំប្រជាជនដែលរស់នៅក្នុងខេត្តចំនួនដប់អំឡុងពេល

មុននិងក្រោយតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ នៅចុងឆ្នាំ២០០៣ យើងបានចាប់ផ្តើមគម្រោងរយៈពេលពីរឆ្នាំជាមួយនឹងអង្គការចិត្តសង្គម-អន្តរវប្បធម៌ ដែលមាននាទីផ្តល់ប្រឹក្សាដល់ជនរងគ្រោះដោយសារការរំលោភបំពានក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។ សព្វថ្ងៃនេះ ជនរងគ្រោះនិងជនដែលកំពុងតែទទួលរងជំងឺផ្លូវចិត្តធ្ងន់ធ្ងរ ។ យើងក៏បានទទួលតំណាងដែលមកពីអង្គការក្រៅរដ្ឋាភិបាលសិទ្ធិមនុស្សក្នុងស្រុកនានាឲ្យចូលរួមសិក្ខាវគ្គហ្វឹកហ្វឺនផ្នែកច្បាប់ដែលរយៈពេលប្រាំមួយសប្តាហ៍ ។ យើងផ្តល់វគ្គហ្វឹកហ្វឺនផ្នែកច្បាប់នេះក្នុងឆ្នាំ២០០៤និង២០០៥ (វគ្គហ្វឹកហ្វឺនផ្នែកច្បាប់មួយទៀតគ្រោងនឹងធ្វើឡើងសម្រាប់ឆ្នាំ២០០៦នេះដែរ) ត្រៀមសម្រាប់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។



នៅក្នុងឆ្នាំ២០០៥ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានចូលរួមនិងខ្ទេសនាមនៅក្នុងសន្និសីទ និងសិក្ខាសាលាជាង៤០កន្លែងដែលរៀបចំដោយអង្គការក្រៅរដ្ឋាភិបាលនៅក្នុងទីក្រុង ភ្នំពេញ ។ បុគ្គលិកយើងក៏បានជួបពិភាក្សាជាមួយនឹងតំណាងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកជាច្រើននាក់ស្តីអំពីតុលាការនិងបានជួយផ្តល់ប្រឹក្សានិងជួយដល់អង្គការទាំងនោះថែមទៀត ។ អង្គការក្រៅរដ្ឋាភិបាលដែលយើងបានសហការជាមួយរួមមានសមាគមអាដហុក សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្សអូអេសដេអាយ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ អង្គការវេទិកានៃកម្ពុជា និងអង្គការដេត ។ ជាងនេះទៅទៀត យើងទទួលបានកិច្ចសហការមកពីសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិ មនុស្សជាដិក និង ដេត ដែលបានជួយចែកចាយទស្សនាវដ្តីប្រចាំខែរបស់មជ្ឈមណ្ឌលយើង ។

ទោះបីជាញឹកញាប់មជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយអង្គការក្រៅរដ្ឋាភិបាលយ៉ាងណាក៏ដោយ ក៏យើងមិនបានសហការជាមួយនឹងអង្គការនេះដោយផ្ទាល់ទេ ពីព្រោះអង្គការទាំងនេះ ត្រូវបានបង្កើតយ៉ាងល្អត្រឹមត្រូវនិងឯករាជ្យរួចទៅហើយ ។ ផ្ទុយទៅវិញ យើងសហការជាមួយនឹងអង្គការ ក្រៅរដ្ឋាភិបាលដែលកំពុងតែអភិវឌ្ឍន៍ដូចជាវិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យនិងអង្គការអន្តរវប្បធម៌ចិត្តសង្គមជាដើម ព្រមទាំងក្រុមដែលពុំសូវមានឈ្មោះជាផ្លូវការមួយចំនួនទៀតដូចជា សមាគមន៍និស្សិត ក្រុមដូនជី និងសហគមន៍ចាមអ៊ិស្លាម ។ ពិតប្រាកដណាស់ ក្រុមទាំងនេះក៏បានផ្តល់ការជួយគាំទ្រមកវិញដែរចំពោះ មជ្ឈ-មណ្ឌលឯកសារកម្ពុជា ។

ជាចុងក្រោយ មានអង្គការក្រៅរដ្ឋាភិបាលជាច្រើនទៀត ដែលកំពុងតែបំពេញការងាររបស់ខ្លួនលើកម្មវិធីនានា ដែលទាក់ទងនឹងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនឹងប្រឈមមុននឹងការរក្សាព័ត៌មានឲ្យត្រឹមត្រូវសម្រាប់ផ្តល់ជូនសាធារណជនបានដឹងបានច្បាស់ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងតែស្វែងរកនីតិវិធីដែលល្អបំផុតក្នុងការធានាឲ្យមានភាពត្រឹមត្រូវក្នុងការផ្តល់ព័ត៌មានដល់សាធារណជន ហើយមជ្ឈមណ្ឌលឯកសារកម្ពុជានឹងសហការជាមួយសង្គមស៊ីវិលដើម្បីពិនិត្យថាតើនីតិវិធីបែបនេះអាចយកមកអនុវត្តបានដែរឬទេ ។

**ឆាំង យុ**

# ទិវៈយោគកថា

យើងទាំងអស់គ្នាមកជួបជុំនៅទីនោះដើម្បីប្រារព្ធពិធីរំឭកដល់វិញ្ញាណក្ខន្ធរបស់វីរជនស្នេហាជាតិ ព្រះសង្ឃ បញ្ញវន្ត និស្សិត និងប្រជាជនកម្ពុជាទាំងអស់ ដែលបាត់បង់ជីវិតដោយអំពើឧក្រិដ្ឋកម្មសាហាវព្រៃផ្សៃបំផុតក្នុងរបបប្រល័យពូជសាសន៍ ប៉ុល ពត ។

ថ្ងៃ២០ឧសភាគឺជាថ្ងៃគោលការណ៍ប្រល័យជាតិរបស់របប ប៉ុល ពត និងចាប់អនុវត្តលើទូទាំងប្រទេស ។


សាន្ត សុខ បច្ចុប្បន្ន

យើងរំឭកនៅថ្ងៃនេះគឺយើងរំឭកដល់វិញ្ញាណក្ខន្ធខ្មែរជាងបីលានបីសែននាក់ដែលត្រូវឃាតករអាវខ្មៅធ្វើទុក្ខទារុណកម្ម វ៉ៃ កាប់សម្លាប់យ៉ាងអណោចអធ័ម ។ ដោយឡែកភស្តុតាងឧក្រិដ្ឋកម្មនៅគ្រប់ឃុំក្នុងស្រុកព្រៃកប្បាសយើងនេះវិញមានកន្លែងឧក្រិដ្ឋកម្មចំនួន៨៣កន្លែង ដែលរបបនេះបានចាត់តាំងឡើងជាទីតាំងឧក្រិដ្ឋកម្មសម្លាប់ជាតិ មានរណ្តៅកប់សាកសពធំចំនួន១៥២ រណ្តៅមធ្យម២០៧ និងរណ្តៅតូចចំនួន៨៨៦ ដូចជានៅភូមិឫស្សីភូមិទួលក្រាំង និងភូមិកំពង់ចកស្ទន់មុនី ។ល ។ រណ្តៅនីមួយៗមានសាកសពពី១០០ទៅ២០០នាក់ ។ ជាក់ស្តែងទៅទៀត នៅក្នុងឃុំបានកាមយើងនេះមានកន្លែងកប់សាកសពចំនួន៩កន្លែង សរុបរណ្តៅទាំងធំទាំងតូចមានចំនួន៨៧រណ្តៅ ដូចជានៅភូមិទួលក្រាំង ភូមិកុងអេង ដែលមួយរណ្តៅៗមានសាកសពរាប់រយនាក់ នៅភូមិដូងខ្ពស់ ភូមិចំបើក ភូមិប្រមូរស ទួលស្រះ ទួលខ្នងបិណ្ឌ ពោធិ៍តាណយ និងត្រពាំងកំប៉ូតរំពាក់ ជាដើម ។ល ។

តាមឯកសារដែលយើងស្រាវជ្រាវនិងពាក្យបណ្តឹងរបស់គ្រួសារជនរងគ្រោះពីឆ្នាំ១៩៧៩ គ្រាន់តែនៅក្នុងស្រុកព្រៃកប្បាសយើងនេះ ក្នុងរយៈពេល៣ឆ្នាំ៨ខែនិង២០ថ្ងៃ ប្រជាជនកម្ពុជាត្រូវពួកវាសម្លាប់និងស្លាប់ដោយអត់អាហារចំនួន២៧,៦៦៣នាក់ ។

១) សូមស្មារតីថ្ងៃ២០ឧសភាដែលជាថ្ងៃកាន់មរណទុក្ខជាប្រវត្តិសាស្ត្ររបស់ប្រជាជនកម្ពុជា ស្ថិតនៅជាប់ជានិច្ចនៅក្នុងក្រអៅបេះដូងរបស់កូនខ្មែរគ្រប់ៗរូប ។

២) ថ្ងៃទី២០ឧសភា យើងទាំងអស់គ្នាសូមលំឱនកាយ វាចាចិត្ត រំឭកដល់គុណូបការគុណអ្នកដែលបានលាចាកលោកយើងនេះទៅ ។

៣) ជីវិតមនុស្សសត្វដែលកើតឡើងក្នុងលោកសន្និវាសនេះតែងតែរលាយសាបសូន្យទៅវិញតាមច្បាប់ធម្មជាតិរបស់វាគឺធ្វើដំណើរទៅតាមចលនានៃបដិច្ចសមុប្បាទធម៌ ប៉ុន្តែការស្លាប់របស់ប្រជាជនកម្ពុជាជាងបីលាននាក់នេះគឺមិនមែនជាកត្តាកំណត់របស់ធម្មជាតិនោះទេ នេះគឺជាភាពអត្តនោម័តិយ៉ាងពិតប្រាកដរបស់ពួក ប៉ុល ពត, អៀង សារី, ខៀវ សំផន, សុន សេន, តាម៉ុក និង នួន ជា ដែលជាមេឃាតករប្រល័យពូជសាសន៍ ដែលបុរាណទំនាយកំណត់ថា "ទមិឡអត់សាសនា"គ្មានមនោសញ្ចេតនាគ្មានការឈឺចាប់ គ្មានមនុស្សធម៌និងសីលធម៌អ្វីទាំងអស់ គឺមានតែចិត្តឃោរឃៅនិងផ្តាច់ការប៉ុណ្ណោះ ។

"ទុកក៏មិនចំណេញ ដកចេញក៏មិនខាត" "ជីកស្មៅជីកទាំងឫស" ពាក្យស្លោកប៉ុន្មានម៉ាត់របស់ពួកនេះធ្វើឲ្យឈាមនិងទឹកភ្នែកជនស្លូតត្រង់ហូរក្រាលពេញដែនទីនៃមាតុភូមិទាំងមូល!

ស្លាប់ដោយស្រេកឃ្លានជាទីបំផុត! ស្លាប់ទាំងចុកចាប់ពើត-ផ្សារ អយុត្តិធម៌ណាស់ ពួកវាសាហាវឃោរឃៅណាស់ ។ គេយកប្រវ៉ាក់ ខ្នោះឃ្នាង ចំពុះទុង ត្បូងចបគល់ឫស្សី ភ្លៅរទេះធាងត្នោត ធ្វើជាអាវុធប្រល័យជាតិ ។ គេដកក្រចក អារ-កវះពោះ ឆក់ខ្សែភ្លើង ឃុមមុខ ចងស្លាបសេក ជ្រមុជទឹក ឲ្យសត្វមានពិសទិច និងដុតទាំងរស់ ទាំងអស់នេះជាវិធីសួរចម្លើយ ។ មុនសម្លាប់គេសម្រាតសំពត់ខោអាវអស់នៅតែខ្លួនទទេ រួចគេចងដណ្តើរទាំងសួរយកទៅវ៉ៃចោលទាំងរណ្តៅៗ កូនង៉ែត កូនក្មេងបានត្រូវចាប់បោកនឹងគល់ឈើ ជីវិតដូចសត្វធាតុ ស្លាប់ដូចតិរច្ឆានទាំងក្តីស្រេកឃ្លាន សំពះអង្វរសុំតែរស់ ស្រែករកយុត្តិធម៌ ប៉ុន្តែគ្មានអ្នកណាម្នាក់មកជួយឡើយ ទីបំផុតគេនាំគ្នាទៅចោល

យើងអស់ ។

អ្នកស្លាប់ ស្លាប់ទាំងមិនអស់ចិត្ត ទាំងបិទភ្នែកមិនជិត ទាំងទុក្ខសោកវេទនា ឈឺចាប់រមួលផ្សា ។ ព្រលឹងលាកចាករូបកាយនៅសល់តែគំនរឆ្អឹង ហើយត្រូវពួកជនពាលគាស់កកាយរកមាសបោលឆ្អឹង គរសសំព្រុះលើផែនដី និងត្រូវសត្វគោជ្រូកស៊ីសត្តិរច្ឆានអូសកកាយ នៅសេសសល់តិចតួចនៅពួនសម្ងំក្នុងចេតិយខ្វាចពួកទមិឡអប្រិយវាចង់រំលាយចោលទៀត ។ ទេ! ទេ! អដ្ឋិធាតុយើងខ្ញុំគឺជាវត្ថុតាងប្រវត្តិសាស្ត្រ ។

៤) វិញ្ញាណក្ខន្ធជនស្លូតត្រង់ស្នេហាជាតិទាំងឡាយ

យើងខ្ញុំទាំងអស់គ្នាចូលរួមដោយក្ដីរន្ធត់ក្ដុកក្ដួល ឈឺចាប់ខ្លោចផ្សា កំហឹងឈឺចាប់ជានិច្ច ជាមួយវិញ្ញាណក្ខន្ធអ្នកទាំងឡាយ ហើយយើងខ្ញុំសូមលំឱនកាយគោរពដឹងគុណនិងចងចាំជានិច្ចចំពោះការលះបង់សព្វបែបយ៉ាងនិងស្មារតីតស៊ូ ធ្វើឲ្យសម្រេចបានភារកិច្ចជាប្រវត្តិសាស្ត្រសង្គ្រោះមាតុភូមិកម្ពុជាឲ្យរស់ឡើងវិញនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។

វិញ្ញាណក្ខន្ធអ្នកស្លូតត្រង់ស្នេហាជាតិទាំងឡាយ!

យោងតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ដោយបានឯកភាពពីអង្គការសហប្រជាជាតិ និងបណ្ដាប្រទេសផ្ដល់ជំនួយមួយចំនួនទៀត នៅពេលដ៏ខ្លីខាងមុខនេះយើងបានបើកឡើងនូវអង្គជំនុំជម្រះវិសាមញ្ញមួយកាត់ទោសជាលក្ខណៈអន្តរជាតិនូវមេក្លោងខុក្រិដ្ឋកម្មប្រល័យពូជសាសន៍ខ្មែរក្រហម ដែលជាមេខុក្រិដ្ឋជនប្រវត្តិសាស្ត្រប្រល័យមនុស្ស ។

សូមដួងព្រលឹងអ្នកទាំងឡាយបានស្ងប់សុខ យើងខ្ញុំទាំងអស់គ្នាមិនព្រងើយកន្តើយទេ ចូលរួមលើកសំណូមពរដោយទទូចជាមួយរាជរដ្ឋាភិបាលក្នុងដំណើរការឲ្យមានការកាត់ទោសនេះ ។

អង្គពិធីទាំងមូលជាទីគោរព!

ដូច្នេះដើម្បីជាបដិការគោរពគុណ សងគុណ និងគោរពវិញ្ញាណក្ខន្ធរបស់ប្រជាជនកម្ពុជាស្លូតត្រង់ទាំងអស់ ខ្ញុំព្រះករុណាខ្ញុំសូមអារាធនាព្រះករុណាគ្រប់ព្រះអង្គមេត្តាចម្រើននូវសត្តប្បរណាភិធម្ម "បង្សុកូល" ដើម្បីចម្រាញ់យកកុសលរាសីឧទ្ទិសជូនចំពោះដួងព្រលឹងនិងវិញ្ញាណក្ខន្ធរបស់អស់លោកទាំងអស់នោះ ។

ដោយសច្ចវាចានេះ សូមគុណានុភាពនៃព្រះរ័ត្នត្រៃ ព្រមទាំងបុញ្ញកុសលដែលយើងខ្ញុំបានបំពេញក្នុងថ្ងៃនេះ សូមបានជាឧបត្ថម្ភកម្មជួយជ្រោមជ្រែងដួងព្រលឹងទាំងឡាយបាននៅបដិសន្ធិនិងសោយសុខស្ងប់ក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ ។

សូមអរព្រះគុណនិងអរគុណ, សូមអារាធនា

**សាន្ត សុខ**

# ស្ដាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្ដីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុមួយចំនួនដូចតទៅ ÷

- វិទ្យុ FM១០២MHz របស់មណ្ឌលពត៌មានស្ត្រីកម្ពុជា រៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង ៧ៈ៣០-៧ៈ៤៥ល្ងាច ។
- វិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង ៧-៧ៈ៣០ព្រឹក និងម៉ោង៧ៈ០០-៧ៈ៣០ល្ងាច ។
- វិទ្យុ FM៩៩MHz ខេត្តព្រះវិហារ រៀងរាល់ថ្ងៃនៅម៉ោង ៧ៈ០០-៧ៈ៣០ព្រឹក និងម៉ោង៦ៈ៣០-៧ៈ០០ល្ងាច ។
- វិទ្យុ FM១០៣.២៥MHz ខេត្តបាត់ដំបង រៀងរាល់ថ្ងៃនៅម៉ោង ៩ៈ០០-៩ៈ៣០ព្រឹក និងម៉ោង៣ៈ០០-៣ៈ៣០ រសៀល ។

នៅក្នុងពេលដ៏ខ្លីខាងមុខនេះមជ្ឈមណ្ឌលយើងនឹងពង្រីកការផ្សព្វផ្សាយនៅវិទ្យុខេត្តសៀមរាបទៀត ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្ដល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។

**ឡាត់ សោភ័ណ និង ឡេង រតនៈ**




គូរដោយ ៖ លោក សាន្ត សុខ

*(អត្ថបទសង្ខេបចេញពីចម្លើយសារភាព)*

# ហ៊ីង សុខុម
# សាស្ត្រាចារ្យមកពីសហរដ្ឋអាមេរិក

ហ៊ីង សុខុម មានស្រុកកំណើតនៅក្នុងខេត្តព្រៃវែង ។ សុខុម បានទៅរៀននៅសហរដ្ឋអាមេរិក បន្ទាប់មកវិលត្រឡប់មកប្រទេសកម្ពុជានៅឆ្នាំ១៩៧៦ ហើយត្រូវអង្គការខ្មែរក្រហមចាប់ខ្លួនបញ្ជូនមកមន្ទីរស-២១ ដោយចោទប្រកាន់ថាក្បត់បដិវត្តន៍ ។

## ប្រវត្តិ

សុខុម ត្រូវជីដូនជីតាយកទៅចិញ្ចឹមបីបាច់ថែរក្សានិងឲ្យរៀនសូត្រនៅសាលាបឋមសិក្សាព្រែកហ្លួង ក្នុងស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។ ឆ្នាំ១៩៤៨ សុខុម ទៅរស់នៅជាមួយបងថ្លៃជានាយកសាលាបឋមសិក្សាកណ្តាល ។ ឆ្នាំ១៩៥០ សុខុម ផ្លាស់ទៅរៀននៅវិទ្យាល័យទំនើប ។ មានគ្រូបារាំងម្នាក់ឈ្មោះ បាតូលី និងគ្រូជនជាតិខ្មែរឈ្មោះ ហុង ហឿង ឌឿង ណែនាំឲ្យ សុខុម ស្គាល់មនុស្សជាច្រើននាក់ ។ ឆ្នាំ១៩៥៤ សុខុម ប្រឡងជាប់ឌីប្លូម ។ គ្រូបង្រៀនជាជនជាតិបារាំងបីនាក់ឈ្មោះ កាស ស្តែក, រ៉ូ ស៊ាន់ និង ព្រុំ ចុស បានបញ្ចូលមនោគមវិជ្ជាប្រតិកិរិយាដល់ សុខុម ឲ្យស្រឡាញ់សង្គមមូលធន ។

ក្រោយពីប្រឡងជាប់សញ្ញាបត្របាក់ឌុបនៅឆ្នាំ១៩៥៦ សុខុម ដាក់ពាក្យសុំអាហារូបករណ៍ទៅសិក្សានៅសហរដ្ឋអាមេរិក ។

ចុងឆ្នាំ១៩៥៧ សុខុម បានទៅបង្រៀនសិស្សនៅអនុវិទ្យាល័យកម្ពុជបុត្របានរយៈពេលពីរខែ ក៏ឈប់វិញដោយសារជាប់រវល់រៀនភាសាអង់គ្លេសដើម្បីត្រៀមខ្លួនទៅរៀននៅអាមេរិក ។ មុនពេលចាកចេញទៅសហរដ្ឋអាមេរិក សុខុម បានទទួលការហ្វឹកហ្វឺនពីគ្រូជនជាតិអាមេរិកជាច្រើននាក់ និងបានមើលខ្សែភាពយន្តស្តីអំពីសហរដ្ឋអាមេរិក ។

ខែ៦ ឆ្នាំ១៩៥៨ សុខុម បានចាកចេញពីប្រទេសកម្ពុជាទៅរៀននៅសាកលវិទ្យាល័យ ប៊ឹកនែល ក្នុងរដ្ឋ ដេនស៊ីលវេនៀ សហរដ្ឋអាមេរិក ។

ឆ្នាំ១៩៦២ សុខុម បានបញ្ចប់ការសិក្សានិងទទួលសញ្ញាបត្របរិញ្ញាផ្នែកនយោបាយនិងសេដ្ឋកិច្ច និងបន្តការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកសេដ្ឋកិច្ចនៅទីក្រុងប៉ារីសរហូតដល់ឆ្នាំ១៩៦៣ ទើបត្រឡប់មកប្រទេសកម្ពុជា ។

ឆ្នាំ១៩៦៤ សុខុម បានវិលត្រឡប់ទៅប្រទេសអាមេរិកវិញ និងសុំបានអាហារូបករណ៍ពីគ្រឹះស្ថានអាស៊ីនៅទីក្រុងញូវយ៉ក និងបានរៀបការជាមួយស្ត្រីហ្វីលីពីនម្នាក់ឈ្មោះ គ្រីស្ទីន ប៉ាទ័រ ហើយមានកូនពីរនាក់ ។

ក្រោយព្រឹត្តិការណ៍រដ្ឋប្រហារនៅឆ្នាំ១៩៧០ សុខុម បានចូលជាសមាជិករណសិរ្សរួបរួមជាតិតាមរយៈឈ្មោះ ឌិក សាគុន និង ជួន មុម្ម ។ សុខុម ត្រូវបានចាត់តាំងឲ្យធ្វើជាតំណាងក្រុមទំនាក់ទំនងជាមួយជនជាតិអាមេរិកដែលគាំទ្រការតស៊ូរបស់ប្រជាជនកម្ពុជា ។ សុខុម បានបំពេញភារកិច្ចយ៉ាងស្មោះត្រង់បំផុត ។

នៅខែ១២ឆ្នាំ១៩៧៤ ដោយសារតែមានការថ្នាំងថ្នាក់ជាមួយអង្គការបដិវត្តន៍អំពីវិវត្តន៍រហ័សពេកនៃនយោបាយកសាងសង្គមនិយមរបស់អង្គការ ជាពិសេសការបំបាត់ទីផ្សារលក់ដូរមិនឲ្យមានការចាយលុយ និងការបំបាត់កម្មសិទ្ធិឯកជនក្នុងខណៈពេលដែលប្រទេសកម្ពុជាមិនទាន់មានមូលដ្ឋានរឹងមាំទាំងផ្នែកសេដ្ឋកិច្ចនយោបាយ និងមនោគមវិជ្ជា សុខុម បានចូលជាសមាជិក សេ.អ៊ី.អានៅទីក្រុងញូវយ៉ក តាមរយៈឈ្មោះ ដុន លុស និង កូវ៉ាវ៉ែ ។ អ្នកទាំងពីរចាត់តាំងឲ្យ សុខុម ធ្វើសកម្មភាពបំផុសបំផុលគំនិតសេរីនិយម ។ ឈ្មោះទាំងពីរនេះខស្សរាហ៍ហៅ សុខុម ណែនាំអំពីសភាពការណ៍ទូទៅនៅក្នុងសកលលោកនិងបញ្ហាប្រទេសកម្ពុជា ។ សុខុម មិនទទួលយកគំនិតទាំងស្រុងរបស់ជនជាតិអាមេរិកទាំងពីរនាក់នេះទេ ។ គាត់ប្រាប់អ្នកទាំងពីរថា ប្រទេសកម្ពុជាទើបតែឆ្លងកាត់សង្គ្រាមវិនាសកម្ម ដូច្នេះបដិវត្តន៍កម្ពុជាត្រូវការពេលវេលាវែងដើម្បីពង្រឹងនិងពង្រីកលទ្ធិប្រជាធិបតេយ្យ ហើយប្រជាជនទូទាំងប្រទេសត្រូវរួមចំណែកស្តារសេដ្ឋកិច្ចជាតិ

សិន ។ ក្រៅពីនេះ សុខុម បានចូលរៀនវគ្គទ្រឹស្តីសេរីនិយមនៅសាលាមួយក្រោមការណែនាំរបស់អាមេរិកាំង ។ ក្រោយមក សុខុម មានតួនាទីប្រមូលព័ត៌មាននិងឃោសនា ហើយបានទទួលប្រាក់ខបត្ថម្ភចំនួនពីរពាន់ដុល្លារសហរដ្ឋអាមេរិក ។ ទោះជាបានចូលជាសមាជិក សេ.អ៊ី.អា ក៏ដោយ សុខុម នៅតែបម្រើការនៅក្នុងជួររណសិរ្សជាធម្មតា ។

ដើមឆ្នាំ១៩៧៥បុគ្គលិកសេ.អ៊ី.អាទាំងអស់បានបើកការប្រជុំមួយពិភាក្សាគ្នាអំពីសង្គ្រាមនៅក្នុងប្រទេសកម្ពុជា ។ អង្គប្រជុំបានប្រគល់ភារកិច្ចឲ្យ សុខុម មើលការខុសត្រូវនិងធ្វើការជាមួយគណៈប្រតិភូរបស់កម្ពុជាប្រជាធិបតេយ្យដែលមកទស្សនានៅទីក្រុងញូវយ៉ក ។ ប្រតិភូដែលទៅដល់ទីក្រុងញូវយ៉កដឹកនាំដោយសមមិត្ត អៀង សារី មកខទ្មេសនាមអំពីសភាពការណ៍នៅកម្ពុជា ។ បន្ទាប់ពីបានចូលរួមស្តាប់បទខទ្មេសនាមរបស់ អៀង សារី និងបានចូលរួមលៀងសាយភោជន៍ជាមួយសម្តេច សីហនុ និងគណៈប្រតិភូរបស់ព្រះអង្គរួចមក សុខុម បានសរសេររបាយការណ៍អំពីនិន្នាការនយោបាយរបស់គណៈប្រតិភូផ្ញើទៅឲ្យ ដុន លុស និងអ្នកស្រី កូវ៉ាវ៉ី ។ ដុន លុស ណែនាំបន្ថែមឲ្យ សុខុម ខិតខំរៀនសូត្រពី ឈន ហៃ និង អ៊ិន សូភាព ឲ្យបានច្រើន និងពង្រឹងចំណងទាក់ទងឲ្យបានល្អជាមួយ ជួន ប្រាសិទ្ធ ។

ចុងឆ្នាំ១៩៧៥ សុខុម សុំអន្តរាគមន៍ពី ជួន ប្រាសិទ្ធ, ឈន ហៃ និង អ៊ឹង សូកាន ដើម្បីបានត្រឡប់មកប្រទេសកម្ពុជាវិញ ។ ចំណែក ដុន លុស ក៏មានបំណងចង់មកទំនាក់ទំនងជាមួយរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យនិងផ្តល់ជំនួយឲ្យរដ្ឋាភិបាលនេះដែរ ប៉ុន្តែ ជួន ប្រាសិទ្ធ បានសំណូមពរឲ្យ ដុន លុស រង់ចាំឲ្យ សុខុម ទៅដល់ប្រទេសកម្ពុជាសិន ហើយគាត់នឹងជម្រាបអំពីសភាពការណ៍កម្ពុជាឲ្យបានក្បោះក្បាយនៅពេលក្រោយ ។

ខែមិថុនា ឆ្នាំ១៩៧៦ សុខុម ត្រឡប់មកកម្ពុជា ប៉ុន្តែមុននឹងចាកចេញ សុខុម បានទៅជួប កូវ៉ាវ៉ី និង ដុន លុស ជាមុនសិន ។ អ្នកទាំងពីរបានណែនាំឲ្យគាត់ទៅទាក់ទងមនុស្សបីនាក់ឈ្មោះ ឆែ ឆែល, ស្រី រិទ្ធី និង កង បុរាជាតិ ដើម្បីភ្ជាប់ខ្សែរយៈនិងបង្កជាបក្សពួកឲ្យរីកសាយនៅក្នុងប្រទេសកម្ពុជា ដើម្បីវាយបដិវត្តន៍នៅខែមិថុនា ឆ្នាំ១៩៧៧ ។ ក្រៅពីនោះមានមនុស្សសំខាន់ៗមួយចំនួនទៀតដែល សុខុម ត្រូវទាក់ទងមាន ភោគ ឆាយ, ចាន់ យូរ៉ាន់, ចាន់ បូផា, ឈន ហៃ, ម៉ុក ស៊ីវ៉ុង (កម្មាភិបាលនៅតំបន់ព្រះវិហារ), ទិក សាគុន, ពឹង គឹមសយ, ខៀវ កុមារ, អ៊ិន សូភាព, ប៉ែន ថៅង អាន, ម៉ុក សូវុត, ឈឹម ខេត្ត, សារិន ឆាក, ជួន ប្រាសិទ្ធ, ហួត សម្បត្តិ, អ៊ីស៊ីប គន្ធី, ស៊ាន អាន, ទេព បូផា ។ ដូច្នេះ សុខុម ត្រូវរៀបចំការទាក់ទងជាមួយអ្នកទាំងអស់នោះឲ្យបានល្អ ។

## នៅប្រទេសកម្ពុជា

សុខុម មានភារកិច្ចប្រមូលព័ត៌មានស្តីអំពីសភាពការណ៍ទូទៅនៅកម្ពុជានៅក្នុងវិស័យធំៗទាំងបី % នយោបាយ សេដ្ឋកិច្ចនិងយោធា ជាពិសេសមតិមហាជនណាដែលមិនសប្បាយចិត្តនឹងបដិវត្តន៍កម្ពុជា ។

អំពីនយោបាយ ៈ តើបដិវត្តន៍កម្ពុជាប្រកាន់មាគ៌ាតាមចិនឬយ៉ាងណា? តើអង្គការបដិវត្តន៍រៀបចំប្រទេសតាមរបៀបណា? តើកម្លាំងសេរីមានកម្រិតណា? តើរៀបចំសហករណ៍តាមរបៀបម៉េច?

អំពីសេដ្ឋកិច្ច ៈ មូលហេតុអ្វីបានជាអង្គការសម្រេចមិនចាយលុយ? តើការមិនចាយលុយធ្វើឲ្យសេដ្ឋកិច្ចដំណើរការបានល្អឬយ៉ាងណា? តើអង្គការផ្អែកលើមូលដ្ឋានអ្វីដើម្បីកសាងវិស័យកសិកម្ម? តើនៅក្នុងរោងចក្រនីមួយៗផលិតអ្វីខ្លះ? តើកម្មកររៀបចំយ៉ាងណាក្នុងផលិតកម្ម និងប្រើមធ្យោបាយអ្វីខ្លះសម្រាប់ដឹកជញ្ជូន?

អំពីយោធា ៈ ស៊ើបរកចំនួនកម្លាំងទ័ពជើងគោក ជើងទឹកនិងជើងអាកាស ។

ពេលមកដល់កម្ពុជា សុខុម ត្រូវអង្គការបញ្ជូនទៅស្នាក់នៅមន្ទីរមួយជាមួយបញ្ញវន្តដទៃទៀតដែលមកពីប្រទេសអាមេរិកនិងបារាំង ។ សុខុម ខំសម្របខ្លួនទៅនឹងចលនាបដិវត្តន៍យ៉ាងខ្ជាប់ខ្ជួនតាមការណែនាំរបស់ ជួន ប្រាសិទ្ធ ។ ម្យ៉ាងទៀត ដើម្បីឲ្យស្របតាមមាគ៌ាអង្គការបដិវត្តន៍ធ្វើស្រែឲ្យបានបីតោនក្នុងមួយហិកតា សុខុម បានចូលរួមជាមតិនិងបញ្ចេញយោបល់ស្របតាមគោលជំហររបស់អង្គការ លត់ដំខ្លួនឲ្យទៅជាកម្មករ កសិករ ដើម្បីឲ្យអង្គការមើលឃើញនិងបញ្ជូនគាត់ទៅធ្វើការនៅក្រសួងការបរទេសនៅទីក្រុងញូវយ៉កតាមការស្នើសុំរបស់ ជួន ប្រាសិទ្ធ ។ ផ្ទុយទៅវិញ

អង្គការបែរជាបញ្ជូន សុខុម ទៅសហករណ៍ភូមិតាឡី ។ ការងាររបស់សុខុម នៅទីនោះគឺជញ្ជូនគុកៅអីមកដាក់នៅកន្លែងហូបបាយ ។ សុខុម ខកចិត្តយ៉ាងខ្លាំង ហើយចាប់ផ្តើមរកមករកនិន្នាការសេរីវិញ ។

**នៅសហករណ៍ភូមិតាឡី**

នៅទីនោះសុខុម, យ៉េង សារុន និង ថោង អាន បានរួមគំនិតគ្នារិះគន់ប្រធានក្រុមរបស់ខ្លួន ឈ្មោះ សាន់ និងប្រធានភូមិតាឡីឈ្មោះ យ៉ុង ថាអ្នកទាំងពីរអសមត្ថភាពរបស់អ្នកទាំងពីរក្នុងការគ្រប់គ្រង ទិតៀនអំពីការហូបចុកមិនគ្រប់គ្រាន់ និងទិតៀនភាពឥតសណ្តាប់ធ្នាប់របស់កុមារបដិវត្តន៍ដែលចូលបេះបោចដំណាំរបស់ប្រជាជន និងការបិទបាំងទោសកំហុសអ្នកដែលនៅជុំវិញខ្លួន ។

ពេលទំនេរពីការងារ សោភ័ណ, ឈឹម ខេត្ត, ប៉ែន ថោងអាន, បូច័ន្ទ និង សុខុម ពិភាក្សាគ្នាអំពីរបបចាស់ និងលើកសរសើរសហរដ្ឋអាមេរិក ។

**ការចាប់ខ្លួន**

នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៧៦ នៅម៉ោង៥:១៥ល្ងាច ឈ្មោះ សាន់ បានមកប្រាប់ សុខុម ថាអង្គការស្នើឲ្យទៅធ្វើការនៅកន្លែងផ្សេង ប៉ុន្តែតាមពិតអង្គការចាប់ខ្លួន សុខុម បញ្ជូនមកមន្ទីរ ស-២១ ។

នៅក្នុងចម្លើយសារភាពរបស់ ហ៊ីង សុខុម បានបញ្ជាក់គាត់ត្រូវសន្តិសុខនៅមន្ទីរស-២១ ឈ្មោះ ប៊ិន សួរចម្លើយចំនួន១០លើក លើកទី១នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៧៦ និងបញ្ចប់ការសរសេរលើកទី១០នៅថ្ងៃ២២ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ។ ក្រៅពីសារភាពអំពីសកម្មភាពរបស់ខ្លួន សុខុម ក៏មានសរសេរពីប្រវត្តិសាច់រឿងរបស់មនុស្សដែលពាក់ព័ន្ធមួយចំនួនដែរ ។

**អំពីសាច់ញាតិ**

ឪពុកឈ្មោះ ហ៊ីង ខាន់ មេឃុំនៅបាណាម ក្នុងខេត្តព្រៃវែង ។

ម្តាយឈ្មោះ រស់ សាត នៅភូមិព្រែកថោង ស្លាប់នៅឆ្នាំ១៩៧៣ ។

មានបងប្អូន៥នាក់ ស្រីម្នាក់ ប្រុសបួននាក់ ។ បងស្រីឈ្មោះ ខាន ស៊ីមជីន ប្តីឈ្មោះ ឃូ ផាត ធ្វើការនៅក្រសួងសិក្សាធិការជាតិនាក្រុងភ្នំពេញ ។ ប្អូនប្រុសបន្ទាប់ ឈ្មោះ ហ៊ីង សុឃឿន ធ្វើការនៅសកលវិទ្យាល័យបច្ចេកទេសមិត្តភាពខ្មែរ-សូវៀត ។ ប្អូនប្រុសម្នាក់ទៀតឈ្មោះ ហ៊ីង សំអឿន ធ្វើការនៅធនាគារជាតិនាក្រុងភ្នំពេញ ។ ប្អូនប្រុសពៅឈ្មោះ ហ៊ីង សម្បត្តិ ។

**ឈ្មោះអ្នកចូលរួមវាយប្រហារបដិវត្តន៍**

ដុន លុស ជនជាតិអាមេរិកាំង ◆ អ្នកស្រី កូរ៉ាំងវ៉ៃ ជនជាតិអាមេរិកាំង ◆ ទេព បូរី និស្សិតសកលវិទ្យាល័យញូវយ៉ក ◆ ដួន ប្រាសិទ្ធ មន្ត្រីក្រសួងការបរទេសភ្នំពេញ ◆ ឈន ហៃ នៅក្នុងប្រទេសទទួលការបរទេស ◆ អ៊ិន សុភាព មន្ត្រីក្រសួងការបរទេសភ្នំពេញ ◆ ម៉ុក សូវុត ◆ ប៉ែន ថោងអាន នៅភូមិតាឡី ◆ សូប៉ូ ត្រានៅភូមិតាឡី ◆ ម្ចាស់ ប៉ាងហៅយ៉ាង នៅភូមិតាឡី ◆ សារិន ឆាកនៅកំពង់ចាម ◆ ចន្ទី យូវ៉ាន់ នៅក្រសួងការបរទេសភ្នំពេញ ◆ ពឹងគឹមសយ ◆ អ៊ិន សូកាន នៅមន្ទីរពេទ្យ១៧មេសា ◆ ឱក សាគុណនៅកន្លែងលត់ដំទូតនៅភ្នំពេញ ◆ អ៊ី ស៊ីបគន្ធី តំណាងរណសិរ្សនៅប្រទេសស៊ុយអែត (នៅកន្លែងលត់ដំទូតនៅភ្នំពេញ) ◆ ម៉ុក ស៊ីវ៉ុងកម្មាភិបាលខេត្តព្រះវិហារ ◆ ស៊ឹង ង៉ុកថាន់ ◆ អ៊ិន តាំ ◆ ប៉ុកសំអាន ◆ អ៊ិន សួង ◆ ច័ន្ទ យូវ៉ាន់ ◆ ហួត សម្បត្តិ ឯកអគ្គរាជទូត ◆ សារិន ឆាក ◆ ឆៃ ឆែល អតីតសាស្ត្រាចារ្យ ចូលបដិវត្ត៥៥នៅបារីស ◆ ប៉ែន ថោងអាន ◆ កង បូរាជាតិ ◆ ស្រី រិទ្ធី វិស្វករ រោងចក្រស៊ីម៉ង់ត៍ ◆ ស៊ឹម សុងឡេង អតីតវិស្វករ ◆ ខៀវ កុមារ អតីតសាស្ត្រាចារ្យ ◆ ម៉ៅ សាវ៉ាន់ អតីតសាស្ត្រាចារ្យវិទ្យាសាស្ត្រ ◆ អ៊ឹង មេង គ្រុយ ។

**លី សុផល**

# ពាក្យស្លោកខ្មែរក្រហម

- ឈរជាថ់ខាតនិងគ្រប់កាលៈទេសៈ លើជំហរឯករាជ្យ ម្ចាស់ការខ្លួនទីពឹងខ្លួន កាន់កាប់ខាសនាដោយខ្លួនឯង។
- កម្ចាត់ជាថ់ខាត ជំហរណបគេ ខ្ញុំគេ សារភាពនិយម ចុះចាញ់និយម។
- ប្រយុទ្ធការពារឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពដែនដីកម្ពុជាប្រជាធិបតេយ្យ។

*(សៀវភៅកំណត់ហេតុលេខ១០៧៦)*

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ (គុកទួលស្លែង)

## រៀបចំនិងចងក្រងដោយៈ យិន នាន

(តពីលេខមុន)

| ល.រ | នាម-គោត្តនាម | មុខងារ | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ២៥៤៣ | ក ថៃគេងយិន (ស្រី) | ប្រពន្ធ គូ សំបូរ | រោងចក្រកង់ឡាន | ៨-៣-៧៧ | ១៤-៥-៧៧ |
| ២៥៤៤ | ឈុន លី ហៅ លីម (ស្រី) | ប្រធានឃ្លាំង | ថាមពល | ១-៣-៧៧ | ១៤-៥-៧៧ |
| ២៥៤៥ | អ៊ុម សឿន ហៅ នី (ស្រី) | ប្រពន្ធ ស៊ុន សួរ | ថាមពល | ៤-៤-៧៧ | ១៤-៥-៧៧ |
| ២៥៤៦ | អៀ សីង ហៅ រ៉ន (ស្រី) | ប្រធានកងតូច | ថាមពល | ១៤-៣-៧៧ | ១៤-៥-៧៧ |
| ២៥៤៧ | អ៊ឹម យ៉ុន (ស្រី) | ប្រពន្ធ ហួន ឆេង | ថាមពល | ២២-៤-៧៧ | ១៤-៥-៧៧ |
| ២៥៤៨ | សូ រឹម (ស្រី) | យុទ្ធនារី | កាត់ដេររដ្ឋ | ២៨-៤-៧៧ | ១៤-៥-៧៧ |
| ២៥៤៩ | ពៅ ស៊ីលន់ ហៅ ដែន (ស្រី) | ប្រពន្ធ គៀ ហៅ ដាន់ | កាត់ដេររដ្ឋ | ២៣-៣-៧៧ | ១៤-៥-៧៧ |
| ២៥៥០ | គុច យ៉ាយ ហៅ ហែង (ស្រី) | យុទ្ធនារី | កាត់ដេររដ្ឋ | ២៣-៣-៧៧ | ១៤-៥-៧៧ |
| ២៥៥១ | សេង ហន ហៅ នី (ស្រី) | ប្រពន្ធ គីម ស្រុង | ថាមពល | ១០-៣-៧៧ | ១៤-៥-៧៧ |
| ២៥៥២ | កុល ហ៊ី ហៅ យឹម (ស្រី) | យុទ្ធនារី | ថាមពល | ៣-៣-៧៧ | ១៤-៥-៧៧ |
| ២៥៥៣ | សឿ អឿម ហៅ រី (ស្រី) | អនុកងហ | កសិកម្មរដ្ឋ | ៣-៤-៧៧ | ១៤-៥-៧៧ |
| ២៥៥៤ | ជូ បាក់ហ៊ាង ហៅ ភឿន (ស្រី) | ប្រពន្ធ ម៉ិល ការ៉ន | កសិកម្មរដ្ឋ | ១៧-៣-៧៧ | ១៤-៥-៧៧ |
| ២៥៥៥ | ចាយ សូយ ហៅ នឹម (ស្រី) | ប្រពន្ធ សោ ថាត | ក្រសួងការបរទេស | ១-៤-៧៧ | ១៤-៥-៧៧ |
| ២៥៥៦ | ម៉េង សំអុល ហៅ ធី (ស្រី) | ប្រពន្ធ ឈាង អេង ហៅ ឃី | ក្រសួងការបរទេស | ១៦-៣-៧៧ | ១៤-៥-៧៧ |
| ២៥៥៧ | ស្រី ស៊ន ហៅ សៀន (ស្រី) | ប្រពន្ធ ម៉ៅ ឆួយ | ក្រសួងការបរទេស | ១៣-៣-៧៧ | ១៤-៥-៧៧ |
| ២៥៥៨ | គឹក អ៊ិនលី ហៅ នូ (ស្រី) | ប្រពន្ធហ៊ីហួយហេន ហៅ សោ | ក្រសួងការបរទេស | ៧-៥-៧៧ | ១៤-៥-៧៧ |
| ២៥៥៩ | ថាច់ ឆាន ហៅ សំ (ស្រី) | ប្រពន្ធ ទេព សំអាន ហៅ សំ | ក្រសួងការបរទេស | ១៧-៣-៧៧ | ១៤-៥-៧៧ |
| ២៥៦០ | ណាំ យ៉ា ហៅ នី (ស្រី) | ប្រពន្ធ ហ៊ឹម | ដឹកជើងទឹក | ៤-៤-៧៧ | ១៤-៥-៧៧ |
| ២៥៦១ | សោ មឹន ហៅ រឿន (ស្រី) | ប្រពន្ធ ហ៊ាង | ដឹកជើងទឹក | ៨-៤-៧៧ | ១៤-៥-៧៧ |
| ២៥៦២ | ភ៉ា នី ហៅ រី (ស្រី) | ប្រពន្ធ សំអុល | ដឹកជើងទឹក | ៧-៤-៧៧ | ១៤-៥-៧៧ |
| ២៥៦៣ | ជា រឿន ហៅ រ៉ុង (ស្រី) | ប្រពន្ធ គុច យ៉ាន់ | ដឹកជើងទឹក | ២៤-៤-៧៧ | ១៤-៥-៧៧ |
| ២៥៦៤ | ម៉ក ឆេង (ស្រី) | ប្រពន្ធ អាវ នី | ដឹកជើងទឹក | ១-៤-៧៧ | ១៤-៥-៧៧ |
| ២៥៦៥ | ប៉ុល វុទ្ធី | កុមារកូនសក្តិ៥ | ដឹកជើងទឹក | ២៦-៤-៧៧ | ១៤-៥-៧៧ |
| ២៥៦៦ | វត្តនី (ស្រី) | ប្រពន្ធឈឿនឱឈាង ហៅឱសា | តំបន់១០៤ | ២៥-៣-៧៧ | ១៤-៥-៧៧ |
| ២៥៦៧ | ជ វិឡាត់ ហៅ ដា (ស្រី) | ប្រពន្ធ សូ ឡាងឡេង | កងពល៩២០ | ៦-៥-៧៧ | ១៤-៥-៧៧ |
| ២៥៦៨ | អៀ លី ហៅ ភ៉ា (ស្រី) | មេក្រុម | កងពល៩២០ | ៣-៥-៧៧ | ១៤-៥-៧៧ |
| ២៥៦៩ | យឹម សុម៉ាភ៉ា ហៅ រុន (ស្រី) | យុទ្ធនារី | កងពល៩២០ | ៤-៥-៧៧ | ១៤-៥-៧៧ |

| | | | | | |
|---|---|---|---|---|---|
| ២៥៧០ | អៀ សៀត ហៅ រិន (ស្រី) | ប្រពន្ធ អ៊ាជី ហៅ សយ | កងពល៩២០ | ២២-៤-៧៧ | ១៤-៥-៧៧ |
| ២៥៧១ | ជ ស៊ីយន ហៅ លាប (ស្រី) | ប្រពន្ធ សៀង ផា | តំបន់៥០៥ | ២៧-៤-៧៧ | ១៤-៥-៧៧ |
| ២៥៧២ | កែ ហាក់ ហៅ ជឿន (ស្រី) | ប្រពន្ធ ផល្លា ហៅ ហ៊ុម | កងពល៤៥០ | ៣១-៣-៧៧ | ១៤-៥-៧៧ |
| ២៥៧៣ | ឡុង យ៉ាត់ ហៅ យ៉ាត (ស្រី) | ប្រពន្ធ រស់យន ហៅ ពាន់ | កងពល៤៥០ | ៣០-៣-៧៧ | ១៤-៥-៧៧ |
| ២៥៧៤ | គឹម គេង ហៅ យន់ (ស្រី) | ប្រពន្ធ អៀឆយ ហៅ យាន | កងពល៤៥០ | ២២-៤-៧៧ | ១៤-៥-៧៧ |
| ២៥៧៥ | ប៉ាល់ ឆនឆាន ហៅ ណាន់ (ស្រី) | ប្រពន្ធ ម៉ី ផាត់ | បឹងត្របែក | ២៧-៤-៧៧ | ១៤-៥-៧៧ |
| ២៥៧៦ | គឹម ឡាយ ហៅ ភក្តិ (ស្រី) | ប្រពន្ធ ស៊ិន ហៅ រី | តំបន់១០៣ | ២៦-៤-៧៧ | ១៤-៥-៧៧ |
| ២៥៧៧ | សេង សង្វាត (ស្រី) | ប្រពន្ធ ស៊ិន ភុំ | ស្ទឹងមានជ័យ | ១៤-៤-៧៧ | ១៤-៥-៧៧ |
| ២៥៧៨ | អ៊ុក សាផុន ហៅ ភា (ស្រី) | ប្រពន្ធ ផាត់ ស៊ីផូ | សាធារណការ | ៣-៥-៧៧ | ១៤-៥-៧៧ |
| ២៥៧៩ | ង៉ែត ង៉ានី (ស្រី) | ប្រពន្ធ ស៊ុយ គឹមថាន | អគ្គិសនីទី២ | ១០-៥-៧៧ | ១៤-៥-៧៧ |
| ២៥៨០ | ញឹក គឹមឡាង (ស្រី) | ប្រពន្ធ ស្វាយ ហន | អគ្គិសនីទី១ | ១០-៥-៧៧ | ១៤-៥-៧៧ |
| ២៥៨១ | ម៉ម ស៊ីវចេង (ស្រី) | ប្រពន្ធ យូ គឹមអេង | ស្ទឹងមានជ័យ | ១០-៥-៧៧ | ១៤-៥-៧៧ |
| ២៥៨២ | ស៊ិន វ៉ាវ៉ាន (ស្រី) | ប្រពន្ធ ហាក់ ស៊ុនឡាយ | ស្ទឹងមានជ័យ | ១០-៥-៧៧ | ១៤-៥-៧៧ |
| ២៥៨៣ | ជា សុខា (ស្រី) | ប្រពន្ធ គុយត្រូ ហៅ ត្រុង | ស្ទឹងមានជ័យ | ១០-៥-៧៧ | ១៤-៥-៧៧ |
| ២៥៨៤ | ឈុន ហេង (ស្រី) | ប្រពន្ធ តែ ម៉េងគង់ | អគ្គិសនីទី១ | ១០-៥-៧៧ | ១៤-៥-៧៧ |
| ២៥៨៥ | សៅ សំបុណ្យ (ស្រី) | ប្រពន្ធ ទន់ ប៊ុនហុង | អគ្គិសនីទី១ | ១០-៥-៧៧ | ១៤-៥-៧៧ |
| ២៥៨៦ | ស៊ិន គិកស៊ុម ហៅ ស៊ីន (ស្រី) | ប្រពន្ធ លី សំផាត់ | រដ្ឋករទឹក | ១០-៥-៧៧ | ១៤-៥-៧៧ |
| ២៥៨៧ | លី សុភាព (ស្រី) | ប្រពន្ធ តែ សាកឈួន | អគ្គិសនីទី១ | ១០-៥-៧៧ | ១៤-៥-៧៧ |
| ២៥៨៨ | ឈឹម សុផន ហៅ ទូច (ស្រី) | ប្រពន្ធ តូច ភឿន | សាធារណការ | ២-៣-៧៧ | ១៤-៥-៧៧ |
| ២៥៨៩ | មុី ចាន់សូផាស៊ី ហៅ ផា | ប្រពន្ធ កែ យាន | អគ្គិសនីទី២ | ២២-៤-៧៧ | ១៤-៥-៧៧ |
| ២៥៩០ | សំ ឃិន (ស្រី) | ម្តាយមីង ទឹម សុផាត | អគ្គិសនីទី១ | ២២-៤-៧៧ | ១៤-៥-៧៧ |
| ២៥៩១ | ឡោ បូណារី ហៅ ស៊ូ(ស្រី) | ប្រពន្ធ អួន ថុល | ស្ទឹងមានជ័យ | ២២-៤-៧៧ | ១៤-៥-៧៧ |
| ២៥៩២ | ជា សុកដៃ (ស្រី) | ប្រពន្ធ រិត រឿន | អគ្គិសនីទី១ | ២២-៤-៧៧ | ១៤-៥-៧៧ |
| ២៥៩៣ | បួ រី (ស្រី) | ប្រពន្ធ ខន | ដែកំពង់សោម | ៤-៥-៧៧ | ១៤-៥-៧៧ |
| ២៥៩៤ | ញ៉ិក ឆិច ហៅ ថាត (ស្រី) | ប្រពន្ធ ធឹម ធួន ហៅ ដែន | ពាណិជ្ជកម្មរដ្ឋ | ២៣-៣-៧៧ | ១៤-៥-៧៧ |
| ២៥៩៥ | ព្រីញ អ៊ិន ហៅ វៀម (ស្រី) | ប្រពន្ធ ហង់ ហឿន ហៅ ហំ | ពាណិជ្ជកម្មរដ្ឋ | ៨-៥-៧៧ | ១៤-៥-៧៧ |
| ២៥៩៦ | ប៉ិ ផាត់ (ស្រី) | ប្រពន្ធ អា ប៉ាង | សេនាធិការ | ១៩-៤-៧៧ | ១៤-៥-៧៧ |
| ២៥៩៧ | ប៊ុន ឡេង ហៅ ឡុង (ស្រី) | ប្រពន្ធ សៀង ប៉ោសែ | មន្ទីរ ស-១១ | ១០-៣-៧៧ | ១៤-៥-៧៧ |
| ២៥៩៨ | គាន់ យ៉ានី ហៅ យ៉ាន (ស្រី) | ប្រពន្ធ សេង កេងហ៊ុន | ពាណិជ្ជកម្មរដ្ឋ | ១៩-៣-៧៧ | ១៤-៥-៧៧ |
| ២៥៩៩ | តែ ថន (ស្រី) | ប្រពន្ធគឹម ប្រេង ហៅ ផល | កងពល៥០២ | ២២-៤-៧៧ | ១៤-៥-៧៧ |
| ២៦០០ | ថៃ សុខា (ស្រី) | កូន ថៃ ឡេង | ពេទ្យ១៧ | ២២-៤-៧៧ | ១៤-៥-៧៧ |

**(នៅមានត)**

# រឿងរ៉ាវដែលមិនចេះសាបសូន្យ

**ប៊ួយ ស្រេង**
**អតីតចាងហ្វាងការសែត**


ស្រេង ម៉ាប់ មុនឆ្នាំ១៩៧៥

*ស្រេង ម៉ាប់ រក្សាទុករូបថតក្រុមគ្រួសាររបស់គាត់ចំនួន៤សន្លឹកដែលថតតាំងពីមុនឆ្នាំ១៩៧៥ ។ រូបថតទាំង៤សន្លឹកនេះមានរូបថតឪពុកម្តាយរបស់គាត់ រូបថតបងប្អូនរបស់គាត់ដែលថតនៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ និងរូបមួយសន្លឹកជារូបថតរបស់គាត់ផ្ទាល់ថតនៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ។ ឪពុករបស់គាត់ឈ្មោះ ប៊ួយ ស្រេង គឺជាចាងហ្វាងការសែត“សង្គ្រោះខ្មែរ” ។ អង្គការបានហៅ ស្រេង ទៅប្រជុំជាមួយយុវជននៅក្នុងភូមិនៅឆ្នាំ១៩៧៦ ហើយ ស្រេង បាត់ខ្លួនរហូតតាំងពីពេលនោះមក ។ ខាងក្រោមនេះគឺជាការរៀបរាប់របស់ ស្រេង ម៉ាប់ ៖*

បងប្អូនរបស់ខ្ញុំ៩នាក់ កើតនៅទីកន្លែងខុសៗគ្នាទាំងអស់ ពីព្រោះប៉ារបស់ខ្ញុំធ្វើជាគ្រូបង្រៀនចល័តច្រើនខេត្តហើយម្តាយរបស់ខ្ញុំទៅតាមឪពុកខ្ញុំគ្រប់ទីកន្លែង ។

ឪពុកខ្ញុំមានស្រុកកំណើតនៅខេត្តព្រៃវែង ។ ដំបូងឡើយគាត់ធ្វើទាហានកាន់ខាងកុងតាប (អ្នកកាន់លុយ) ។ ក្រោយមកគាត់ចូលធ្វើគ្រូបង្រៀន ហើយត្រូវចាត់តាំងឲ្យទៅបង្រៀន នៅខេត្តពោធិសាត់ ។ គាត់បង្រៀនថ្នាក់ឌីប្លូម ។ នៅទីនោះគាត់បានចាប់ចិត្តស្រលាញ់ម្តាយរបស់ខ្ញុំ ឈ្មោះ កង សុជាត ដែលជាកូនរបស់ថៅកែបាវឈ្មោះ កង ហួត ។ ម្តាយរបស់ខ្ញុំរៀនបានត្រឹមថ្នាក់ឌីប្លូមក៏ឈប់រៀន ហើយជួយលក់ដូរជាមួយឪពុកម្តាយរបស់គាត់ ។ គាត់ទាំងពីរនាក់ស្រលាញ់គ្នាទៅវិញទៅមក ។ ក្រោយពីគាត់ទាំងពីររៀបការហើយ គាត់មានកូនស្រីម្នាក់ឈ្មោះ ប៊ួយ ណារី ហៅ មុំ ។ ក្រោយមកម្តាយខាងឪពុកខ្ញុំឈ្មោះ យាយម៉ូយ បានឲ្យឪពុកខ្ញុំឲ្យរៀបការប្រពន្ធមួយទៀត ។ ពេលដែលម្តាយរបស់ខ្ញុំមានផ្ទៃពោះកូនទី២ ប្រពន្ធទី២របស់ប៉ាក៏មានផ្ទៃពោះដំណាលគ្នាដែរ ហើយអ្នកទាំងពីរសម្រាលកូននៅក្នុងខែតែមួយ ។ ឪពុករបស់ខ្ញុំវិលទៅរកម្តាយខ្ញុំនៅឯខេត្តពោធិសាត់វិញ និងផ្លាស់ទៅបង្រៀននៅខេត្តកោះកុង ។ នៅកោះកុងម្តាយខ្ញុំកើតកូនប្រុសមួយទៀតដាក់ឈ្មោះ ប៊ួយ វង្ស ។ ពីឆ្នាំក្រោយឪពុកខ្ញុំផ្លាស់ទៅបង្រៀននៅខេត្តក្រចេះ ។ ម្តាយខ្ញុំនិងកូនៗទៅតាមជាមួយឪពុកខ្ញុំគ្រប់ទីកន្លែង ។ នៅខេត្តក្រចេះម្តាយខ្ញុំកើតបានខ្ញុំ ។ ឈ្មោះពិតរបស់ខ្ញុំគឺ ប៊ួយ សុម៉ាចា ប៉ុន្តែដោយសារកាលពីក្មេងខ្ញុំធាត់ពេកទើបបងប្អូនខ្ញុំហៅខ្ញុំ ម៉ាប់ ។ គ្រួសារខ្ញុំមានជីវភាពធូរធារសមរម្យដោយសារប្រាក់បៀវត្សរ៍របស់ឪពុកខ្ញុំច្រើនគួរសម ។


ប៊ួយ ស្រេង មុនឆ្នាំ១៩៧៥

ក្រោយមក ឪពុកខ្ញុំឈប់ធ្វើគ្រូបង្រៀនមកឈរឈ្មោះជាតំណាងរាស្ត្រនៅខេត្តព្រៃវែង ប៉ុន្តែគាត់ចាញ់ឆ្នោត ហើយវិលទៅរស់នៅទីក្រុងភ្នំពេញវិញ បើកក្រុមហ៊ុនកាសែតមួយឈ្មោះ “ប្រយោជន៍ខ្មែរ” ។ កាសែតនេះមានទីស្នាក់ការនៅទល់មុខស្តាតអូឡាំពិក ។ ក្រោយមកឪពុកខ្ញុំជាប់គុកនៅទួលគោកអស់រយៈពេល១ឆ្នាំ ដោយសារកាសែតរបស់គាត់ប្រឆាំងជាមួយ លន់ នល់ ។

ពេលចេញពីគុកមកវិញ ឪពុកខ្ញុំបង្កើតកាសែតមួយទៀតឈ្មោះ “សង្គ្រោះខ្មែរ” មានទីតាំងនៅកន្លែងដដែល ។ យើងមានផ្ទះមួយទៀតនៅបឹងកេងកង ។ ពេលខ្លះយើងទៅដេកនៅទីស្នាក់ការកាសែត ។ គាត់ចេញលក់កាសែតដែលបង្កើតក្រោយនេះបានតែរយៈពេល១អាទិត្យប៉ុណ្ណោះ ខ្មែរក្រហមក៏ចូលមកកាន់កាប់ទីក្រុងភ្នំពេញ ។

នៅមុនបែកឆ្នាំ១៩៧៥ មិត្តភក្តិគាត់នៅឯប្រទេសអាមេរិកបានប្រាប់ឲ្យគាត់រត់ភៀសខ្លួនទៅដែរ ប៉ុន្តែឪពុកខ្ញុំមិនដាច់ចិត្តរត់ចេញទៅ ពីព្រោះគាត់មានកូនច្រើននៅក្នុងបន្ទុក ម្យ៉ាងទៀតគាត់

ទើបតែរៀបចំរៀបការឲ្យបងស្រីរបស់ខ្ញុំឈ្មោះ ណារី ដូច្នេះគាត់មិនដាច់ចិត្តទៅចោលទេ ។ ពេលខ្មែរក្រហមប្រកាសឲ្យប្រជាជនចេញពីទីក្រុងភ្នំពេញរយៈពេលបីថ្ងៃ ឪពុកខ្ញុំមិនជឿទេ ព្រោះគាត់ជាអ្នកកាសែតគាត់ដឹងពត៌មានច្បាស់ ។ យើងធ្វើដំណើរទៅស្រុកកំណើតនៅឯស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង ។ ពេលចេញពីផ្ទះ យើងរៀបចំរបស់របរដាក់ឡាន ប៉ុន្តែខ្មែរក្រហមនិយាយថាបើយើងជិះឡានមានន័យថា យើងជាអ្នកជិះជាន់កម្លាំងពលកម្មអ្នកដទៃ ។ ទៅដល់អ្នកលឿង យើងរុញឡានទម្លាក់ទឹក ហើយធ្វើដំណើរបន្តដោយថ្មើរជើង ។ យើងឆ្លងសាឡាង ហើយធ្វើដំណើរអស់រយៈពេល២ថ្ងៃទៀតទើបទៅដល់ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង ។ នៅតាមផ្លូវ យើងហូបរបស់របរដែលយកពីផ្ទះបានខ្លះ និងដោះដូរសម្លៀកបំពាក់ ដើម្បីយកអាហារហូប ។ លុយកាក់ដែលយើងយកទៅប្រែជាអត់ប្រយោជន៍ ព្រោះអង្គការឈប់ឲ្យចាយលុយ ។

យើងទៅដល់ភូមិកន្ទ្រាញព្រៃស្វាដែលជាស្រុកកំណើតខាងឪពុករបស់ខ្ញុំ ។ អង្គការតម្រូវឲ្យយើងសង់ខ្ទមនៅដោយខ្លួនឯង ។ អ្នកភូមិដែលធ្លាប់ស្គាល់ឪពុកខ្ញុំខ្លះបានឲ្យបុស្សីម្នាក់មួយកង់ៗដើម្បីសង់ខ្ទម ។ អង្គការបែងចែកយើងជាក្រុមៗ មានក្រុមយុវជនយុវនារី ក្រុមមនុស្សចាស់ និងក្រុមកុមារ ។ ឪពុកខ្ញុំធ្វើខ្លួនជាកសិករលាក់ឈ្មោះលាក់ប្រវត្តិ ។ ឪពុកខ្ញុំបិទទ្រូ ដាក់មង ធ្វើតុ និងធ្វើស្រែ ។ ចំណែកម្តាយរបស់ខ្ញុំមានផ្ទៃពោះជិតគ្រប់ខែ អង្គការចាត់តាំងឲ្យទៅស្ទូងស្រូវនៅឆ្ងាយពីភូមិ ។ អង្គការបែងចែកឲ្យយើងរស់នៅតាមក្រុម ហើយឲ្យហៅគ្នាថា សមមិត្តបង ឬសមមិត្តប្អូន ។ អង្គការមិនអនុញ្ញាតឲ្យយើង ហៅឈ្មោះចំៗទេ ។ យើងទៅធ្វើការជាក្រុមៗ ។ អង្គការកំណត់ឲ្យយើងស្លៀកពណ៌ខ្មៅទាំងអស់ ។ យើងយកផ្លែម្លឿទៅដាំរំងាស់ ហើយយកខោអាវពណ៌ទៅជ្រលក់ ។ អង្គការប្រមូលរបស់របរប្រើប្រាស់ទៅដាក់រួម ។ ពេលព្យុះរដូវយើងកាន់ចានទៅបើករបបអាហាររៀងៗខ្លួន ។ នៅទីនោះមានការប្រណែនគ្នារវាងប្រជាជនមូលដ្ឋាននិងប្រជាជន១៧មេសា ។ ប្រជាជនមូលដ្ឋានស្គាល់ក្រុមគ្រួសារខ្ញុំច្បាស់ ព្រោះវាជាស្រុកកំណើតឪពុករបស់ខ្ញុំ ។ ការហូបចុក គឺមិនស្មើភាពគ្នាទេ ។ មានអ្នកខ្លះចង់ឲ្យមានរបបហូបស្មើគ្នា ប៉ុន្តែមានអ្នកខ្លះមិនចង់ឲ្យមានរបបហូបចុកស្មើគ្នាទេ គឺចង់ឲ្យប្រជាជន ជម្លៀសមកពីភ្នំពេញហូបតិចជាងប្រជាជនមូលដ្ឋាន ។



ស្រេង ម៉ាប់ និងក្រុមគ្រួសារ ថតនៅឆ្នាំ១៩៦០

ម្តាយរបស់ខ្ញុំឆ្លងទន្លេនៅភូមិកន្ទ្រាញ ។




នៅសម័យនោះ គ្មានថ្នាំពេទ្យព្យាបាលត្រឹមត្រូវទេ មានតែថ្នាំអាចមន៍ទន្សាយពណ៌ខ្មៅ និងឱសថបុរាណដែលគ្មានជំនាញពិតប្រាកដ ។ ម្តាយខ្ញុំកើតបានកូនប្រុសម្នាក់រួចហើយគាត់ក៏ស្លាប់នៅពេលនោះដោយសារធ្លាក់ឈាមច្រើនពេក ។ អង្គការមិនអនុញ្ញាតឲ្យឪពុកខ្ញុំយកសាក សពរបស់ម្តាយខ្ញុំទៅធ្វើបុណ្យទេ ។ ឪពុកខ្ញុំយកសពម្តាយខ្ញុំទៅកប់នៅក្នុងព្រៃ ។ សាច់ញាតិរបស់ខ្ញុំដាក់ឈ្មោះប្អូនខ្ញុំថា "សំណាង" ។ សំណាង អត់មានទឹកដោះបៅទេ ។ ឪពុកខ្ញុំយកវាទៅសុំឲ្យអ្នកភូមិចិញ្ចឹមជំនួស ហើយឲ្យធ្វើជាកូន ។ ឪពុកម្តាយចិញ្ចឹមរបស់ សំណាង ស្រលាញ់និងចូលចិត្តវាណាស់ ហើយបីបាច់ថែរក្សាវាដូចជាកូនបង្កើត ។ នៅឆ្នាំ១៩៧៦ អង្គការបានហៅឪពុកខ្ញុំទៅជាមួយបុរសៗនៅក្នុងភូមិហើយក៏បាត់ដំណឹងរហូត ។ មុនពេលអង្គការហៅឪពុកខ្ញុំទៅ លឿត បានលួចសម្លាប់ប្រធានភូមិ ។ អង្គការបានតាមដានស្រាវជ្រាវអំពីរឿងនេះ ហើយហៅបុរសៗនៅក្នុងភូមិទៅទាំងអស់ទៅប្រជុំដើម្បីសួរចម្លើយ ។ ខ្ញុំឃើញឈ្លបជាច្រើននាក់បណ្តើរឪពុកខ្ញុំចេញទៅនៅពេលយប់ ។ ឪពុកខ្ញុំពាក់អាវផ្តួតបង់កក្រមាក្រឡាធំៗ ។ ឪពុកខ្ញុំដឹងថាគាត់ប្រាកដជាមានរឿងមិនល្អកើតឡើងចំពោះគាត់ ។ គាត់បានត្រៀមខ្លួនជាស្រេច ។ គាត់បានលាក់ទុកលុយដែលយកចេញពីភ្នំពេញទុកនៅក្នុងបំពង់ឫស្សី ហើយប្រាប់កូនៗឲ្យដឹងនិងផ្តាំផ្ញើថា បើគាត់មិនត្រឡប់មកវិញទេត្រូវនាំបងប្អូនរត់ចេញពីទីនេះ ហើយត្រូវប្រយ័ត្នប្រយែងអំពីរូបថតទាំងអស់ផង ។

ក្រោយពេលអង្គការយកឪពុកខ្ញុំទៅ អង្គការបានជម្លៀសបងប្អូនខ្ញុំទៅខេត្តបាត់ដំបងតាមរថភ្លើង ។ យើងទៅដល់ស្រុកមោងរស់នៅបែកគ្នាហើយធ្វើជាមិនស្គាល់គ្នាដើម្បីកុំឲ្យអង្គការសង្ស័យ ។ បងខ្ញុំឈ្មោះ ណារី បានយកប្អូនស្រីខ្ញុំពីរនាក់ដែលកើតនៅភ្នំពេញធ្វើជាកូន ។ គាត់រស់នៅក្នុងកងស្ត្រីមេម៉ាយ ។

ខ្ញុំយករូបថតនិងរបស់របរមានតម្លៃទុកនៅក្នុងពាង ហើយកប់ពាងនោះនៅក្នុងដី រួចហើយខ្ញុំបន្ទោរបង់នៅពីលើកន្លែងនោះ ហើយបោះចោលសំរាមលើនោះទៀត ។ ក្រោយមកទើបខ្ញុំយករូបថតទាំងនោះមកចែកបងប្អូនខ្ញុំរៀងៗខ្លួនវិញ ។ រូបថតមួយសន្លឹករបស់ឪពុកខ្ញុំគឺថតនៅពេលគាត់មានអាយុ៤០ឆ្នាំ ក្នុងពេលគាត់ឈរឈ្មោះធ្វើជាតំណាងរាស្ត្រនៅខេត្តព្រៃវែង ។

រូបថតរបស់ខ្ញុំមួយសន្លឹកនេះខ្ញុំថតនៅទីក្រុងភ្នំពេញពេលខ្ញុំមានអាយុ១២ឆ្នាំ ។ ខ្ញុំថតសម្រាប់បិទកាតសិស្សនៅឆ្នាំ១៩៧៤ ខ្ញុំក៏រៀននៅសាលាឯកជនអប្សរា ។◆◆◆

## កុក សារឿន

## អតីតទាហាន លន់ នល់




នេះគឺជារូបថតរបស់ កុក សារឿន ដែលថតនៅក្នុងទសវត្សរ៍៦០ ។ រូបនេះ សារឿន ថតនៅអាយុ២៨ឆ្នាំ ដើម្បីយកទៅបិទកាតនៅពេលគាត់បានឡើងបុណ្យស័ក្តិក្នុងជួរទាហាន ។ សារឿន ចូលចិត្តឯកសណ្ឋាននៅក្នុងរូបថតនេះណាស់ ។ នៅក្នុងរបបខ្មែរក្រហមម្តាយរបស់ សារឿន លាក់រូបថតនេះនៅក្នុងប្រអប់ស្លាម្លូនៅផ្ទះរបស់គាត់នៅខេត្តតាកែវ ។ សារឿន បានរៀបរាប់ថា ÷

ពីដើម ខ្ញុំរៀននៅសាលាវត្តនាងខ្មៅ ស្ថិតនៅក្នុងឃុំរវៀង ស្រុកសំរោង ខេត្តតាកែវ ។ នៅឆ្នាំ១៩៥៦ ក្រោយពេលប្រឡងសីទីហ្វិកាជាប់ ខ្ញុំទៅរៀននៅសាលាត្រាំខ្នារ ។ បន្ទាប់មកខ្ញុំទៅបន្តការសិក្សានៅសាលាកម្ពុជបុត្រនៅទីក្រុងភ្នំពេញ ។ ពេលរៀនចប់ខ្ញុំប្រឡងចូលធ្វើក្រឡាបញ្ជី ព្រោះខ្ញុំស្រលាញ់ការងារនេះ ប៉ុន្តែខ្ញុំប្រឡងធ្លាក់ ខ្ញុំក៏ដាក់ពាក្យចូលធ្វើប៉ូលិស ។ ខ្ញុំត្រូវបានចាត់តាំងឲ្យទៅរៀនច្បាប់ប៉ូលិសនៅខេត្តកំពង់ឆ្នាំង ។ នៅទីនោះ ខ្ញុំរៀនច្បាប់ចរាចរណ៍ ច្បាប់ព្រហ្មទណ្ឌ ច្បាប់ទូទៅ និងរៀនក្បួនយុទ្ធសាស្ត្រប្រយុទ្ធ ។ ខ្ញុំរៀននៅរយៈពេល១ឆ្នាំ៨ខែ ។ ក្រោយពេលរៀនចប់ ខ្ញុំទៅធ្វើការនៅខេត្តកំពតផ្នែកខាងព្រហ្មទណ្ឌ ។ ខ្ញុំធ្វើនៅខេត្តកំពតបានតែមួយឆ្នាំ ក៏ផ្លាស់ទៅធ្វើការនៅខេត្តកោះកុង ។

ពេលខ្ញុំត្រឡប់ទៅលេងស្រុកកំណើតរបស់ខ្ញុំនៅស្រុកព្រៃកប្បាស ខ្ញុំដើរមើលនារីៗនៅតាមផ្ទះ ។ ខ្ញុំដើរមើលអស់ជាច្រើនផ្ទះ ប៉ុន្តែខ្ញុំមិនត្រូវចិត្ត ។ ផ្ទះខ្លះចង់លើកកូនក្រមុំឲ្យខ្ញុំ ហើយថែមទាំងទិញម៉ូតូឲ្យមួយទៀត ។ ខ្ញុំបានទៅដល់ផ្ទះលោកគ្រូខាន់ ឃើញ

កូនក្រមុំគាត់កំពុងស្បាញហូលជាមួងនៅក្រោមផ្ទះ ។ ខ្ញុំឡើងទៅអង្គុយនៅលើផ្ទះមួយសន្ទុះខ្ញុំចុះមកវិញ ហើយលោកគ្រូខាន់នាំខ្ញុំទៅមើលកូនក្រមុំផ្ទះផ្សេងៗទៀតរហូតដល់ល្ងាច ។ ខ្ញុំហូបបាយល្ងាចនៅផ្ទះលោកគ្រូខាន់ ។ ក្រោយពេលហូបបាយរួច លោកគ្រូខាន់ បបួលខ្ញុំទៅមើលផ្ទះផ្សេងទៀត ។ ខ្ញុំនិយាយថា ខ្ញុំមិនចង់ទៅទៀតទេ ខ្ញុំចង់នៅសម្រាកផ្ទះនេះហើយ ។

លោកគ្រូខាន់ បានគិតគូរមើលថ្ងៃខែរៀបការខ្ញុំនិងកូនស្រីរបស់គាត់ ។ ហោរាទាយថា យើងទាំងពីរនាក់បើរៀបការជាមួយគ្នា ទៅថ្ងៃមុខអាចមានទ្រព្យសម្បត្តិមធ្យម ហើយអត់មានការលែងលះគ្នាទេ ប៉ុន្តែខ្ញុំនឹងមានប្រពន្ធមួយទៀត ។ ខ្ញុំបាននាំឪពុកម្តាយខ្ញុំទៅមើលអនាគតប្រពន្ធខ្ញុំ ។ គាត់ទាំងពីរនាក់ក៏ពេញចិត្តដូចខ្ញុំដែរ ។ ពិធីរៀបការរបស់យើងធ្វើឡើងក្នុងរយៈពេល៣ថ្ងៃ ។ ក្រោយពេលរៀបការហើយមានអ្នកខ្លះលេបខាយឲ្យខ្ញុំថា បើសិនជាខ្ញុំរៀបការជាមួយកូនគាត់វិញ គាត់និងទិញម៉ូតូវេស្ប៉ាឲ្យខ្ញុំមួយ ។ ខ្ញុំរៀបការជាមួយប្រពន្ធខ្ញុំដោយក្តីស្រលាញ់ ហើយខ្ញុំចេញថ្លៃការដោយខ្លួនខ្ញុំទៀតផង ។ នៅពេលរៀបការខ្ញុំមិនបានថតរូបទេ ព្រោះកាលណោះគ្មានជាងថតរូបទេ ។ ក្រោយពេលរៀបការហើយ ខ្ញុំបាននាំប្រពន្ធរបស់ខ្ញុំទៅរស់នៅខេត្តកោះកុងជាមួយគ្នា ។

ក្រោយមក ខ្ញុំត្រូវផ្លាស់ទៅធ្វើការនៅផ្នែកពេទ្យ ។ រយៈពេលដែលខ្ញុំធ្វើការនៅខេត្តកោះកុង ខ្ញុំទទួលបានប្រាក់បៀវត្សរ៍ច្រើនជាងនៅទីកន្លែងផ្សេងៗ ព្រោះកន្លែងនោះគឺជាតំបន់ដែលសម្បូរទៅដោយជំងឺគ្រុនចាញ់ ។ នៅឆ្នាំ១៩៦៤ ខ្ញុំផ្លាស់ពីខេត្តកោះកុងទៅខេត្តតាកែវ ហើយដល់ឆ្នាំ១៩៧០ ខ្ញុំផ្លាស់ទៅធ្វើការនៅតាខ្មៅ ។ ក្រោយមកខ្ញុំត្រូវចាត់តាំងទៅរៀនផ្នែកយុទ្ធសាស្ត្រទាហាននៅប្រទេសវៀតណាមអស់រយៈពេល៨ខែ ។ កាលណោះខ្ញុំពាក់ស័ក្តិ៣ ។ ពេលខ្ញុំមកវិញ ខ្ញុំប្រចាំការនៅតាខ្មៅដែលជាទីតាំងការពារខ្សែក្រវាត់ក្រុង ។ ខ្ញុំនៅផ្នែកខាងភ័ស្តុភារ ។

ខ្ញុំបានចេញច្បាំងនៅសមរភូមិសិត្បូ ។ ពេលនោះខ្ញុំបែកពីកូនទាហាន ហើយសន្លប់អស់២យប់២ថ្ងៃទើបដឹងខ្លួនមកវិញ ។ កូនទាហានរបស់ខ្ញុំស្មានតែខ្ញុំស្លាប់នៅក្នុងសមរភូមិ ប៉ុន្តែខ្ញុំត្រឡប់ទៅបន្ទាយវិញដោយសុវត្ថិភាព ។ នៅពេលដែលខ្ញុំបោះទីតាំងធ្វើការនៅកន្លែងណាមួយ ខ្ញុំណែនាំសមាជិកខ្ញុំឲ្យយកចិត្តទុកដាក់ជួយដល់ប្រជាជន និងមិនត្រូវលួចរបស់ទ្រព្យប្រជាជនទេ ។

ខ្ញុំចំណាយលុយអស់៣០ម៉ឺនរៀលដើម្បីសុំប្តូរការងារមកធ្វើនៅបន្ទាយទាហានពិការ ។ ខ្ញុំឈប់ចេញច្បាំងដូចមុនទៀតហើយ ។ ខ្ញុំធ្វើការនៅទីនោះរហូតដល់បែកទីក្រុងភ្នំពេញ ។

នៅថ្ងៃជម្លៀស ខ្មែរក្រហមបានប្រកាសថាឲ្យចេញពីទីក្រុងភ្នំពេញឲ្យអស់យ៉ាងយូរ១អាទិត្យនឹងឲ្យវិលត្រឡប់មកវិញ ។ ខ្មែរក្រហមបានឃោសនាថា ប្រជាជនត្រូវចេញពីទីក្រុងដើម្បីបោសសម្អាតខ្មាំង ។ ខ្ញុំលាក់ខោអាវទាហាននិងកាំភ្លើងហើយខ្ញុំស្លៀកសម្លៀកបំពាក់ស៊ីវិលធ្វើដំណើរចេញពីផ្ទះ ។ ខ្ញុំយករបស់របរចេញពីផ្ទះបានតែបន្តិចបន្តួចទេ ព្រោះខ្មែរក្រហមប្រាប់ថាទៅទីនោះអង្គការមានរបស់របរឲ្យប្រើប្រាស់និងមានអាហារសម្រាប់ហូបចុកហើយ ។ យើងមានតែកង់មួយសម្រាប់ដឹកឥវ៉ាន់ ។ ខ្មែរក្រហមឲ្យយើងទៅត្រឹមក្បាលថ្នល់សិន ប៉ុន្តែពេលដែលខ្ញុំទៅដល់ទីនោះ ខ្មែរក្រហមដេញបន្តទៀតទៅដល់តាខ្មៅ ។ ខ្មែរក្រហមចេះតែដេញបន្តបន្ទាប់ទៀត ខ្ញុំចំណាយពេលអស់កន្លះខែធ្វើដំណើរទៅដល់ស្រុកកំណើត ។

នៅទីនោះខ្ញុំអង្គការឲ្យយើងស្នាក់នៅជាមួយឪពុកម្តាយរបស់ខ្ញុំ ។ ឪពុកម្តាយនិងសាច់ញាតិរបស់ខ្ញុំគឺជាអ្នកមូលដ្ឋាន ហើយប្រជាជននៅទីនោះស្គាល់ខ្ញុំច្បាស់ថាខ្ញុំអតីតជាទាហានលន់ នល់ ។ កាលខ្ញុំនៅធ្វើការនៅក្នុងរបបលន់នល់ ខ្ញុំធ្លាប់បានជួយអ្នកទាំងនោះជាច្រើនដងដូចជា ពេលដែលកងទ័ពទាំងនោះឡើងមកទិញថ្នាំនៅតាខ្មៅ ហើយត្រូវទាហានលន់នល់ចាប់បានខ្ញុំបានជួយដោះលែង និងជួយទិញថ្នាំឲ្យទៀត ។ កងទ័ពទាំងនោះចាត់ទុកថាខ្ញុំជាមនុស្សមានស្នាដៃល្អទើបប្រគល់កាតមួយឲ្យខ្ញុំ ។ ពេលដែលខ្ញុំមានកាតនេះ ទោះទៅទីណាក៏មានអ្នកជួយដែរ ។ ហើយកងទ័ពខ្មែរក្រហមទទួលស្គាល់កាតនេះគ្រប់ៗគ្នា ។ ខ្ញុំប្រគល់កាតនោះឲ្យទៅអ្នកគ្រប់គ្រងនៅទីនោះ ។

ទៅដល់ទីនោះដំបូងខ្ញុំមានអាហារហូបចុកគ្រប់គ្រាន់ ។ គណៈគ្រប់គ្រងចិត្តល្អជាមួយខ្ញុំ និងក្រុមគ្រួសារខ្ញុំណាស់ ។ គាត់ប្រាប់សមាជិករបស់គាត់ឲ្យយកចិត្តទុកដាក់ចំពោះខ្ញុំ ។ ពេលនោះខ្ញុំឃើញមនុស្សបាត់ពីភូមិស្ទើរតែរាល់ថ្ងៃជាពិសេសអ្នកជម្លៀស ។

នៅស្រុកកំណើតរបស់ខ្ញុំ អង្គការអត់មានសួរនាំអំពីប្រវត្តិរូបរបស់ខ្ញុំទេ ព្រោះគណៈគ្រប់គ្រងនៅទីនោះស្គាល់ខ្ញុំទាំងអស់គ្នា ។ ចំណែកអ្នកផ្សេងដែលជម្លៀសទៅពីទីក្រុងនិងទៅពីកន្លែងផ្សេងៗ ខ្មែរក្រហមសួរប្រវត្តិរូបទាំងអស់ ។ អង្គការចាត់តាំងឲ្យខ្ញុំលើកទំនប់និងជីកប្រឡាយ ។

ក្រោយមក អង្គការយកខ្ញុំទៅដាក់នៅគុកវត្តអង្គចង្អេរ ស្រុកសំរោង ។ ខ្ញុំជាប់គុកដោយសារខ្ញុំជាប់និន្នាការធ្វើទាហានលន់នល់ ។ គី ដែលជាអ្នកធ្វើការនៅក្នុងគុកបានប្រាប់ខ្ញុំថា មិនត្រូវនិយាយអ្វីផ្តេសផ្តាសទេប្រយ័ត្នស្លាប់ ។ នៅក្នុងបន្ទប់គុកមានពាងមួយសម្រាប់ឲ្យយើងបន្ទោរបង់ ។ ខ្ញុំគ្មានអ្វីក្រាលដេកទេ គឺមានតែស្លឹកត្នោតដែលមាននៅក្នុងនោះស្រាប់ ។ ព្រលឹមឡើងម៉ោង៤កន្លះ កងទ័ពបណ្តើរអ្នកទោសចេញពីគុកទៅធ្វើការ ។ ម៉ោង១១យើងសម្រាកហូបអាហារថ្ងៃត្រង់ ។ យើងធ្វើការរហូតដល់ពេលល្ងាចទាហានបណ្តើរយើងចូលក្នុងគុកវិញ ។ ៣ថ្ងៃក្រោយគណៈឃុំបានដោះលែងឲ្យខ្ញុំនៅក្រោមបន្ទប់ឃុំឃាំង ។ ខ្ញុំដេកនៅមាត់ទ្វារគុក ។ អង្គការចាត់តាំងខ្ញុំឲ្យយកបាយម្ហូបឲ្យអ្នកទោសពីសហករណ៍មួយទៅសហករណ៍មួយទៀត ។

ពេលអង្គការចាប់ខ្ញុំដាក់គុក សាច់ញាតិខ្ញុំដែលជាអ្នកមូលដ្ឋានត្រូវរស់នៅដោយការខ្វះខាតអាហារនិងធ្វើការលំបាកវេទនា ។ បងខ្ញុំម្នាក់និងម្តាយខ្ញុំស្លាប់ដោយសារការអត់អាហារ ។ ពេលអ្នកទាំងពីរស្លាប់ខ្ញុំកំពុងតែនៅក្នុងគុក ។ ខ្ញុំបានសុំការអនុញ្ញាតទៅមើលគាត់រយៈពេល១អាទិត្យចុងក្រោយ ហើយយកសាកសពគាត់ទៅកប់ ។

៣ខែក្រោយមក អង្គការបានបញ្ជូនប្រពន្ធនិងកូនខ្ញុំមករស់នៅសហករណ៍ក្នុងគុកជាមួយខ្ញុំដែរ ។ អង្គការចាត់តាំងឲ្យខ្ញុំធ្វើជាប្រធានក្រុម ហើយឲ្យខ្ញុំទៅស្វែងរកអាហារសម្រាប់សហករណ៍ ។ កេត ក៏ជាប្រធានក្រុមដែរ ប៉ុន្តែវាធ្វើការងារមិនបានល្អ ។ វាប្តឹងទៅថ្នាក់លើថាខ្ញុំធ្វើការងារមិនបានល្អ ។ អង្គការស៊ើបទៅឃើញថាខ្ញុំមិនបានធ្វើអ្វីខុសទេ ក៏ឲ្យខ្ញុំរួចពីការចោទប្រកាន់នេះ ។

ពេលបែកឆ្នាំ១៩៧៩ ខ្ញុំយកអង្ករបានខ្លះពីផ្ទះម្តាយរបស់ខ្ញុំ លុយដុល្លារដែលខ្ញុំខំលាក់តាំងពីភ្នំពេញមក និងសម្លៀកបំពាក់ដាក់ក្នុងរទេះធ្វើដំណើរមកទីក្រុងភ្នំពេញ ។ នៅតាមផ្លូវពីតាកែវមកភ្នំពេញ ខ្មែរក្រហមដេញបាញ់ខ្ញុំរត់ចោលរទេះដឹកអីវ៉ាន់យករួចតែខ្លួន ។

ខ្ញុំបានឃើញរូបថតនេះឡើងវិញនៅពេលដែលខ្ញុំចេញពីគុក ។ ទៅផ្ទះម្តាយរបស់ខ្ញុំ ហើយយករូបថតនោះមកវិញ ។ ពេលដែលខ្ញុំឃើញរូបថតនេះម្តងៗ ខ្ញុំឆ្អែតឆ្អន់និងការងារដែលធ្វើពីមុនមក ។ មកដល់បច្ចុប្បន្ននេះ ខ្ញុំក៏មិនឲ្យកូនៗរបស់ខ្ញុំធ្វើប៉េអឹម ឬធ្វើប៉ូលិសទេដែរ ។ ខ្ញុំរាងហើយ ។◆◆◆

**ឌឹុង ឌន**

## អតីតទាហាន លន់ នល់


សូ រី ក្នុងរបបលន់នល់

សូ រី បានរក្សាទុកនូវរូបថតចំនួន ២សន្លឹក មួយសន្លឹកជារូបរបស់គាត់ និងមួយសន្លឹកទៀតគឺជារូបប្តីរបស់គាត់ដែលថតនៅក្នុងរបបលន់នល់ ។ កាលណោះ គាត់ទាំងពីរនាក់ថតដើម្បីយកទៅបិទលើបញ្ជីដំឡើងប្រាក់ខែ ។ រូបថតទាំងពីរសន្លឹកនេះថតនៅក្រោយពេលរៀបការរួចរយៈពេល១ខែ ។ គាត់ថតនៅហាងមួយនៅខាងលិចផ្សារទ្វីមខេត្តតាកែវ ។ នៅពេលខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ រី បានរក្សាទុករូបថតនេះនៅក្នុងកូនកាបូបដៃ ហើយលាក់ទុកជាប់នឹងខ្លួនរបស់គាត់ ។ ចំណែកឯកសារផ្សេងៗដែលជាប់ពាក់ព័ន្ធនិងប្តីរបស់គាត់ គាត់បានដុតចោលនៅតាមផ្លូវ ។ ពាក់ព័ន្ធនិងបញ្ហារូបថត សូ រី បានរៀបរាប់ថា ÷

ប្តីរបស់ខ្ញុំគឺជាអ្នកស្រុកភូមិជាមួយខ្ញុំ ។ គាត់មានសម្បុរសណ្តែកបាយ និងមានចរិតស្លូតបូតនិងឧស្សាហ៍ព្យាយាម ។ គាត់ខ្ពស់ជាមនុស្សនិយាយច្រើន ទោះទៅទីណាក៏មានមនុស្សចូលចិត្តគាត់ដែរ ។ រៀនបានថ្នាក់ឌីប្លូមពីដើម ។ ឪពុកម្តាយរបស់គាត់ចូលស្តីដណ្តឹងខ្ញុំ៣ដងទើបខ្ញុំយល់ព្រមរៀបការជាមួយគាត់ ។ លើកទី១និងលើកទី២ខ្ញុំប្រកែក ពីព្រោះខ្ញុំទើបតែមានអាយុ១៦ឆ្នាំប៉ុណ្ណោះ ។ ក្រោយមក ដោយសារញាតិមិត្តបងប្អូនរបស់ខ្ញុំពេញចិត្តគាត់ហើយបញ្ចុះបញ្ចូលខ្ញុំថា បើខ្ញុំទទួលយកគាត់គឺមិនខុសទេ ព្រោះគាត់ជាមនុស្សល្អ ។ ខ្ញុំក៏យល់ព្រមរៀបការជាមួយគាត់ ។

ពិធីរៀបការរបស់យើងប្រារព្ធធ្វើឡើងអស់រយៈពេល២យប់២ថ្ងៃ ។ សម្លៀកបំពាក់ដែលខ្ញុំស្លៀកក្នុងពិធីរៀបការគឺ មានតែ២កំប្លេប៉ុណ្ណោះ ។ ក្នុងថ្ងៃនោះខ្ញុំបួងសក់ឡើងលើ ខ្ញុំទៅធ្វើសក់នៅផ្សារតាកែវ ។

ក្រោយពេលរៀបការហើយប្រហែលជា១ខែ អាជ្ញាធរភូមិឃុំបានមកឃោសនាឲ្យប្តីខ្ញុំចូលបម្រើក្នុងជួរទាហានលន់នល់ ។ ប្តីខ្ញុំមិនចង់ចូលទេ ប៉ុន្តែគាត់ចូលដោយបង្ខំចិត្ត ។ ប្តីរបស់ខ្ញុំមិនសូវបាននៅផ្ទះទេ ពេលខ្លះខ្ញុំយកបាយម្ហូបទៅឲ្យគាត់នៅឯបន្ទាយ ។ គាត់ចូលច្បាំងនៅសមរភូមិជាច្រើនដូចជា ដីឥដ្ឋ តាកែវ និងទីក្រុងភ្នំពេញ ។

នៅឆ្នាំ១៩៧៤ ក្រុមគ្រួសារខ្ញុំបានប្តូរទៅរស់នៅទីរួមខេត្តតាកែវ ពីព្រោះភូមិរបស់ខ្ញុំមានគ្រាប់ផ្លោងចូលច្រើននិងមានចម្បាំងរវាងកងទ័ពរំដោះជាមួយទាហានលន់នល់ ។ យើងធ្វើកូនខ្ទមទាបផ្ទាល់ដីដើម្បីស្នាក់នៅជាបណ្តោះអាសន្ន ។ យើងស្តាយស្រូវដែលយើងខំដាំណាស់ ។ យើងប្រថុយគ្រោះថ្នាក់ដើម្បីទៅច្រូតស្រូវបានខ្លះយកមកបែនទុកហូប ។ ពេលខ្លះគ្រាប់ផ្លោងធ្លាក់មកត្រូវរបស់របរដែលនៅក្រៅផ្ទះ ប៉ុន្តែអត់មានគ្រោះថ្នាក់ដល់អាយុជីវិតមនុស្សទេ ។


សី រី ក្នុងរបបលន់នល់

នៅដើមឆ្នាំ១៩៧៥ ប្តីរបស់ខ្ញុំត្រូវបានចាត់តាំងឲ្យទៅច្បាំងនៅសមរភូមិត្រពាំងព្រាយនៅជាយក្រុងភ្នំពេញ ។ ពេលនោះ គាត់ត្រូវរបួសបាក់ភ្លៅមួយចំហៀង ។ អ្នករួមការងារជាមួយគាត់បានប្រាប់ដំណឹងនេះដល់ខ្ញុំ ហើយខ្ញុំជិះឡានទូម្ភាគចក្រទៅទីក្រុងភ្នំពេញដើម្បីមើលថែប្តីរបស់ខ្ញុំ ។ ពេលនោះខ្ញុំមានផ្ទៃពោះជិតគ្រប់ខែហើយ ។ ប្តីរបស់ខ្ញុំសម្រាកព្យាបាលនៅមន្ទីរពេទ្យធំ ។ ពេលខ្ញុំទៅឃើញសភាពជំងឺរបស់គាត់ ខ្ញុំមិនអាចទប់ទឹកភ្នែកបានទេ ។ ជើងរបស់គាត់ហូរឈាម រលួយស្អុយ និងមានដង្កូវ ។ ខ្ញុំដឹងថាគាត់ឈឺខ្លាំងណាស់ ។ ពេទ្យបានតជើងឲ្យគាត់ ប៉ុន្តែគាត់មិនទាន់អាចដើរបាន នៅឡើយទេ ។

ពេលដែលកងទ័ពខ្មែរក្រហមជម្លៀសប្រជាជនឲ្យចេញពីទីក្រុង ខ្ញុំបានប្រកែកមិនព្រមចេញ ព្រោះប្តីរបស់ខ្ញុំមិនទាន់ជាសះស្បើយនៅឡើយ ប៉ុន្តែកងទ័ពទាំងនោះមិនអនុញ្ញាត ។ យើងចង់ធ្វើដំណើរទៅស្រុកកំណើតរបស់យើងវិញនៅឯខេត្តតាកែវ អង្គការដាក់ទិសឲ្យយើងធ្វើដំណើរទៅតាមផ្លូវជាតិលេខ៥ ។ ខ្ញុំដាក់ប្តីខ្ញុំលើរទេះរុញ ហើយយកក្រមាចងទប់គាត់ ។ ពោះរបស់ខ្ញុំកាន់តែធំទៅៗពិបាកធ្វើដំណើរណាស់ ។

ខ្ញុំយកបានតែចានឆ្នាំងនិងអង្ករបន្តិចបន្តួចប៉ុណ្ណោះសម្រាប់ដាំបាយហូបតាមផ្លូវ ។ ខ្ញុំយកឯកសណ្ឋានទាហានរបស់ប្តីខ្ញុំ និងឯកសារដែលពាក់ព័ន្ធទៅកប់ចោលនៅតាមផ្លូវ ។ នៅតាមផ្លូវអង្គការបានសួរប្រវត្តិរូបយើងជាហូរហែ ។ ខ្ញុំឆ្លើយប្រាប់ថា ប្តីរបស់ខ្ញុំជាអ្នកអូសទឹកលក់ចំណែកខ្ញុំនៅផ្ទះ ។ ខ្ញុំនៅតែរក្សាចម្លើយដដែលៗគ្រប់ពេលដែលអង្គការសួរ ។ នៅតាមផ្លូវអង្គការបានប្រកាសថា អ្នកណាធ្វើការងារអ្វីឲ្យទៅធ្វើការងារតាមមុខតំណែងចាស់វិញ ហើយមានឡានចាំដឹកចេញទៅ ។ អង្គការមិនជឿថា ប្តីខ្ញុំជាអ្នកអូសទឹកលក់ទេ ព្រោះឃើញប្តីខ្ញុំបាក់ជើងមួយចំហៀង ។ អង្គការចាប់ប្តីខ្ញុំដាក់ឡាន ។ ប្តីខ្ញុំផ្តាំខ្ញុំថាពេលគាត់ទៅបាត់សូមឲ្យខ្ញុំសរសេរសំបុត្រស្វែងរកគាត់ផង ។ ខ្ញុំចេះតែស៊ើបសួរដំណឹងពីប្តីរបស់ខ្ញុំជាហូរហែនៅតាមផ្លូវ ប៉ុន្តែមិនបានទទួលដំណឹងអ្វីសោះពីគាត់ ។ ខ្ញុំយល់ថា ប្តីរបស់ខ្ញុំត្រូវអង្គការយកទៅសម្លាប់ហើយ ព្រោះគាត់ជាអតីតទាហានលន់នល់ ។

ខ្ញុំធ្វើដំណើរបន្តទៅដល់ភូមិចំបក់ស្រុកចម្ការលើខេត្តកំពង់ចាម ។ អង្គការឲ្យខ្ញុំរស់នៅខ្ទមតូចមួយប្រជាជន ។ នៅទីនោះអ្នកខ្លះធ្វើល្អជាមួយខ្ញុំ អ្នកខ្លះទៀតចិត្តអាក្រក់ជាមួយខ្ញុំ ដោយនិយាយមិនល្អពីខ្ញុំ ជាពិសេសប្រជាជនមូលដ្ឋានដៀមដាមឲ្យខ្ញុំថា ទុកនៅធ្វើអ្វីយកទៅសម្លាប់ចោលទៅ ។ ខ្ញុំទៅដល់ទីនោះបានប្រហែលជាកន្លះខែខ្ញុំឈឺពោះឆ្លងទន្លេ ។ នៅទីនោះគ្មានពេទ្យឆ្មបទេ ខ្ញុំបង្កើតកូនដោយខ្លួនឯង ។ ខ្ញុំយំ ខ្ញុំមិនចេះបង្កើតកូនដោយខ្លួនឯងទេ ម្យ៉ាងទៀតខ្ញុំគ្មានសាច់ញាតិ ហើយគ្មានប្តីនៅក្បែរទៀត ។ អ្នកជិតខាងម្នាក់ដែលជាប្រជាជនជម្លៀសដូចគ្នា បានជួយបង្កើតកូនឲ្យខ្ញុំ ហើយកូនខ្ញុំកើតបញ្ច្រាសជើងទៀត ។ ខ្ញុំពិបាកវេទនាណាស់ ទម្រាំតែបង្កើតកូននេះបាន ។ ខ្ញុំដាក់ឈ្មោះកូនស្រីរបស់ខ្ញុំថា ចំបក់

ព្រោះភូមិនេះឈ្មោះភូមិចំបក់ ។ អ្នកភូមិនិយាយថាដាក់ឈ្មោះនេះឲ្យដើម្បីកុំឲ្យភ្លេចទឹកន្លែងកំណើតវា ។ ពេលកូនខ្ញុំកើតហើយ ខ្ញុំមានតែបបររាវហូបជាមួយអំបិល និងពេលខ្លះខ្ញុំហូបបបរជាមួយកូនត្រីចង្វា ។

ខ្ញុំឆ្លងទន្លេបានកន្លះខែ អង្គការចាត់តាំងខ្ញុំឲ្យទៅធ្វើការទាំងខ្ញុំនៅសសៃខ្ចី ។ ដោយសារខ្ញុំឃ្លានពេក ហើយត្រូវការទឹកដោះឲ្យកូនខ្ញុំបៅ ខ្ញុំបានស្លធាងត្រាវហូប ។ ក្រោយពេលហូបហើយ ខ្ញុំទាស់ស្ទើរស្លាប់ស្ទើររស់អស់រយៈពេលយូរថ្ងៃ ។ អ្នកនៅជិតខាងបានជួយយកអាសារខ្ញុំ ដោយរកថ្នាំឫសឈើមកដាំឲ្យខ្ញុំផឹក ទើបខ្ញុំបានធូរស្បើយ ។ អង្គការចោទប្រកាន់ខ្ញុំថាឈឺសតិអារម្មណ៍ ហើយប្រើឲ្យខ្ញុំធ្វើការងារទាំងឈឺ ។ ពេលខ្ញុំទៅធ្វើការខ្ញុំយកកូនខ្ញុំទៅដែរ ដោយចងអង្រឹងឲ្យដេកនៅកន្លែងធ្វើការ ហើយខ្ញុំចេះតែឆ្លៀតពេលមើលវាផងនិងធ្វើការងារផង ។ ពេលកូនខ្ញុំអាយុ៩ខែវាឈឺ ហើយគ្មានពេទ្យព្យាបាលទេ ។ អ្នកជិតខាងប្រាំខ្ញុំឲ្យរកឫសឈើមកដាំឲ្យវាផឹក ប៉ុន្តែនៅតែមិនជាហើយគ្រុនញាក់រីងថ្កាមរហូតដល់ស្លាប់ ។ ខ្ញុំសុំយកសាកសពកូនពីអង្គការដើម្បីយកទៅកប់ដោយខ្លួនឯង ប៉ុន្តែអង្គការមិនអនុញ្ញាតទេ ហើយយកកូនខ្ញុំទៅបោះចោលនៅក្នុងទឹក ។ ខ្ញុំលួចយំស្ងាត់ៗមិនហ៊ានឲ្យអ្នកណាឮទេ ។ បើអង្គការដឹងថាខ្ញុំយំ ខ្ញុំពិតជាត្រូវស្លាប់ហើយ ។ ចាប់តាំងពីពេលនោះមក ខ្ញុំគ្មានសល់អ្វីទៀតទេ ខ្ញុំបាត់បង់ប្តីបាត់បង់កូនជាទីស្រលាញ់ ខ្ញុំរស់នៅតែម្នាក់ឯង ។

ក្រោយពេលកូនខ្ញុំស្លាប់ អង្គការចាត់តាំងឲ្យខ្ញុំរវៃអំបោះ ។ ខ្ញុំធ្វើការស្ទើរតែគ្មានពេលសម្រាក ចំណែកឯការហូបចុកវិញ គឺហូបតែបបររាវជាមួយសម្លម្ជូរព្រលឹតដែលមានទឹកខ្មៅក្រខ្វក់ ។ ខ្ញុំកម្របានបាយហូបណាស់ ។ ខ្ញុំបានហូបបាយតែពេលរដូវស្រូវទុំប៉ុណ្ណោះ ហើយបានហូបតែកន្លះខែទៀត ។ នៅថ្ងៃភ្ជុំបិណ្ឌខ្ញុំមាននំអន្សមហូប ចំណែកឯថ្ងៃចូលឆ្នាំ ខ្ញុំមាននំច័ក្កច័នហូប ។ យើងមិនអាចទៅវត្ត ឬធ្វើពិធីបុណ្យទានបានទេ ពីព្រោះវិហារត្រូវបានខ្មែរក្រហមបំផ្លាញចោលអស់ហើយ ។

ខ្ញុំប្តូរការងារជាច្រើនផ្នែក ។ ខ្ញុំត្រូវអង្គការផ្លាស់ឲ្យច្រូតស្រូវនិងរែកដី ។ នៅទីនោះក្នុងរយៈពេល១ខែ ខ្ញុំចូលរួមប្រជុំម្តងដែលអង្គប្រជុំបានជំរុញអំពីការប្រឹងប្រែងធ្វើការងារ ។ ពេលខ្ញុំទៅធ្វើការនៅការដ្ឋាន ឈ្លបទៅឆែកឆេរនៅផ្ទះខ្ញុំជាច្រើនដង ប៉ុន្តែរកមិនឃើញរបស់របរអ្វីទេ ។ ខ្ញុំលាក់រូបថតនៅក្នុងថង់ប្លាស្ទិក ហើយទុកនៅក្នុងហោប៉ៅ អង្គការសួរនាំអំពីប្តីរបស់ខ្ញុំដែរ ខ្ញុំប្រាប់ថាប្តីខ្ញុំជាអ្នកអូសទឹកលក់ ហើយត្រូវខ្មែរក្រហមយកទៅសម្លាប់ហើយ ។ ចាប់ពីពេលនោះមក មិនដែលមានអ្នកណាមកសួរនាំខ្ញុំទៀតទេ ។

នៅពេលវៀតណាមវាយរំដោះ សភាពការណ៍ច្របូកច្របល់ណាស់ ។ ខ្ញុំទៅលួចកើបស្រូវដែលទើបតែច្រូតហើយយកមកលាក់ទុកនៅផ្ទះ ហើយកិននឹងត្បាល់ដៃទៅជាអង្ករ ។ ខ្ញុំបានយកអង្ករនោះមួយតៅទៅឲ្យអ្នកចែវទូកជ ដើម្បីឲ្យគាត់ជូនខ្ញុំពីស្រុកចម្ការលើមកទីក្រុងភ្នំពេញវិញ ។ ទូកបានមកដល់ទន្លេបួនមុខរលកកាន់តែខ្លាំង បោកទឹកចូលព្រៀបពេញទូក ។ មនុស្សម្នានៅលើទូកភ័យជ្រួលច្របល់ ប៉ុន្តែទូកអត់លិចទេ ហើយអែបច្រាំងនៅជ្រោយចង្វារ ។ ខ្ញុំបានយករបស់របរដែលនៅជាប់ខ្លួនបន្តិចបន្តួចធ្វើដំណើរចូលទីក្រុងភ្នំពេញ ។ ខ្ញុំឃើញផ្ទះថ្មមានសុទ្ធតែលាមក ។ ខ្ញុំបន្តដំណើរទៅពោធិចិនតុង ហើយរស់នៅនិងធ្វើស្រែនៅទីនោះអស់រយៈពេលមួយឆ្នាំទើបបានជួបម្តាយខ្ញុំដែលតាមរកខ្ញុំរហូតដល់ពោធិចិនតុង ។ រយៈពេលដែលខ្ញុំនៅទីក្រុងភ្នំពេញខ្ញុំស៊ើបសួរដំណឹងអំពីប្តីរបស់ខ្ញុំដែរ ប៉ុន្តែខ្ញុំមិនបានទទួលដំណឹងអ្វីទាំងអស់ ។ ខ្ញុំត្រឡប់ទៅស្រុកកំណើតជាមួយម្តាយខ្ញុំវិញ ។ ផ្ទះរបស់ខ្ញុំនៅខេត្តតាកែវត្រូវខ្ទេចខ្ទីដោយសារគ្រាប់កាំភ្លើង ។

ពេលមកដល់ផ្ទះវិញ ម្តាយរបស់ខ្ញុំប្រាប់ថា ឪពុកខ្ញុំត្រូវអង្គការយកទៅសម្លាប់ហើយ ដោយសារគាត់ប្រកែកមិនព្រមឲ្យប្អូនស្រីខ្ញុំរៀបការតាមការស្នើសុំរបស់អង្គការ ។ ម្តាយរបស់ខ្ញុំនិយាយថា ឈ្លបបានបណ្តើរឪពុកខ្ញុំចេញពីភូមិឆ្ពោះទៅអង្គតាសោម ហើយក៏បាត់ដំណឹងរហូត ។ ២ថ្ងៃក្រោយមក ប្អូនរបស់ខ្ញុំត្រូវឈ្លបហៅទៅបាត់ដែរ ។

រហូតមកដល់បច្ចុប្បន្ននេះ ខ្ញុំគិតថាប្តីខ្ញុំស្លាប់ហើយ ខ្ញុំគ្មានសង្ឃឹមថាគាត់នៅរស់ទេ ។ បើគាត់នៅរស់ គាត់ពិតជាមករកខ្ញុំហើយ ។ ពេលមានបុណ្យទានម្តងៗខ្ញុំតែងតែរំឭកឈ្មោះគាត់ ហើយធ្វើបុណ្យឧទ្ទិសកុសលទៅឲ្យគាត់ ។ ពេលនឹកគាត់ម្តងៗ ខ្ញុំលួចយំតែម្នាក់ឯង ។ គាត់ជាមនុស្សស្លូតមិនគួរណាគាត់ស្លាប់

ទេ ។ ខ្ញុំគិតដល់គាត់គ្រប់ពេល ។ បើសិនជាគាត់នៅរស់ម្ល៉េះខ្ញុំមិនពិបាកដូចសព្វថ្ងៃទេ ។◆◆◆

## ចែម ហ៊ឹម

### អតីតអ្នកបើកតាក់ស៊ី

*ប៊ុត លី មានស្រុកកំណើតនៅភូមិខ្វិត សង្កាត់សាក់សំពៅ ខ័ណ្ឌដង្កោ ។ លី ជាកូនពៅក្នុងចំណោមបងប្អូន៥នាក់ (ស្រី៣នាក់ ប្រុស២នាក់) ។ លី ជាកូនពៅក្នុងគ្រួសារ ។ បងប្អូនរបស់ លី ស្លាប់របបប៉ុលពតអស់ហើយ ខ្លះស្លាប់ដោយអត់អាហារខ្លះទៀត ត្រូវខ្មែរក្រហមបញ្ជូនទៅបាត់ដំបងហើយក៏បាត់ខ្លួន ។ ខាងក្រោមនេះគឺជាការរៀបរាប់របស់ លី ÷*

កាលពីក្មេងខ្ញុំធ្វើស្រែ ហើយមិនបានរៀនសូត្រទេ ។ បងប្អូនខ្ញុំមានឱកាសបានរៀនខ្ញុំ ចំណែកខ្ញុំវិញនៅផ្ទះធ្វើអង្ករឲ្យបងប្អូនហូបនិងថែជីងឺឪពុកម្តាយខ្ញុំ ។

ប្តីខ្ញុំឈ្មោះ ចែម ហ៊ឹម កាលគាត់ស្លាប់គាត់មានអាយុទើបតែជាង៥០ឆ្នាំប៉ុណ្ណោះ ។ ដើមឡើយគាត់រស់នៅសិត្បូ ស្រុកស្អាង ។ ប្តីខ្ញុំជាអ្នកឡើងត្នោត ក្រោយមកគាត់បើកឡានតាក់ស៊ី ។ គាត់ស៊ីឈ្នួលបើកឡានតាក់ស៊ី បានប្រាក់ឈ្នួលក្នុងមួយខែ៥០០រៀល ។ ពេលមួយគាត់បានមកលេងម្តាយមីងគាត់នៅភូមិខ្វិត ម្តាយមីងគាត់បានណែនាំគាត់ឲ្យចូលដណ្តឹងខ្ញុំ ។ យើងស្គាល់គ្នាមុនរៀបការរហូតដល់មួយឆ្នាំ ។

ក្រោយពីរៀបការរួចគាត់នៅតែធ្វើស្រែនិងបើកឡានដដែល ពេលទំនេរគាត់ផ្អៀតឡើងត្នោតនិងរកត្រី ។ ថ្វីត្បិតតែគាត់ជាអ្នកបើកឡានមែន ប៉ុន្តែខ្ញុំមិនដែលបានធ្វើដំណើរទៅឆ្ងាយជាមួយគាត់ទេ ខ្ញុំនៅតែផ្ទះឯគាត់វិញព្រលឹមចេញបាត់ ល្ងាចទើបមកដល់ផ្ទះ ។

ប្តីខ្ញុំជាកូនច្បងក្នុងគ្រួសារ គាត់ទទួលបន្ទុកចិញ្ចឹមប្អូន៩នាក់ទៀត ហេតុនេះជីវភាពរស់នៅរបស់យើងមិនសូវជាគ្រប់គ្រាន់ប៉ុន្មានទេ ដោយសារគ្រួសារគាត់ស្ថិតក្នុងបន្ទុកតែមួយជាមួយយើង ។ ម្តាយក្មេកខ្ញុំក៏មកស្នាក់នៅនឹងខ្ញុំនេះដែរ ។ ចរិតប្តីខ្ញុំមិនកោងកាចហើយក៏មិនដែលឈ្លោះទាស់ទែងជាមួយបងប្អូនដែរ ។ ខ្ញុំស្តាយណាស់ដែលគាត់ស្លាប់នៅក្នុងរបបប៉ុលពត ។

នៅជំនាន់ លន់ នល់ ពេលគ្រាប់បែកទម្លាក់កាន់តែច្រើនឡើងនៅក្នុងភូមិ ក្រុមគ្រួសារខ្ញុំភៀសខ្លួនទៅស្នាក់នៅទួលឫស្សីសាញ់ ។ ពេលយើងចេញផុតយន្តហោះទម្លាក់គ្រាប់បែកឆេះផ្ទះអស់ជាច្រើនខ្នង ប៉ុន្តែគ្មាននរណាម្នាក់ទទួលរងរបួសទេ ។ ពេលនោះគឺជារដូវច្រូតកាត់យើងកំពុងតែច្រូតស្រូវនៅឡើយ ហេតុនេះយើងផ្អៀតចូលមកភូមិវិញ ច្រូតស្រូវខ្លះយកទៅហូប ។ ក្រៅពីស្រូវដែលយើងច្រូតបានដោយខ្លួនឯងនៅមានអង្ករជំនួយដែលរដ្ឋាភិបាល លន់នល់ទម្លាក់មកតាមយន្តហោះ ប៉ុន្តែអង្ករនោះទម្លាក់ឆ្ងាយណាស់ នៅជិតពោធិចិនតុងនិងវត្តកំពែងឯណោះ អ្នកនៅម្តុំនោះទើបអាចទៅរើសបាន ។ យើងផ្អៀតជីកក្តាមលក់ដើម្បីរកលុយទិញអង្ករហូប ។ ផ្អៀតពេលដែលសភាពការណ៍ក្នុងភូមិស្ងប់ស្ងាត់ ខ្ញុំផ្អៀតត្រឡប់មករកខសនៅក្នុងភូមិម្តងម្កាលដែរ ។

ពេលភៀសខ្លួនចេញពីផ្ទះទៅខ្ញុំគ្មានយកបានអីវ៉ាន់ ទៅជាមួយច្រើនទេ គឺយកបានតែក្រមួយ និងរបស់របរជាប់ខ្លួនបន្តិចបន្តួច ។ យើងសង់ជម្រកដើម្បីស្នាក់នៅបណ្តោះអាសន្ននៅទួលឫស្សីសាញ់រហូតពេលដែលយន្តហោះទម្លាក់គ្រាប់នៅទួលនេះទៀតទើបយើងរត់ភៀសខ្លួនទៅរកកន្លែងផ្សេង ។

## ជម្លៀសឆ្នាំ១៩៧៥

ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានដេញគ្រួសារខ្ញុំឲ្យចេញទៅ ហើយប្រាប់ឲ្យធ្វើដំណើរទៅខាងមុខទៅរកអង្គការ ។ ខ្ញុំមិនទាំងដឹងថាអង្គការនោះជានរណានិងនៅឯណាផង ។ យើងខ្លាចខ្មែរក្រហមសម្លាប់ យើងចេះតែធ្វើដំណើរទៅមុខតាមបញ្ជាទៅ ។ យើងស្នាក់នៅកន្លែងនេះបន្តិច នៅកន្លែងនោះបន្តិចរួចយើងចេះតែបុកស្រូវហូបតាមផ្លូវរហូត ។ យើងចុះពីទួលឫស្សីសាញ់ទៅឃុំក្រាំងថ្មី ខេត្តកណ្តាល ។

ទៅដល់ដំបូងយើងគ្មានផ្ទះនៅត្រឹមត្រូវទេ យើងឡើងកាប់ស្លឹកត្នោតដោយខ្លួនឯងដើម្បីធ្វើខ្ទមនៅ ។ យើងជាប្រជាជនថ្មីត្រូវរស់នៅដោយឡែកពីប្រជាជនមូលដ្ឋាន ។

ការងារខ្ញុំនៅពេលនោះគឺធ្វើអង្ករ រីឯប្តីខ្ញុំអារឈើហ៊ុំបធ្វើផ្ទះនិងកាប់ស្លឹកត្នោត ។ ជួនពេលខ្លះខ្ញុំនៅបុកអង្ករដល់ម៉ោងមួយរសៀលហើយ នៅមិនទាន់បានបាយហូបទៀត ។ ពេលខ្លះទៀតខ្ញុំសម្រាកបានតែមួយភ្លែតក៏ត្រឡប់ទៅធ្វើការវិញ ។ ខ្ញុំត្រូវតែធ្វើការឲ្យទាន់ពេលវេលា ។ ក្រុមធ្វើអង្ករមានតែ១២នាក់ត្រូវ

អង្គការបញ្ជាឲ្យខ្ញុំធ្វើអង្ករឲ្យបាន៨គោនក្នុងមួយថ្ងៃ។ បើយើងធ្វើមិនទាន់ពេលទេ អង្គការនឹងហៅយើងទៅកសាង។ យើងគ្មានត្បាល់ម៉ាស៊ីនទេគឺយើងធ្វើដោយត្បាល់ដៃសុទ្ធសាធ។ ត្បិតតែយើងជាអ្នកកិនស្រូវមែនតែយើងមិនដែលបានបាយល្អហូបដូចកម្មាភិបាលទេ យើងហូបតែបបររាវកក្តួកជាមួយសម្លត្រកួនព្រលឹតនិងដើមចេក។ ឯផលស្រូវដែលផលិតបានត្រូវអង្គការប្រមូលទុកមិនឲ្យប្រជាជនហូបទេ។ ខ្ញុំមិនដឹងថាអ្នកមូលដ្ឋានហូបខុសពីយើងប៉ុយ៉ាងណាទេ ព្រោះយើងហូបដាច់ដោយឡែកពីអ្នកមូលដ្ឋាន។ ប្រជាជនមូលដ្ឋានមានសិទ្ធិហូបពោតគ្រាប់ធំៗពណ៌លឿង។

ខ្ញុំមានកូនទាំងអស់៥នាក់ ប៉ុន្តែយើងមិនបាននៅជុំគ្នាទេ។ កាលនោះអង្គការប្រើយើងឲ្យកាប់ដីនៅក្បែរព្រះវិហារប៉ះចំគ្រាប់ផ្ទុះស្លាប់អស់កូន២នាក់។ សព្វថ្ងៃខ្ញុំនៅសល់កូនតែ៣នាក់ទេ។ ខ្ញុំពិបាកណាស់ បើយើងមិនកាប់ក៏យើងស្លាប់ យើងទៅកាប់ហើយផ្ទុះគ្រាប់ក៏ស្លាប់ដែរ។

ប្តីខ្ញុំគ្មានកំហុសទេមានតែសាច់ញាតិខ្លួនឯងទេដែលនាំគាត់យកទៅសម្លាប់។ ពូហ៊ុង ជាខ្មែរ ក្រហមនិងជាប្រជាជនមូលដ្ឋានចាស់។ កាលនោះខ្ញុំមិនដឹងថាគាត់បានធ្វើអ្វីខុសទេ គាត់នៅអារឈើនៅឡើយទេ។ យប់ឡើង ពូហ៊ីង បានមកប្រាប់ប្តីខ្ញុំថាមិនចាំបាច់ទៅអារឈើនៅវត្តព្រៃរោងទៀតទេ តែឲ្យគាត់ទៅទន្លេបាទីវិញនៅព្រឹកស្អែក។ ប្តីខ្ញុំដូចជាដឹងខ្លួនមុន គាត់និយាយថា ពូហ៊ីងមកហៅប្តីខ្ញុំនៅពេលយប់ ប៉ុន្តែគាត់ថាចាំភ្លឺទើបគាត់ទៅ។ គាត់ប្រាប់ ពូហ៊ីង វិញថា “ពូឯងមិនបាច់កុហកខ្ញុំថាយកធ្វើរោងឲ្យពួកដែលយកទៅមុនទេ ខ្ញុំដឹងតែយកខ្ញុំទៅសម្លាប់ហើយ”។ ចំណែកឯកូនៗវិញក៏មិនបានដឹងដែរ ព្រោះវារវល់ទៅកាប់ទន្រ្ទានខែត្រ។ នៅម៉ោងប្រមាណ៨ព្រឹកគាត់ធ្វើដំណើរទៅជាមួយអ្នកស្រុកពីរនាក់ដោយចងខ្សែដើរទៅបន្តគ្នា។ គ្មាននរណាហ៊ានមើលគាត់ទេ។ ពេលនោះខ្ញុំមិនបានដឹងទេ ព្រោះរវល់ធ្វើអង្ករ។ ២ថ្ងៃក្រោយទើបខ្ញុំដឹង។

ក្រោយពីយកប្តីខ្ញុំទៅបាត់ អង្គការបានហៅខ្ញុំទៅកសាងថាខ្ញុំធ្វើអង្ករឲ្យប្រជាជនហូបមិនទាន់។ ថ្ងៃមួយពេលមកធ្វើអង្ករវិញឈ្លបប្រើខ្ញុំឲ្យទៅដឹករណ្តៅសម្រាប់កប់ខ្លួនឯង។ ខ្ញុំតវ៉ាថាខ្ញុំមានកំហុសអ្វីទើបឲ្យខ្ញុំមកជីករណ្តៅ។ ឈ្លបសម្តុតខ្ញុំថាហេតុអ្វីខ្ញុំហ៊ានតវ៉ាជាមួយគេ។ ខ្ញុំនៅតែបន្តប្រកែកតវ៉ាថា “ខ្ញុំគ្មានកំហុសទេ ហេតុអ្វីក៏យកខ្ញុំមកកប់ យកប្តីខ្ញុំទៅម្នាក់ហើយ នៅមកយកខ្ញុំទៅទៀត”។ ឈ្លបក៏ដោះលែងខ្ញុំ។

ប្តីខ្ញុំទៅបាត់រហូតទាល់តែថ្ងៃបែក១៩៧៩ហើយ នៅមិនទាន់ឃើញត្រឡប់វិញទៀត។ គាត់ប្រហែលជាស្លាប់នៅទន្លេបាទីបាត់ហើយមើលទៅ។ យើងគ្មានសង្ឃឹមថាគាត់នៅរស់ទេ បើសិនជាគាត់នៅរស់គឺគាត់មករកយើងហើយ កូនខ្ញុំក៏អត់សង្ឃឹមចំពោះប៉ាវាដែរ។ ក្រោយឆ្នាំ១៩៧៩ មីងម្នាក់ឈ្មោះ គ្រប់ ដែលធ្លាប់ជាប់គុកជាមួយប្តីខ្ញុំបានបបួលប្តីខ្ញុំរត់មកដែរ ប៉ុន្តែប្តីខ្ញុំមិនព្រមមកតាម។


ថែម ហ៊ីន មុនឆ្នាំ១៩៧៥

ខ្ញុំមិនដឹងថារូបថតមួយសន្លឹកនេះថតជំនាន់ណាទេ ព្រោះរូបថតនេះមិននៅជាមួយខ្ញុំទេ តែនៅជាមួយម្តាយក្មេកខ្ញុំ គាត់លាក់នៅក្នុងហិបស្លា។ រហូតទាល់តែម្តាយក្មេកខ្ញុំមកពីបាត់ដំបងទើបឃើញនៅសល់រូបថតមួយសន្លឹកនេះរួចយកទៅផ្តិត។ ខ្ញុំបង្ហាញរូបថតនេះទៅកូនខ្ញុំ ពួកវាស្គាល់ឪពុកគ្រប់គ្នាលើកលែងតែកូនស្រីពៅខ្ញុំទេដែលមិនស្គាល់ ព្រោះកាលណោះវានៅតូចពេក។

ពេលជម្លៀសចេញពីភូមិខ្ញុំបានយករូបថតខ្លះទៅតាមដែរ លុះដល់ យើងយកទៅដល់ យើងកប់រូបនោះចោលទៅក្នុងដី។ ពេលដែលខ្មែរក្រហមគាស់ទៅឃើញក៏យករូបទៅហែកចោលអស់។

កូនខ្ញុំធ្លាប់ទៅរកគ្រូមើលដែរ គ្រូទាយថាគាត់នៅរស់ហើយនឹងត្រឡប់មកវិញនៅខែ១២។ គ្រូទាយជាច្រើននាក់ហើយសុទ្ធតែប្រាប់ថាប្តីខ្ញុំនៅរស់។ តាំងពី៧៩មកឲ្យតែដល់ខែ១២ខ្ញុំចាំមើលផ្លូវគាត់រាល់ឆ្នាំ ប៉ុន្តែសូម្បីតែដំណឹងបន្តិចក៏គ្មានដែរ។ ខ្ញុំទៅបញ្ចាន់រូបឃើញតែគាត់អង្គុយសំកុកដៃជាប់ខ្នោះ។ ខ្ញុំគ្រាន់តែមានអារម្មណ៍ថា បើគាត់ពិតជានៅរស់មែនទោះជាគាត់នៅដល់ទីណាក៏គង់តែមករកក្រុមគ្រួសារឃើញដែរ។ អារម្មណ៍មួយទៀតនៅទឹកស្តាយស្រណោះគាត់មិនគួរណាគាត់ ស្លាប់យ៉ាងនេះសោះ។ ខ្ញុំមិនអាចបំភ្លេចបានទេតាំងពីចាប់ដៃគ្នាមក យើងមិន

*ដែលឈ្មោះទាស់ទែងគ្នាទេ ។◆◆◆*

## កូវ ជ័រ និង កូវ ជឿន

## អតីតទាហានលន់នល់

*គ្រួសាររបស់ សំរិទ្ធិ គិត មានសមាជិកពីរនាក់ជាទាហានលន់នល់ គឺប្តីរបស់គាត់ឈ្មោះ កូវ ជ័រ និងកូនប្រុសឈ្មោះ កូវ ជឿន ។ អ្នកទាំងពីរស្លាប់នៅក្នុងស្ថានភាពពីរខុសគ្នា កូវ ជឿន ស្លាប់ក្នុងសង្គ្រាមរវាងលន់នល់និងខ្មែរក្រហម រីឯ កូវ ជ័រ ស្លាប់ដោយជំងឺនៅក្នុងរបបខ្មែរក្រហម ។ រឿងរ៉ាវរបស់ កូវ ជឿន និង កូវ ជ័រ ស្ថិតនៅជាមួយនិងរូបថតនិងការចងចាំរបស់ សំរិទ្ធ គិត ÷*

*ប្តីខ្ញុំឈ្មោះ កូវ ជ័រ ជាកូនចៅចិនមានសម្បុរសមិនខ្ពស់មិនទាប ។ គាត់ជាកូនទីពីរក្នុងគ្រួសារ ។ គាត់រៀនបានតិចតួចទេ គឺត្រឹមថ្នាក់ទី១០ចាស់ ។*

*ខ្ញុំរៀបការនៅអាយុ១៨ឆ្នាំ ពេលនោះប្តីខ្ញុំអាយុ២២ឆ្នាំ ។ យើងរស់នៅភូមិជាមួយគ្នា ប៉ុន្តែយើងមិនស្គាល់គ្នាទេទោះបីជាយើងនៅផ្ទះជិតគ្នាក៏ដោយ ។ ពេលខ្ញុំធំឡើងពុកម៉ែរបស់គាត់បានចូលដណ្តឹងខ្ញុំ ។ ពេលនោះពុកម៉ែខ្ញុំបង្គាប់គាត់ថ្លៃផ្ទះ១០០រៀល ។ កាលនោះ១០០រៀល ថ្លៃណាស់មិនងាយនឹងរកទេ ។ ពុកម៉ែគាត់ស្រឡាញ់ខ្ញុំ គាត់សុខចិត្តយល់ព្រមតាមការបង្គាប់ ។ យើងរៀបការអស់ជ្រូកគោជាច្រើន ។*

*ពេលរៀបការរួច គាត់បានផ្លាស់មកនៅផ្ទះខាងខ្ញុំ ។ ជីវភាពគ្រួសារខ្ញុំនៅសម័យលន់នល់មិនសូវជាធូរធារប៉ុន្មានទេ ។ ផ្ទះខ្ញុំក្រសឹងតែរកបាយហូបមិនបាន ពេលខ្លះគ្រួសារខ្ញុំត្រូវទិញបាយក្តាំងចែកឲ្យកូនៗហូប ។ យើងគ្មានស្រែធ្វើទេ ហេតុនេះយើងចេះតែរករបរផ្សេងៗដើម្បីបគ្រ្គប់ជីវភាព ដូចជាកាប់ខសឬធ្វើនំលក់ជាដើម ។ ជួនកាលខ្ញុំនិងប្តីខ្ញុំត្រូវឡើងទៅភ្នំពេញរកស៊ីលក់ដូរនៅតាមផ្សាររយៈ៤-៥ថ្ងៃទើបមកម្តង ។*

*ខ្ញុំមានស្រុកកំណើតនៅភូមិខ្វិត ឃុំសាក់សំពៅ ស្រុកដង្កោ ខេត្តកណ្តាល ។ នៅជំនាន់លន់នល់ ដោយមានការទម្លាក់គ្រាប់បែកកាន់តែញឹកញាប់ ខ្ញុំនិងប្តីព្រមទាំងម្តាយឪពុកបងប្អូនបានរត់ចេញពីភូមិ ។ យើងរត់ទៅដល់វត្តចំបក់ ភូមិក្រាំងទ្រា ឃុំទៀន ស្រុកកណ្តាលស្ទឹង ។ ពេលយើងរត់ចេញពីភូមិ យើងគ្មានទ្រព្យសម្បត្តិមានតម្លៃដើម្បីយកទៅជាមួយទេមានតែខោអាវមួយកំប្លេម្នាក់ប៉ុណ្ណោះ ។ នៅឆ្នាំ១៩៧៥ ពេលដែលខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គ្រួសារខ្ញុំជម្លៀសទៅភូមិថ្ម ហើយក្រោយមកក៏ត្រឡប់មកភូមិក្រាំងទ្រាវិញ ។ យើងមាននៅតាមផ្លូវខ្ញុំបានកប់ខោអាវទាហាន និងរូបថតរបស់ប្តីខ្ញុំចោល ។ នៅពេលខ្មែរក្រហមដួលរលំ យើងបានត្រឡប់ទៅមើលកន្លែងដែលខ្ញុំកប់របស់ទាំងនោះ ឃើញសុទ្ធតែស្នាមគាស់ក្រហេងក្រហូង ។ សំណាងល្អដែលខ្មែរក្រហមមិនយករូបថតទាំងនោះមកតាមដានរកម្ចាស់ ។*

*ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្ញុំមិនបានរស់នៅជាមួយអ្នកមូលដ្ឋានទេ ។ ខ្ញុំជាអ្នកជម្លៀសរស់នៅតំបន់ខាងមុខ ប្រជាជនមូលដ្ឋានរស់នៅតំបន់ខាងក្រោយ ។ ប្រជាជនមូលដ្ឋានជាអ្នកគ្រប់គ្រងប្រជាជនថ្មី ។ យើងមិនអាចរស់នៅជួបជុំគ្នាទេ កុមារត្រូវដាក់នៅកងកុមារ ស្ត្រីនៅកងស្ត្រី ពេលណាខ្ញុំចង់ជួបកូនខ្ញុំទៅជួបដោយលួចលាក់ ។ យើងហូបតែបបរលាយពោត ។ នៅពេលយើងទៅដល់ឃុំទៀនដំបូងអង្គការចែកអង្ករឲ្យយើងដាំហូបនៅតាមផ្ទះក្នុងម្នាក់បានអង្ករចំនួន២ខាំ ។ ពេលនោះយើងហៅថាជំនាន់អង្ករពីរខាំ ។ ក្រោយមក អង្ករ ចាន ឆ្នាំង និងសម្ភារផ្សេងៗទៀតត្រូវអង្គការតម្រូវឲ្យដាក់ក្នុងសហករណ៍រួមទាំងអស់ លើកលែងតែសម្លៀកបំពាក់ស្លៀកជាប់នឹងខ្លួន ។ ខ្ញុំមិនដែលបានហូបឆ្អែតទេនៅពេលចូលសហករណ៍បាយរួម ។ ក្នុងមួយថ្ងៃយើងមានរបបអាហារពីរពេលបបរ ឬបាយសុទ្ធតែវាល់វែកទាំងអស់ក្នុងមួយពេលយើងបានបបរតែបីវែកប៉ុណ្ណោះ ។ របបអាហារប៉ុណ្ណោះមិនសក្តិសមនឹងកម្លាំងពលកម្មដែលខ្ញុំបញ្ចេញទេ ។*

*ខ្ញុំជាអ្នកសែងលាមកនិងលាយជីដាក់ស្រែ ។ ខ្ញុំដើរប្រមូលលាមកតាមផ្ទះ ហើយសែងទៅកន្លែងធ្វើជី ។ ថ្ងៃខ្លះខ្ញុំសែងដួលអុកគូថនៅលើស្ពានធ្វើឲ្យកំពប់លាមកអស់ ។*

*ប្តីខ្ញុំឈឺរាគមួលរហូតដល់ស្លាប់ដោយគ្មានថ្នាំព្យាបាល ។ គាត់មិនសុខចិត្តលេបថ្នាំអាចម៍ទន្សាយរបស់ខ្មែរក្រហមទេ ។ គាត់សម្រាកនៅពេទ្យប្រហែលពីរខែទើបស្លាប់ ។ ខ្ញុំខំឆ្លៀតលួចលាក់អន្ទង់ទុកឲ្យគាត់បរិភោគ ប៉ុន្តែត្រូវអង្គការដកហូតអស់រលីង ។ រហូតដល់ពេលគាត់ស្លាប់ ទើបអង្គការហៅខ្ញុំឲ្យទៅដឹកសពរបស់គាត់យកទៅកប់ ។ ប្រជាជនថ្មីមួយចំនួនបានជួយខ្ញុំដឹកសពប្តីខ្ញុំទៅកន្លែងកប់ ។ ពេលកំពុងកប់មេឃរកកលភ្លៀង ខ្ញុំក៏រត់ត្រឡប់*

មកផ្ទះវិញទាំងមិនដឹងថាសពកប់ដិតហើយឬនៅទេ ។ នៅក្រោយពេលខ្មែរក្រហមដួលរលំទៅខ្ញុំបានទៅមើលកន្លែងកប់សពនោះម្តងទៀត ខ្ញុំគាស់មកបានតែឆ្អឹងលលាដ៍និងធ្មេញ ។ ខ្ញុំបានយកឆ្អឹងនោះមកធ្វើបុណ្យនៅវត្ត ។ ខ្ញុំស្រណោះគាត់ណាស់ មុនពេលគាត់ស្លាប់យើងមិនបានជួបគ្នាផ្តែផ្តាំទេ អង្គការមិនទាំងអនុញ្ញាតឲ្យខ្ញុំទៅកំដរគាត់នៅពេទ្យផង ។

កូនប្រុសខ្ញុំជាមនុស្សដឹងគុណណាស់ ។ មុននឹងចូលធ្វើទាហាន ជឿន ធ្លាប់បួសនេនបានបីវស្សានៅវត្តរកាខ្សាច់ ។

ជឿន ក៏ជាមនុស្សស្លូតបូតត្រឹមត្រូវមិនដែលចេះជេរស្តីឬសម្តីធំតូចដាក់បងប្អូនទេ ហើយក៏មិនដែលហ៊ានតវ៉ាជាមួយឪពុកម្តាយដែរ ។ កូនៗខ្ញុំខស្សាហ៍ឈ្លោះប្រកែកគ្នាណាស់ ប៉ុន្តែ ជឿន មិនដូចបងប្អូនវាទាល់តែសោះ ។ ជឿន មិនចេះឈ្លោះរករឿងជាមួយបងប្អូនឯងទេ ។ នៅពេលទៅរកត្រីមួបបានយកមកផ្ទះ វាមិនដែលនៅចាំបាយសម្ងំឆ្អិនសិនទេ វាហូបបាយជាមួយអំបិលហើយក៏ចេញទៅបាត់ទៀត ។

ខ្ញុំស្តាយ ជឿន ណាស់ ព្រោះវាជាកូនប្រុសតែម្នាក់គត់ ។ ខ្ញុំស្រឡាញ់កូនម្នាក់នេះស្មើជីវិត ។ រូបថតរបស់កូនខ្ញុំធ្វើឲ្យខ្ញុំអណោចអាធ័មកូនណាស់ ។ បើកុំតែស្រុកកើតចម្បាំងកុំអីក៏កូនខ្ញុំមិនស្លាប់ដែរ ។

ជឿន ជាកូនទីបីក្នុងចំណោមកូន១៣នាក់និងជាកូនប្រុសតែម្នាក់គត់ ។ ជឿន ត្រូវបង្ខំចិត្តចូលធ្វើជាទាហានលន់នល់ ។ ដោយគ្មានវិធីជ្រើសរើស ហើយយើងគ្មានផ្លូវដើម្បីរត់ចេញពីភូមិ ខ្ញុំមិនបានដឹងច្បាស់ថាកូនខ្ញុំបានទៅហាត់ក្បួនយុទ្ធសាស្ត្រនៅទីណាច្បាស់លាស់ទេ ខ្ញុំគ្រាន់តែដឹងថាទាហាន ភាគច្រើនត្រូវទៅហាត់ទាហាននៅបន្ទាយវត្តអង្គមេត្រីក្នុងឃុំព្រៃសរ ។

ជឿន បានរៀបការជាមួយស្ត្រីម្នាក់ឈ្មោះ ជុក រ៉ុម នៅព្រែកអញ្ចាញ និងមានកូនប្រុសម្នាក់ ហើយទៅរស់នៅខាងប្រពន្ធ ។ ជឿន បានត្រូវបញ្ជូនឲ្យទៅច្បាំងនៅកប់ស្រូវ ។ អកុសល ពេលកំពុងច្បាំងជាមួយកងទ័ពខ្មែរក្រហម ជឿន ត្រូវរបួសហើយក៏បញ្ជូនឲ្យទៅសម្រាកនៅពេទ្យរុស្ស៊ី ។ កូនខ្ញុំត្រូវរបួសជើង ប៉ុន្តែវាមិនបានទទួលការព្យាបាលដោយយកចិត្តទុកដាក់ទេទើបបណ្តាលឲ្យស្លាប់ ។ នៅពេលនោះមានទាហានរបួសច្រើនណាស់សម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ ។ ពេល ជឿន ស្លាប់ហើយ ខ្ញុំបានដឹកសាកសពកូនទៅស្រុកប្រពន្ធវានៅព្រែកអញ្ចាញដើម្បីធ្វើបុណ្យ ។ កូនប្រសាខ្ញុំយំបោកខ្លួនស្ទើរតែលែងចេញទឹកភ្នែក ។ ពេលនោះចៅប្រុសខ្ញុំទើបតែចេះអង្គុយ គឺមុនខ្មែរក្រហមវាយចូលភ្នំពេញប្រមាណកន្លះខែ ។

ខ្ញុំចាំថាពេលមួយនោះ អង្គការអនុញ្ញាតឲ្យប្រជាជនទាំងអស់សម្រាកហើយអាចទៅលេងកូនចៅ ឬបងប្អូនដែលនៅកងផ្សេងពីគ្នាបាន គឺនៅពេលចូលឆ្នាំខ្មែរ ។ ទោះជាយ៉ាងនេះក៏ដោយ យើងមិនអាចធ្វើបុណ្យឬទៅវត្តបានទេ ខ្មែរក្រហមបំបាត់វត្តអារាមពិធីបុណ្យសាសនាប្រពៃណី និងសាសនាទាំងអស់ ។ ដាក់ស្តែងសូម្បីអ្នកដែលកោរសក់បំបាត់ចៃក៏ត្រូវអង្គការសង្ស័យថាកោរសក់លាបំណន់ដែរ ហើយត្រូវអង្គការហៅទៅសួរដើកឬសគល់ ។






រូបថតដែលនៅសល់ទាំងពីរសន្លឹកនេះខ្ញុំរក្សាទុកដោយប្រុងប្រយ័ត្នណាស់ ។ ខ្ញុំដាក់ក្នុងស្បោងមួយ ហើយទុកក្នុងហោប៉ៅជាប់រហូតមិនហ៊ានដាក់ចោលនៅផ្ទះទេ ។ ពេលខ្ញុំទៅធ្វើការក៏ខ្ញុំដាក់តាមខ្លួនដែរ ខ្លាចអង្គការឡើងមកឆែកនៅលើផ្ទះឃើញ ។ យប់មួយនោះ ពេលខ្ញុំកំពុងកណ្តៀតបង្គីដើរលើខ្នងប្រឡាយ ខ្ញុំដើរទាក់នឹងខ្សែភ្លើងដែលគនឹងអំពូលដើម្បីបំភ្លឺពេលកំពុងធ្វើការហើយ ត្រូវភ្លើងឆក់ធ្លាក់ចូលក្នុងប្រឡាយទឹក ។ ខ្ញុំទទឹកខ្លួនជោកចំណែកឯរូបថតដែលនៅជាប់នឹងហោប៉ៅខ្ញុំក៏ទទឹកអស់ ។ ពេលមកដល់ផ្ទះវិញ ខ្ញុំលួចហាលរូបថតនោះ ទើបរូបថតខ្លះរបករបាញ ។ រូបថតកូនខ្ញុំនេះរបកត្រង់ភ្នែក ។

ក្រៅពីរូបថតទាំងពីរសន្លឹកនោះ ខ្ញុំបានយករូបថតផ្សេងៗពីរ-បីសន្លឹកទៅជាមួយដែរ ដូចជារូបថត ជឿន កាលនៅបួសជាព្រះសង្ឃ ប៉ុន្តែរូបថតទាំងនោះបានរលុបខូចអស់ទៅហើយ ។ រូបថតកូនប្រុសខ្ញុំថតពាក់អាវកបើកពណ៌ក្រហមលាយផ្កាពណ៌លឿងខៀវ

ស្អាតណាស់ ហើយមានក្រវ៉ាត់កន្សែងចងនៅកអាវទៀត ។

ក្រោយឆ្នាំ១៩៧៩ ខ្ញុំសល់តែរូបថតពីរសន្លឹកនេះគត់ ។ រូបថតនេះធ្វើឲ្យខ្ញុំនឹកឃើញកូនប្រុសនិងប្តីខ្ញុំ ។ កូនខ្ញុំជាមនុស្សស្លូតបូតត្រឹមត្រូវ បែរជាត្រូវស្លាប់នៅក្នុងចម្បាំង ។ ខ្ញុំស្រណោះប្តីខ្ញុំដែលឈឺមិនមានម្ហូបអាហារបរិភោគគ្រប់គ្រាន់រហូតដល់ស្លាប់ ។ ខ្ញុំចាំពេលមួយនោះ គាត់ហូបបាយអស់ពីឆ្នាំង តែគាត់នៅមិនទាន់ឆ្អែត គាត់នៅមិនអស់ចិត្តហើយអង្គុយសម្លឹងឆ្នាំង ។ ឃើញដូច្នេះខ្ញុំនិយាយនឹងគាត់ថា "កុំសម្លឹងឆ្នាំង របបដែលអង្គការចែកឲ្យយើងគឺមានតែប៉ុណ្ណេះ យើងហូបមិនឆ្អែតទាំងអស់គ្នាទេ" ។ សង្គមមានការបែកបាក់ធ្វើឲ្យគ្រួសារខ្ញុំបែកបាក់គ្នាដែរ ។ បើគ្មានសង្គ្រាមទេ យើងពិតជាបានរស់នៅជួបជុំគ្នា ។

**ប៉ាង ពីរ័ន និង ស៊ីរិ សាវីណា**

# គ្មានអ្វីអាចសងជីវិតក្រុមគ្រួសារខ្ញុំបានទេ


**អន ស៊ីផាន ឆ្នាំ២០០៥**

អន ស៊ីផាន អាយុ៥៦ឆ្នាំ រស់នៅស្រុកកំពង់លាវ ខេត្តព្រៃវែង ។ គាត់មានបងប្អូន៨នាក់ ក្នុងនោះ ៤នាក់ បានស្លាប់នៅក្នុងរបបខ្មែរក្រហម ។

បងប្រុសរបស់ ស៊ីផាន ឈ្មោះ គោ ឈុន គឺជាសិស្សពូកែប្រចាំខេត្តស្វាយរៀង ។ ក្រោយពីប្រលងជាប់សញ្ញាបត្របាក់ឌុប ឈុន បានបន្តការសិក្សានៅមហាវិទ្យាល័យមួយនៅទីក្រុងភ្នំពេញ ។ ឈុន រៀនបណ្តើរបង្រៀនសិស្សបណ្តើរដើម្បីយកប្រាក់មកផ្គត់ផ្គង់គ្រួសារនិងការសិក្សារបស់ខ្លួនឯងនិងប្អូនៗ ។ ៥ឆ្នាំក្រោយមក ឈុន ក៏ទទួលតំណែងជានាយកវិទ្យាល័យព្រះអង្គឌួង ។

ឆ្នាំ១៩៦៤ ឈុន រៀបការជាមួយនារីម្នាក់ឈ្មោះ ខៀវ ស៊ីអាន និងមានកូនបីនាក់ ។ បន្ទាប់ពីរួមរស់ជាមួយគ្នាបានរយៈពេលជិត៥ឆ្នាំអ្នកទាំងពីរក៏លែងលះគ្នា ។ ឆ្នាំ១៩៦៩ ឈុន បានជាប់ជាតំណាងរាស្ត្រខេត្តព្រៃវែង ។ ឆ្នាំ១៩៧៣ បន្ទាប់ពីរៀបការឲ្យប្អូនស្រីពីរនាក់ឈ្មោះ ស៊ីផាន និង ស៊ីសុផន ឲ្យមានគូស្រករហើយ ឈុន បានរៀបការប្រពន្ធទីពីរឈ្មោះ ស៊ីនួន ។ នៅឆ្នាំ១៩៧៤ ដោយសភាពការណ៍មានភាពតានតឹង ឈុន មិនហ៊ានសម្រាកនៅផ្ទះរបស់ខ្លួនឯង គាត់ដើរស្នាក់នៅផ្ទះប្អូនៗម្នាក់ៗពីរបីយប់ ។ ឈុន បានបំពេញសំណុំបែបបទនិងធ្វើលិខិតឆ្លងដែនរួចរាល់ហើយ ដើម្បីធ្វើដំណើរទៅបរទេសជាមួយ សិរិមតៈ និង អ៊ឹង ម៉ឹង (តំណាងរាស្ត្រមណ្ឌលបាត់ដំបង) រង់ចាំតែថ្ងៃចេញដំណើរប៉ុណ្ណោះ ប៉ុន្តែ ឈុន បែរជាប្តូរចិត្តមិនទៅវិញ ព្រោះគាត់មិនដាច់ចិត្តចាកចោលឪពុកចាស់ជរានិងបងប្អូន ។

នៅអំឡុងពេលមានការបាញ់ផ្លោងនៅតាមជាយទីក្រុងភ្នំពេញ បងប្អូនទាំងអស់របស់ ស៊ីផាន បានមកជួបជុំគ្នានៅផ្ទះរបស់ ស៊ីផាន នៅម្តុំផ្សារទួលទំពូង លើកលែងតែក្រុមគ្រួសាររបស់ គោ ឈុន ប៉ុណ្ណោះ ។

ពេលធ្វើដំណើរជម្លៀសចេញពីទីក្រុងភ្នំពេញ ប្តីរបស់ ស៊ីផាន ឈ្មោះ គីមហេង បានក្រឡេកឃើញ ឈុន និង ឈឹម (បងធម៌របស់ ស៊ីផាន) ដែលរុំមុខនឹងក្រមាយ៉ាងជិតកំពុងបណ្តើរម៉ូតូមានផ្ទុកអីវ៉ាន់មួយចំនួន ។ ស៊ីផាន បានស្ទុះទៅរកបងប្រុស ។ ឈុន បានខ្សឹបប្រាប់ ស៊ីផាន ថាកុំឲ្យនិយាយខ្លាំងៗពេកខ្លាចអ្នកផ្សេងឮ ។

ក្រុមគ្រួសាររបស់ ស៊ីផាន បានបន្តដំណើរទៅមុខទៀត ។ ឈុន នៅតែគ្របមុខនឹងក្រមាជានិច្ចដើម្បីកុំឲ្យអ្នកដទៃស្គាល់មុខ ។ ថ្ងៃរសៀល ស៊ីផាន និងក្រុមគ្រួសារបានមកដល់ឃុំចំបក់ ស្រុកបាទី ខេត្តតាកែវ ។

ដើមឆ្នាំ១៩៧៦ ក្រុមគ្រួសាររបស់ ស៊ីផាន ត្រូវអង្គការជម្លៀសទៅទីរួមស្រុកស្វាយស៊ីសុផុន ។ ឈុន បានជួបកម្មាភិបាលខ្មែរក្រហមមួយក្រុមដែលធ្លាប់ធ្វើគ្រូបង្រៀនជាមួយគ្នាមុនឆ្នាំ១៩៧០ និងធ្លាប់បបួលគាត់ឲ្យចូលបម្រើចលនារបស់ខ្មែរក្រហមដែរ ប៉ុន្តែគាត់បដិសេធ ។

ព្រលឹមឡើង ក្រុមគ្រួសាររបស់ ស៊ីផាន ត្រូវបានដឹកតាម

រថយន្តទៅ ភូមិគោករត់ ស្រុកភ្នំស្រុក ។

ទៅដល់ទីនោះ ក្រុមគ្រួសាររបស់ ស៊ីដាន ជួបការលំបាកក្នុងការហូបចុកជាខ្លាំង ។ ឈុន, ស៊ីដាន និង ប្តី បានរកក្តាមខ្យង និងសត្វល្អិតគ្រប់ប្រភេទដើម្បីយកមកបរិភោគ ។ ឈុន មិនដែលសម្លាប់សត្វធ្វើការងារបែបនេះទេពីមុនមក ។

ខ្មែរក្រហមប្រកាសឲ្យប្រជាជនយករបស់របរប្រើប្រាស់ទៅដាក់រួម ជាពិសេសរបស់មានតម្លៃដូចជាមាសពេជ្រជើម ។ ស៊ីដាន លាក់ទុកខោអាវរបស់គាត់មួយចំនួនដើម្បីទុកដូរអំបិល ស្ករ និងអង្ករ ។ រយៈពេលប្រហែលជាបីខែក្រោយ បន្ទាប់ពីប្រូតស្រូវរួចរសៀលប្រហែលម៉ោងបី មានកម្មាភិបាលមួយក្រុមបានបើកឡានមកឈប់នៅកន្លែងរបស់ ស៊ីដាន សួររក ឈុន ហើយប៉ុន្មាននាទីក្រោយមកកម្មាភិបាល៥នាក់ទៀតក៏មកដល់ ។ កម្មាភិបាលម្នាក់បានដឹកដៃ ឈុន ទៅក្បែរសាលារៀនដែលនៅមិនឆ្ងាយប៉ុន្មានពីកន្លែងធ្វើការរបស់គាត់ ហើយនិយាយគ្នាអស់រយៈពេលប្រហែល២ម៉ោង ។ បន្ទាប់មក ឈុនត្រឡប់មកកន្លែងធ្វើការវិញ ។ ឈុន ប្រាប់បងប្អូនៗថា កម្មាភិបាលទាំងនោះគ្រាន់តែមកសួរសុខទុក្ខគាត់ប៉ុណ្ណោះ ។ ចាប់តាំងពីពេលនោះមក ឈុន មានទឹកមុខស្រស់ស្រាត់គ្រប់ពេល ។

២ខែក្រោយមក ឈុន ត្រូវអង្គការចាប់ខ្លួនពេលដែលគាត់កំពុងបោកកណ្តាប់ស្រូវ ។ មុនពេលចាប់ខ្លួន កងសន្តិសុខតំបន់មួយក្រុមបានប្រកាសរកឈ្មោះឈុន ដោយប្រាប់ថា អង្គការឲ្យគាត់និងគ្រួសារផ្លាស់ទៅនៅភូមិផ្សេង ។ ស៊ីដាន ឆ្ងល់ជាខ្លាំងក៏បានសួរទៅកងសន្តិសុខថា "តើអង្គការផ្លាស់ប្តូរប្រជាជនទាំងអស់ឲ្យទៅនៅកន្លែងផ្សេងឬ?" ។ សន្តិសុខឆ្លើយថា ផ្លាស់តែក្រុមគ្រួសាររបស់ ឈុន ប៉ុណ្ណោះ ។ ដោយបារម្ភអំពីសុវត្ថិភាពរបស់ ឈុន, ឪពុកនិងប្អូនស្រីប្អូនប្រុស២នាក់ទៀតក៏បានសុំទៅជាមួយដែរ ។ ចំណែក ស៊ីដាន មិនបានទៅជាមួយ ឈុន ទេ ពីព្រោះប្តីរបស់គាត់មិនទាន់ត្រឡប់មកពីប្រូតវិញ ។ ដំបូង ស៊ីដាន មិនសូវមានការតក់ស្លុតទេ ប៉ុន្តែបន្ទាប់ពីឃើញក្រុមសន្តិសុខទាំងនោះភ្ជង់កាំភ្លើងបងប្អូននិងឪពុករបស់គាត់ឲ្យឡើងឡានទើបគាត់រន្ធត់ចិត្ត ហើយគិតនឹកក្នុងចិត្តថា អង្គការប្រាកដជាយកអ្នកទាំងអស់ទៅសម្លាប់ហើយ ។ ឪពុករបស់ ស៊ីដាន បាននិយាយថា "កូនអើយកុំយំអី បើអាយុវែងគង់តែជួបគ្នាទេ" ។ ឈុន បានរៀបចំចបកាប់ចបជីកដើម្បីយកទៅជាមួយ ប៉ុន្តែសន្តិសុខមិនអនុញ្ញាត ។

ពាក់កណ្តាលឆ្នាំ១៩៧៦ ខ្មែរក្រហមប្រកាសឲ្យអ្នកដែលធ្លាប់បម្រើការក្នុងរដ្ឋការលន់នល់ ដូចជាគ្រូបង្រៀន ទាហាន ប៉ូលិស ជាដើម ចូលមកទទួលតំណែងឡើងវិញ ។ ប្តីរបស់ ស៊ីដាន និងមិត្តភក្តិដែលធ្លាប់ធ្វើប៉េអឹមជាមួយគ្នា ព្រមទាំងបងប្រុសដែលធ្លាប់ធ្វើគ្រូបង្រៀនបានចេញទៅតាមការហៅរបស់អង្គការ ហើយក៏បាត់ខ្លួនរហូត ។ ស៊ីដាន មិនបានស៊ើបសួរដំណឹងប្តីរបស់គាត់ឡើយ ព្រោះគាត់ក៏ស្ថិតក្នុងការតាមដានដែរ ។

ឆ្នាំ១៩៧៨ ស៊ីដាន និងកូន២នាក់ បានរត់ទៅនៅតំបន់ជិតបឹងទន្លេសាប ដើម្បីទទួលបានអាហារហូបចុកច្រើន ព្រោះនៅទីនោះសម្បូរត្រី ។ អ្នកទាំងបីបានទទួលរបបអាហារគ្រាន់បើជាងមុន ។

ឆ្នាំ១៩៧៩ ស៊ីដាន និងកូនបានវិលត្រឡប់មកភូមិកំណើតរបស់គាត់នៅឯខេត្តស្វាយរៀង ហើយបានជួបបងប្រុសឈ្មោះ គោ ឈុំ ។

ឆ្នាំ១៩៨២ ស៊ីដាន បានទទួលដំណឹងតាមរយៈមិត្តភក្តិរបស់គាត់ម្នាក់ដែលរស់នៅប្រទេសបារាំង ថាប្អូនស្រីរបស់គាត់ឈ្មោះ ស៊ីសុផន រស់នៅសហរដ្ឋអាមេរិក ។ ក្រោយមកគាត់ក៏បានផ្ញើសំបុត្រទៅសួរសុខទុក្ខប្អូនរបស់គាត់ដែរ ។ ស៊ីសុផន បាននិយាយថា គោ ឈុន ព្រមទាំងប្រពន្ធកូនរបស់គាត់ ត្រូវខ្មែរក្រហមបញ្ជូនទៅភ្នំពេញក្នុងឆ្នាំ១៩៧៦ហើយបាត់ដំណឹងរហូត ។ ឪពុករបស់គាត់ស្លាប់ដោយសារជំងឺ ហើយគាត់បានកប់សាកសពឪពុករបស់គាត់ដោយផ្ទាល់ដៃ ។ ចំណែកគាត់និងបងប្រុសឈ្មោះ គោ ស៊ីដៃ បានរត់ទៅជំរំទល់ដែនកម្ពុជា-ថៃ ក្នុងឆ្នាំ១៩៧៩ ។ ស៊ីដៃ មិនបានទៅសហរដ្ឋអាមេរិកជាមួយ ស៊ីសុផន ទេ ។ សព្វថ្ងៃគាត់រស់នៅខេត្តបាត់ដំបង ។

ស៊ីដាន មិនដែលភ្លេចរបបខ្មែរក្រហមឡើយ គាត់បាត់បង់ប្តី និងបងប្អូនរបស់គាត់ជាច្រើននាក់ ។ គាត់យល់ថាតុលាការខ្មែរក្រហមអាចនឹងជួយឲ្យគាត់ស្ងប់ចិត្តខ្លះ ប៉ុន្តែមិនអាចជួយឲ្យបងប្អូនរបស់គាត់រស់រានមានជីវិតឡើងវិញបានទេ ។

**សារិន ឌីរ:**

# សំណងសម្រាប់ជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្ស ក្រុមខណ្ឌលិខិតូបករណ៍និងស្ថាប័ននានា

*(តពីលេខមុន)*

**៣) ស្ថាប័នទាក់ទិននឹងសំណង**

លិខិតូបករណ៍ច្បាប់សិទ្ធិមនុស្សកម្រិតអន្តរជាតិនិងកម្រិតតំបន់ទាំងអស់ខាងលើនេះអាចយកមកប្រើប្រាស់សម្រាប់ស្វែងរកសំណងដោយសារការរំលោភបំពានលើសិទ្ធិមនុស្ស ក៏ប៉ុន្តែការស្វែងរកសំណងបែបនេះមិនអាចផ្តល់ជូនដល់ជនរងគ្រោះបានទាំងស្រុងទេ ពោលគឺអាស្រ័យទៅលើលទ្ធភាពនៃការអនុវត្តលិខិតូបករណ៍ច្បាប់នេះក្នុងការដោះស្រាយបញ្ហាសំណងចំពោះមុខស្ថាប័នសិទ្ធិមនុស្សនានាដែលមានសមត្ថកិច្ចរៀងៗខ្លួន ។

**ក) ស្ថាប័នអង្គការសហប្រជាជាតិ**

**ក១) តុលាការយុត្តិធម៌អន្តរជាតិ**

តុលាការយុត្តិធម៌អន្តរជាតិគឺជាស្ថាប័នយុត្តិធម៌សំខាន់មួយរបស់អង្គការសហប្រជាជាតិក្នុងការស្វែងរកនីតិវិធីដែលជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្សអាច ឬមិនអាចរៀបចំពាក្យបណ្តឹងទៅតុលាការដើម្បីស្វែងរកសំណង ។ ទាក់ទិននឹងតម្រូវការឲ្យឈរនៅចំពោះមុខតុលាការ មានតែជនរងគ្រោះជាដើមបណ្តឹងដែលជាភាគីរដ្ឋទេទើបអាចរៀបចំពាក្យបណ្តឹងមុនពេលមានតុលាការយុត្តិធម៌អន្តរជាតិ ។ ប្រការសំខាន់ដំបូងនេះគឺការស្វែងយល់ថាតើមានតែភាគីរដ្ឋទេឬដែលអាចរៀបចំពាក្យបណ្តឹងមុនពេលមានតុលាការយុត្តិធម៌អន្តរជាតិ ។ ការរៀបចំពាក្យបណ្តឹងនេះត្រូវមានការយល់ព្រមពីភាគីទាំងឡាយដែលពាក់ព័ន្ធនឹងរឿងក្តីនេះដែរ ។

សំណួរបន្ទាប់គឺថា តើតុលាការយុត្តិធម៌អន្តរជាតិអាចពិនិត្យសើរើពាក្យបណ្តឹងការរំលោភសិទ្ធិមនុស្សបានដែរឬទេ ។ ក្នុងមាត្រា៣៦ នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិចែងអំពីដែនយុត្តាធិការរបស់តុលាការយុត្តិធម៌អន្តរជាតិបញ្ជាក់ថា ករណីរំលោភបំពានលើសិទ្ធិមនុស្សបែបនេះគឺស្ថិតនៅក្រោមដែនយុត្តាធិការរបស់តុលាការយុត្តិធម៌អន្តរជាតិ ដោយហេតុផលថា ករណីទាំងឡាយដែលពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្សបែបនេះមានចែងនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ ឬនៅក្នុងសន្ធិសញ្ញានិងអនុសញ្ញានានាដែលចូលជាធរមាន” ។ ជាក់ស្តែង ចាប់តាំងពីពេលដែលតុលាការយុត្តិធម៌នេះត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៤៦ យ៉ាងហោចណាស់មានសាលក្រម២ក្នុងចំណោមសាលក្រម៧៣ដែលចេញដោយតុលាការ លើកឡើងអំពីបរិបទសិទ្ធិមនុស្សគឺ“សិទ្ធិជ្រកកោន” និង “សិទ្ធិសុំឆ្លងកាត់និងសិទ្ធិសេដ្ឋកិច្ច” ។

ប្រសិនបើតុលាការរកឃើញថាមានការរំលោភបំពានលើសិទ្ធិមនុស្សមែននោះ តុលាការយុត្តិធម៌អន្តរជាតិអាចចេញសាលក្រមទៅឲ្យជនរងគ្រោះ ។ សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោបានដាក់ពាក្យបណ្តឹងទៅតុលាការយុត្តិធម៌អន្តរជាតិប្រឆាំងនឹងរាជាណាចក្របែលហ្សិក អំពីដីកាចាប់ខ្លួនរដ្ឋមន្ត្រីការបរទេសនៃប្រទេសកុងហ្គោ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០០០។ ជាលទ្ធផល តុលាការនេះបានរកឃើញថាមានការរំលោភបំពានលើសិទ្ធិរបស់រដ្ឋមន្ត្រីការបរទេសម្នាក់នេះ និងវិនិច្ឆ័យទៅលើសំណង “ជម្ងឺចិត្ត” ដោយសម្រេចថា “ប្រទេសបែលហ្សិកត្រូវតែលុបចោល ដីកាចាប់ខ្លួនរដ្ឋមន្ត្រីការបរទេសនៃប្រទេសកុងហ្គោ និងជូនព័ត៌មានដល់អាជ្ញាធរដែលពាក់ព័ន្ធ ។ ម្យ៉ាងទៀត ប្រទេសអង់គ្លេសបានដាក់ពាក្យបណ្តឹងទៅតុលាការប្រឆាំងនឹងប្រទេសអាល់បានីទាក់ទិននឹងការស្វែងរកសំណងជំងឺចិតអំពីបន្ទុះគ្រាប់ដែលបង្កឲ្យមានការខូចខាតសម្ភារៈ និងការបាត់បង់អាយុជីវិតមនុស្ស ។

សេចក្តីសម្រេចរបស់តុលាការយុត្តិធម៌អន្តរជាតិមានសារសំខាន់នៅក្នុងក្របខ័ណ្ឌតុលាការនេះ ។ សេចក្តីសម្រេចនេះចាំបាច់ត្រូវអនុវត្តដោយភាគីរដ្ឋនៃរឿងក្តីនិងដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិដូចមានចែងក្នុងមាត្រា៩៤(២) ក្នុងធម្មនុញ្ញថា ÷

*ប្រសិនបើភាគីបណ្តឹងណាមួយមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនតាមសាលក្រមចេញដោយតុលាការនោះទេ ភាគីបណ្តឹងមួយ*

ទៀត អាចស្នើសុំក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិផ្តល់អនុសាសន៍ ឬធ្វើសេចក្តីសម្រេចលើវិធានការដើម្បីធ្វើឲ្យសាលក្រមនេះមានប្រសិទ្ធភាពប្រសិនបើចាំបាច់ ។

ដោយពិចារណាលើទស្សនៈស្តីអំពីក្របខ័ណ្ឌតុលាការនេះ ខ្លឹមសារនៃបណ្តឹងមិនមែនជាបញ្ហានោះទេ ប៉ុន្តែបញ្ហាគឺការឈរចំពោះមុខតុលាការទៅវិញ ព្រោះថាជនរងគ្រោះនឹងមិនអាចឈរចំពោះមុខគ្រប់ៗគ្នាបានទេ ។ បើទោះបីជាជនរងគ្រោះអាចឈរចំពោះមុខតុលាការបានក៏ដោយ "ជារឿយៗ លទ្ធផលដែលទទួលបានពីរឿងក្តីទាំងនេះអាចនឹងប៉ះពាល់ដោយប្រយោលដល់ស្ថានភាពជនរងគ្រោះម្នាក់ៗ" ។

បន្ទាប់ពីបរាជ័យក្នុងការស្វែងរកសំណងសម្រាប់ការរំលោភបំពានសិទ្ធិមនុស្សដែលបន្សល់ទុកពីតុលាការយុត្តិធម៌អន្តរជាតិ កិច្ចខិតខំប្រឹងប្រែងក្នុងស្វែងរកសំណងផ្លាស់ប្តូរទៅតាមរយៈស្ថាប័នផ្សេងៗ និងយន្តការនានាដែលផ្អែកលើសន្ធិសញ្ញាក្រោមការគ្រប់គ្រងរបស់អង្គការសហប្រជាជាតិ មានដូចជាគណៈកម្មការសិទ្ធិមនុស្ស គណៈកម្មាធិការសិទ្ធិមនុស្ស គណៈកម្មាធិការប្រឆាំងអំពើទារុណកម្ម និងគណៈកម្មាធិការការលុបបំបាត់ការរើសអើងពូជសាសន៍ ។

## ក២) គណៈកម្មការស្តីអំពីសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ

ស្ថាប័នដោះស្រាយបញ្ហាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិដែលត្រូវបានស្គាល់ថាជាគណៈកម្មការស្តីអំពីសិទ្ធិមនុស្ស បង្កើតឡើងដោយក្រុមប្រឹក្សាសង្គមនិងសេដ្ឋកិច្ចក្នុងគោលបំណងត្រួតពិនិត្យនិងធ្វើសេចក្តីរាយការណ៍ជាសាធារណៈអំពីស្ថានភាពនៃការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងររបស់រដ្ឋ ជាសមាជិកមួយដែលតម្រូវឲ្យមានការឆ្លើយតបភ្លាមៗ ។ តួនាទីក្នុងការត្រួតពិនិត្យនិងធ្វើសេចក្តីរាយការណ៍ពីបញ្ហានេះរបស់គណៈកម្មការស្តីអំពីសិទ្ធិមនុស្សត្រូវធ្លាក់បន្ទុកទៅលើ"បេសកជនពិសេស អ្នកជំនាញឯករាជ្យ តំណាងពិសេស និងសមាជិកក្រុមការងារ ដើម្បីបំពេញការងារអំពីប្រទេសឬប្រធានបទជាក់លាក់ណាមួយ" ។ ក្រុមការងារនីមួយៗមានអាណត្តិរៀងៗខ្លួន ។

តាមសេចក្តីសម្រេចលេខ១៩៨៥/៣៣និង១៩៩២/៧២ គណៈកម្មការស្តីអំពីសិទ្ធិមនុស្ស បានចាត់បេសកជនពិសេសជាបន្តបន្ទាប់ឲ្យដោះស្រាយបញ្ហាលើទម្រង់ណាមួយនៃការឃុំខ្លួន ឬការដាក់គុកជាពិសេសការធ្វើទារុណកម្មនិងការផ្តន្ទាទោស ឬ



កន្លែងសួរចម្លើយដោយព្យួរជនរងគ្រោះ

បង្គោលប្រមទាំងខ្សែពួរនេះសម្រាប់សិស្សានុសិស្សអនុវត្តការហាត់ប្រាណ ។ ពួកខ្មែរក្រហមបានប្រើប្រាស់កន្លែងនេះជាកន្លែងសួរចម្លើយជនរងគ្រោះ ។ អ្នកសួរចម្លើយបានចងដៃទាំងពីរនៃជនរងគ្រោះទៅខាងក្រោយខ្នងទៅនិងខ្សែពួរហើយនាំគ្នាទាញទៅលើទម្លាក់ចុះឡើងជាច្រើនសាររហូតជនរងគ្រោះសន្លប់បាត់ស្មារតី ។ បន្ទាប់មក ពួកវាបានជ្រមុជក្បាលជនរងគ្រោះទៅក្នុងពាងទឹកស្អុយដែលពួកវាបានប្រើប្រាស់ជាជីសម្រាប់ការដាំដំណាំនៅវាលខាងក្រៅ ។ ពួកវាធ្វើដូច្នេះ ដើម្បីធ្វើឲ្យជនរងគ្រោះមានស្មារតីឡើងពីសន្លប់វិញដើម្បីពួកវាបានសួរចម្លើយបន្តទៅទៀត ។

(សេចក្តីពន្យល់នៅលើផ្ទាំងប៉ាណូ)

ការប្រព្រឹត្តឃោរឃៅអមនុស្សធម៌ ឬដែលនាំឲ្យបាត់បង់តម្លៃជាមនុស្សនិងទម្រង់នៃការកាត់ទោសក្រៅច្បាប់ភ្លាមៗនិងតាមអំពើចិត្ត" ។ គណៈកម្មការនេះបានបង្កើតក្រុមការងារតាមសេចក្តីសម្រេចលេខ១៩៩៧/២៦ ដោយដោះស្រាយបញ្ហាទម្រង់នៃការឃុំខ្លួន ការចាប់ដាក់គុក និងការបាត់ខ្លួនដោយអចេតនានិងបង្ខំ ។

បើពិនិត្យមើលលក្ខខណ្ឌសំណងចំពោះការរំលោភបំពានលើសិទ្ធិមនុស្ស សំណងទាំងឡាយអាចនឹងដោះស្រាយបញ្ហាការរំលោភបំពានសិទ្ធិមនុស្សតាមការកំណត់ពេលវេលារៀងៗខ្លួន ។ តាមសេចក្តីសម្រេចរបស់ខ្លួនលេខ១៩៨៥/៣៣ គណៈកម្មការស្តីអំពីសិទ្ធិមនុស្សបានចាត់តាំងបេសកជនពិសេសម្នាក់ឲ្យទៅដោះស្រាយបញ្ហាការធ្វើទារុណកម្ម ។ ក្រោយមកទៀត គណៈកម្មការនេះសម្រេចពន្យារអាណត្តិឲ្យបេសកជនពិសេសរូបនេះ ដោយសេចក្តីសម្រេចលេខ១៩៩២/៣២ ។ បេសកជនពិសេសត្រូវអនុវត្តអាណត្តិពន្យាររបស់ខ្លួន ដោយខិតខំ"ស្វែងរកនិងទទួល"ព័ត៌មានអំពីទិដ្ឋភាពផ្សេងៗនៃអំពើទារុណកម្មនិងការផ្តន្ទាទោសឬការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅអមនុស្សធម៌ឬដែលនាំឲ្យបាត់បង់តម្លៃជាមនុស្ស ដែលបានមកពី"រដ្ឋាភិបាលនានា ទីភ្នាក់ងារឯកទេស ព្រមទាំងអង្គការអន្តររដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ។"

លទ្ធផលសំខាន់ៗដែលទទួលបានទាំងប៉ុន្មាន បេសកជនពិសេសត្រូវធ្វើសេចក្តីរាយការណ៍ចុងក្រោយជូនគណៈកម្មការស្តីអំពីសិទ្ធិមនុស្ស ដោយធ្វើសេចក្តីសន្និដាននិងផ្តល់អនុសាសន៍លើបញ្ហានេះ ។ តាមរយៈការសន្និដ្ឋាននិងអនុសាសន៍នេះ សំណងដែលត្រូវបានរាប់បញ្ចូលរួមមាន"ជនរងគ្រោះដែលពុំទាន់ទទួលបាននូវការជួសជុលសំណងដែលមានប្រសិទ្ធភាពនិងសំណងសមរម្យណាមួយនោះ" និង"ជនរងគ្រោះដែលមានសិទ្ធិដាក់បណ្តឹងដែលត្រូវស៊ើបអង្កេតឲ្យទៀងទាត់និងមិនលម្អៀង ដោយអាជ្ញាធរដែលមានសមត្ថកិច្ច ហើយដែលជនរងគ្រោះទាំងនេះមានសិទ្ធិទទួលបានសំណងដ៏សមរម្យ" ។ ដូចដែលលោកស្រីសាស្ត្រាចារ្យ ឌីណា ស្វែលតុន បានកត់សម្គាល់ក្នុងសៀវភៅរបស់លោកស្រីដែលមានចំណងជើងថា "ការជួសជុលសំណងក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ" បេសកជនពិសេស "កម្រនឹងពិភាក្សាអំពីសំណងសម្រាប់ជនរងគ្រោះ... កម្រនឹងស្នើសុំឲ្យរដ្ឋាភិបាលពិនិត្យដោះស្រាយបញ្ហានេះណាស់ ប្រសិនបើលទ្ធផលនៃការស៊ើបសួរបញ្ជាក់ថាការចោទប្រកាន់ពិតជាមានមែននោះ ជនដៃដល់នឹងត្រូវបានផ្តន្ទាទោស ហើយជនរងគ្រោះនឹងត្រូវបានសំណងជំងឺចិត្ត" ។

នៅក្នុងឆ្នាំ១៩៩២ គណៈកម្មការសិទ្ធិមនុស្សបានចាត់តាំងបេសកជនពិសេសម្នាក់ទៀតឲ្យបំពេញការងារលើករណីកាត់ទោសបន្ថែមក្រៅច្បាប់ភ្លាមៗនិងតាមអំពើចិត្ត ។ ក្របខណ្ឌនេះមិនខុសពីការប្រមូលព័ត៌មានពីរដ្ឋាភិបាល បុគ្គល និងអង្គការសិទ្ធិមនុស្សនានាដែលមានជំនាញ ។ មានប្រភពព័ត៌មានដ៏ច្រើនស្តីអំពីការរំលោភបំពានលើសិទ្ធិរស់រានមានជីវិតដែលបេសកជននេះអាចទទួលបាន ។ តាមរយៈសេចក្តីសន្និដ្ឋាននិងអនុសាសន៍នេះ បេសកជនពិសេសអាច"អំពាវនាវសុំឲ្យអាជ្ញាធរដែលមានសមត្ថកិច្ចដើម្បីធានាឲ្យមានការគោរពនិងអនុវត្តន៍បទដ្ឋានអន្តរជាតិដែលធានាសិទ្ធិរស់រានមានជីវិតសម្រាប់ជនគ្រប់រូប" ឬ"អំពាវនាវសុំឲ្យរដ្ឋាភិបាលដែលមានកាតព្វកិច្ចក្នុងការធានាសិទ្ធិរស់រានមានជីវិតយ៉ាងមានប្រសិទ្ធភាពនិងការពារញាតិសន្តានរបស់ជនរងគ្រោះដោយសារការរំលោភបំពានលើសិទ្ធិមនុស្ស ។"

បេសកជនពិសេសដែលទទួលបន្ទុកលើការកាត់ទោសក្រៅច្បាប់ភ្លាមៗនិងតាមអំពើចិត្ត ពុំមានជំហរច្បាស់លាស់ណាមួយឡើយ ដោយហេតុថា "បេសកជនពិសេសនេះទទួលបានព័ត៌មានតិចតួចបំផុតអំពីសំណងដែលបានផ្តល់ជូនទៅក្រុមគ្រួសារជនរងគ្រោះដោយសារការកាត់ទោសក្រៅច្បាប់ភ្លាមៗនិងតាមអំពើចិត្ត..." ទោះបីជាយ៉ាងក៏ដោយ បេសកជននេះបានត្រឹមតែ "អំពាវនាវសុំឲ្យរដ្ឋាភិបាលទាំងអស់ដែលជាប់ទាក់ទិនអនុវត្តទៅតាមបទដ្ឋាននិងគោលការណ៍ទាំងឡាយដែលមាននៅក្នុងលិខិតូបករណ៍ច្បាប់អន្តរជាតិពាក់ព័ន្ធប៉ុណ្ណោះ ។"

ក្រុមការងាររបស់គណៈកម្មាធិការសិទ្ធិមនុស្សមានកាតព្វកិច្ចនិងកិច្ចការដូចទៅនឹងកាតព្វកិច្ចនិងកិច្ចការរបស់បេសកជនពិសេស បើទោះបីជាមានភាពខុសគ្នាលើទំនាក់ទំនងរវាងជនរងគ្រោះនិងរដ្ឋជាសមាជិកដែលពាក់ព័ន្ធក៏ដោយ ។ ក្រុមការងារនេះទទួលបន្ទុកលើការបាត់ខ្លួនដោយអចេតនាឬដោយបង្ខំ និងត្រូវបាន

បង្កើតឡើងនៅក្នុងឆ្នាំ១៩៨០ ឆ្លើយតបទៅនឹងបញ្ហាបាត់ខ្លួននៅលើពិភពលោក ។ ក្រុមការងារនេះនៅបន្តកិច្ចការរបស់ខ្លួនស្រប ទៅតាមពេលកំណត់ដែលគណៈកម្មការសិទ្ធិមនុស្សបានផ្ដល់ឲ្យ តាមសេចក្ដីសម្រេចលេខ១៩៩៧/២៦ ។

ទាក់ទិននឹងសំណងជនរងគ្រោះ ក្រុមការងារបានធ្វើសេចក្ដីសន្និដ្ឋាននិងផ្ដល់អនុសាសន៍ខុសៗគ្នា ។ ក្រុមនេះបានអះអាងថា "ក្នុងកិច្ចព្រមព្រៀងជាមួយក្រុមគ្រួសារជនរងគ្រោះដែលបាត់ខ្លួន យន្តការទាំងឡាយអាចនឹងត្រូវបានយកមកពិនិត្យពិច័យដើម្បីបញ្ជាក់ឲ្យកាន់តែច្បាស់ចំពោះរឿងក្ដីនេះ ដោយរាប់បញ្ចូលការយល់ដឹងអំពីការទទួលខុសត្រូវនៃរដ្ឋជាសមាជិកនិងការបង្កើតសំណងជំងឺចិត្តសមរម្យ ។ នៅក្នុងទំនាក់ទំនងនេះ ក្រុមនេះត្រៀមខ្លួនជាស្រេចសហការជាមួយភាគីទាំងឡាយដែលជាប់ពាក់ព័ន្ធ ។

សេចក្ដីសន្និដ្ឋានទីពីររបស់ក្រុមនេះលើបញ្ហាការបាត់ខ្លួនដដែល ទំនងជាមានភាពច្បាស់លាស់ជាងមុន ដោយនិយាយថា "ក្រុមការងារនេះអាចជួយដោះស្រាយរឿងក្ដីដោយសារតែសេចក្ដីប្រកាសរបស់តុលាការដែលសន្មតថាជនដែលបាត់ខ្លួននោះបានស្លាប់ទៅហើយ ។ ការសន្មតត្រូវមានការយល់ពីក្រុមគ្រួសាររបស់ជនរងគ្រោះ និងត្រូវមានសំណងជំងឺចិត្តដល់ក្រុមគ្រួសាររបស់ជនរងគ្រោះដែរ ។"

ហេតុដូច្នេះហើយ របាយការណ៍ដែលបានមកពីកិច្ចការរបស់បេសកជនពិសេសនិងក្រុមការងារនឹងត្រូវប្រគល់ទៅឲ្យគណៈកម្មការស្ដីពីសិទ្ធិមនុស្ស បន្ទាប់មកប្រគល់ជូនក្រុមប្រឹក្សាសង្គមនិងសេដ្ឋកិច្ចនិងជាចុងក្រោយបញ្ជូនទៅឲ្យមហាសន្និបាតអង្គការសហប្រជាជាតិឲ្យអង្គមហាសន្និបាតបោះឆ្នោតសម្រេចលើបញ្ហាដែលមាននៅក្នុងរបាយការណ៍ ។

នៅក្នុងប្រព័ន្ធច្បាប់របស់អង្គការសហប្រជាជាតិ ទាក់ទិននឹងសន្ធិសញ្ញាសំខាន់ៗស្ដីអំពីសិទ្ធិមនុស្ស គណៈកម្មាធិការជាច្រើនត្រូវបានបង្កើតក្រោមឈ្មោះថាជាសន្ធិសញ្ញាស្ដីអំពីសិទ្ធិមនុស្ស ។ គណៈកម្មាធិការនីមួយៗត្រូវដោះស្រាយបញ្ហាសិទ្ធិដែលមានចែងនៅក្នុងសន្ធិសញ្ញា ។ មានន័យថា គណៈកម្មាធិការដែលផ្អែកលើសន្ធិសញ្ញាទាំងនេះបានបង្កើតនូវនីតិវិធីជាអន្តរជាតិរបស់ខ្លួនទាក់ទិននឹងប្រព័ន្ធច្បាប់ក្នុងស្រុកដើម្បីការពារសុវត្ថិភាពបុគ្គលម្នាក់ៗព្រមទាំងធានាដល់ការអនុវត្តនូវកាតព្វកិច្ចដែលមាននៅក្នុងសន្ធិសញ្ញាសម្រាប់រដ្ឋជាសមាជិក ។

### ក៣) គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ

យន្តការទីមួយគឺគណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ។ គណៈកម្មាធិការនេះត្រូវបានបង្កើតដោយអនុលោមទៅតាមមាត្រា២៨នៃកតិកាសញ្ញាអន្តរជាតិស្ដីអំពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ដើម្បី "សិក្សារបាយការណ៍ដែលភាគីរដ្ឋដាក់ជូនកតិកាសញ្ញាថ្មីនេះពិនិត្យ" ។ គណៈកម្មាធិការសិទ្ធិមនុស្សមានសិទ្ធិអំណាចទទួលនិងពិចារណាទំនាក់ទំនងពីបុគ្គលក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ព្រោះថាបុគ្គលទាំងនេះប្រកាសថាខ្លួនជាជនរងគ្រោះដែលត្រូវរដ្ឋរំលោភបំពានសិទ្ធិ ហើយសិទ្ធិនោះមានចែងក្នុងកតិកាសញ្ញាអន្តរជាតិថែមទៀត" ។ តម្រូវការសំខាន់គឺអាស្រ័យទៅលើថាតើភាគីរដ្ឋព្រមទទួលស្គាល់សមត្ថភាពរបស់គណៈកម្មាធិការសិទ្ធិមនុស្សនិងព្រមទទួលស្គាល់ថាខ្លួនក៏ជាសមាជិកនៃពិធីសារបន្ថែមនៃកតិកាសញ្ញានេះដែរឬទេ ។

ដូចមានសង្ខេបក្នុងសៀវភៅរបស់លោកស្រីសាស្ត្រាចារ្យ ស្វែរលគុន គណៈកម្មាធិការសិទ្ធិមនុស្សមានសិទ្ធិសម្រេចបញ្ហាសំណងជំងឺចិត្ត ឬសំណងទ្រព្យសម្បត្តិចំពោះជនរងគ្រោះដោយសារការរំលោភបំពានសិទ្ធិមនុស្ស ដោយយោងតាមមាត្រា២កថាខណ្ឌ៣(ក) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ។ មាត្រា២ចែងថា "បុគ្គលម្នាក់ដែលសិទ្ធិនិងសេរីភាពរបស់ខ្លួនត្រូវរំលោភបំពាន ត្រូវតែទទួលបាននូវការជួសជុលជាសំណងប្រកបដោយប្រសិទ្ធភាព" ។

តាមការយល់ឃើញរបស់គណៈកម្មាធិការសិទ្ធិមនុស្ស ចំពោះគំនិតជាច្រើន (ស្ដីអំពីទោសប្រហារជីវិត) ទាក់ទិននឹងការរំលោភសិទ្ធិដែលមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិ ។ កតិកាសញ្ញាអន្តរជាតិបានសម្រេចថា "ក្នុងមាត្រា២កថាខណ្ឌ៣(ក) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ជនរងគ្រោះមានសិទ្ធិទទួលបានសំណងជំងឺចិត្តប្រកបដោយប្រសិទ្ធភាព... អ្នកផ្ដើមគំនិតមានសិទ្ធិទទួលសំណងជំងឺចិត្ត..." ។ ទាក់ទិននឹងខទាំងឡាយស្ដីអំពីសំណងដែលមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិ គណៈកម្មាធិការសិទ្ធិមនុស្សនៅតែយោងលើមាត្រា២កថាខណ្ឌ

៣(ក) ដោយភ្ជាប់ជាមួយនឹងខទាំងឡាយសម្រាប់វិនិច្ឆ័យលើបញ្ហាសំណងចំពោះជនរងគ្រោះ ។ នៅក្នុងបទបញ្ញត្តិផ្សេងទៀត គណៈកម្មាធិការសិទ្ធិមនុស្សមិនមានសិទ្ធិសម្រេចផ្តល់សំណងជំងឺចិត្តឡើយ ប៉ុន្តែមានសិទ្ធិសម្រេចផ្តល់ការព្យាបាលសមរម្យជាការជួសជុលលើសំណងប្រកបដោយប្រសិទ្ធភាពដល់ជនរងគ្រោះដោយសារការរំលោភសិទ្ធិមនុស្សតែមួយ ។ ក្នុងទស្សនៈខ្លះ គណៈកម្មាធិការសិទ្ធិមនុស្សនៅបន្តសង្កត់ធ្ងន់ថា "ភាគីរដ្ឋមានកាតព្វកិច្ចធានាថា ការរំលោភបំពានស្រដៀងនេះនឹងមិនកើតឡើងជាថ្មីម្តងទៀតនៅពេលអនាគត ។"

យោងតាមមាត្រា៥(៤)នៃពិធីសារបន្ថែមនេះ ទស្សនៈរបស់គណៈកម្មាធិការសិទ្ធិមនុស្សសំដៅយកទាំងភាគីរដ្ឋជាសមាជិកនិងជនរងគ្រោះម្នាក់ៗ ដោយរាប់បញ្ចូលសំណងជំងឺចិត្ត ។ ការអនុវត្តតាមទស្សនៈយល់ឃើញរបស់គណៈកម្មាធិការសិទ្ធិមនុស្សអំពីបញ្ហាសំណងជាទ្រព្យសម្បត្តិនិងសំណងជំងឺចិត្តដល់ជនរងគ្រោះនៅតែជួបបញ្ហា ពីព្រោះបញ្ហានេះបានផ្តល់រយៈពេល៩០ថ្ងៃដល់ភាគីរដ្ឋឲ្យផ្តល់ព័ត៌មានត្រឡប់មកវិញជូនគណៈកម្មាធិការសិទ្ធិមនុស្សដើម្បីចាត់វិធានការឲ្យមានប្រសិទ្ធភាព ។ ដូចដែលលោកស្រី សៀនលីស អេនថូនី បានរៀបរាប់នៅក្នុងអត្ថបទមួយក្រោមចំណងជើងថា "នីតិវិធីផ្អែកលើសន្ធិសញ្ញាសម្រាប់រៀបចំពាក្យបណ្តឹងសិទ្ធិមនុស្សនៅក្នុងប្រព័ន្ធច្បាប់អង្គការសហប្រជាជាតិ"ថា ÷

តាមលក្ខណៈបច្ចេកទេស ទស្សនៈចុងក្រោយរបស់គណៈកម្មាធិការសិទ្ធិមនុស្សពុំមានលក្ខណៈបង្ខំទេ ។ គ្មានការផ្តន្ទាទោសណាមួយទៅលើរដ្ឋដែលត្រូវបានរកឃើញថាបានរំលោភបំពានកតិកាសញ្ញានេះទេ ។ តាមការពិត រឿងក្តីភាគច្រើនភាគីរដ្ឋមិនបានកត់សម្គាល់អំពីទស្សនៈរបស់គណៈកម្មាធិការសិទ្ធិមនុស្សឡើយ ។ ហេតុដូច្នេះហើយ បញ្ហាអំណាចរបស់គណៈកម្មាធិការសិទ្ធិមនុស្សក្លាយជាប្រធានបទពិភាក្សា បើកាលណាទស្សនៈរបស់ខ្លួនត្រូវបានបញ្ជូនទៅឲ្យរដ្ឋជាសមាជិកដែលជាប់ពាក់ព័ន្ធនោះ ។

ដូចនេះ គណៈកម្មាធិការសិទ្ធិមនុស្សត្រូវរៀបចំនីតិវិធីតាមដានពិនិត្យដោយភ្ជាប់ជាមួយ ទស្សនៈរបស់ខ្លួនដើម្បីឲ្យដឹងច្បាស់ថា ភាគីរដ្ឋពិតជាអនុលោមទៅតាមសេចក្តីសម្រេចរបស់ខ្លួនដូចចែងក្នុងច្បាប់៩៥(១)ថា "គណៈកម្មាធិការសិទ្ធិមនុស្សត្រូវចាត់បេសកជនពិសេសម្នាក់មកពិនិត្យទស្សនៈដែលអនុម័តក្រោមមាត្រា៥ កថាខណ្ឌ៤នៃពិធីសារបន្ថែមក្នុងគោលបំណងឲ្យដឹងច្បាស់វិធានការដែលចាត់ដោយភាគីរដ្ឋដើម្បីធ្វើឲ្យទស្សនៈនេះមានប្រសិទ្ធភាព" ។ ទោះបីជាយ៉ាងណាក៏ដោយ បញ្ហាអនុវត្តទស្សនៈរបស់គណៈកម្មាធិការសិទ្ធិមនុស្សនេះកំពុងតែកើតមានឡើងហើយ ដោយហេតុថាចម្លើយរបស់ភាគីរដ្ឋមិនមានភាពច្បាស់លាស់ "ចម្លើយខ្លះមិនបានបង្ហាញពីការអះអាងបញ្ជាក់របស់គណៈកម្មាធិការសិទ្ធិមនុស្ស ចម្លើយខ្លះទៀតបង្ហាញថាជនរងគ្រោះមិនបានប្តឹងទាមទារសំណងជំងឺចិត្ត ហើយក៏គ្មានសំណងណាមួយត្រូវបានសងដែរ ។

### ក៤) គណៈកម្មាធិការលុបបំបាត់ការប្រកាន់ពូជសាសន៍របស់អង្គការសហប្រជាជាតិ

យន្តការទីពីរគឺគណៈកម្មាធិការលុបបំបាត់ការប្រកាន់ពូជសាសន៍ ។ ក្រោមមាត្រា៨នៃអនុសញ្ញាអន្តរជាតិស្តីអំពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ គណៈកម្មាធិការនេះត្រូវបានបង្កើតឡើងដើម្បីពិចារណាអំពីទំនាក់ទំនងរវាងរដ្ឋជាសមាជិកក្រោមមាត្រា១១ និងពិចារណាអំពីទំនាក់ទំនងជាបុគ្គលដោយផ្អែកលើសេចក្តីប្រកាសបន្ថែមក្រោមមាត្រា១៤នៃអនុសញ្ញាអន្តរជាតិនេះ ។

ក្នុងរឿងក្តីរវាង អិលខេ (LK) និងប្រទេសហុល្លង់ គណៈកម្មាធិការនេះបានស្នើឲ្យមានសំណងដល់ជនរងគ្រោះដោយសារការរំលោភបំពានលើសិទ្ធិមនុស្សក្នុងលក្ខណៈរើសអើងពូជសាសន៍ ដោយហេតុផលថា "នៅពេលណាមានការគំរាមកំហែងរំលោភបំពានលើពូជសាសន៍ និងជាពិសេសនៅពេលណាដែលការគំរាមកំហែងនេះត្រូវបានធ្វើឡើងជាសាធារណៈនិងដោយក្រុមមួយគឺភាគីរដ្ឋមានភារៈស៊ើបអង្កេតដោយចុះបេសកកម្មនិងខិតខំប្រឹងប្រែងឲ្យអស់ពីសមត្ថភាពទៅតាមពេលវេលាកំណត់" ។ ដោយពិនិត្យឃើញថាចម្លើយមិនមានភាពត្រឹមត្រូវចំពោះការប្រកាន់ពូជសាសន៍ដោយរដ្ឋ និងដោយយោងតាមមាត្រា៦នៃអនុសញ្ញាអន្តរជាតិនេះ គណៈកម្មាធិការសិទ្ធិមនុស្សអាចស្នើឲ្យភាគីរដ្ឋសងទៅម្ចាស់បណ្តឹងស្មើនឹងការខូចខាតសតិបញ្ញាដែលម្ចាស់បណ្តឹងទទួលរង" ។ ទោះបីជាយ៉ាងណាក៏ដោយ គណៈកម្មាធិការសិទ្ធិមនុស្ស

មិនបានបង្កើតសំណងដល់ជនរងគ្រោះដោយចាត់ទុកថាជាការជួសជុលសំណងប្រកបដោយប្រសិទ្ធភាពតាមមាត្រា៦នៃអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ដែលខូះភ័ស្តុតាងពីជនរងគ្រោះ ។

**ក៥) គណៈកម្មាធិការប្រឆាំងអំពើទារុណកម្មរបស់អង្គការសហប្រជាជាតិ**

យន្តការទីបី គឺគណៈកម្មាធិការប្រឆាំងអំពើទារុណកម្ម ។ ដោយយោងលើមាត្រា១៧នៃអនុសញ្ញាប្រឆាំងអំពើទារុណកម្ម និងការផ្តន្ទាទោសឬការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅអមនុស្សធម៌ឬដែលនាំឲ្យបាត់បង់តម្លៃជាមនុស្ស គណៈកម្មាធិការប្រឆាំងនឹងអំពើទារុណកម្មអាចពិចារណាគំនិតដោះដូរគ្នារវាងភាគីរដ្ឋក្នុងពេលណាមួយក៏បាន ព្រោះភាគីរដ្ឋទាំងនោះទទួលស្គាល់ថា គណៈកម្មាធិការប្រឆាំងអំពើទារុណកម្មមានលទ្ធភាពដោះស្រាយបញ្ហានេះ ក្នុងករណីដែលភាគីរដ្ឋមួយផ្សេងទៀតមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនក្រោមអនុសញ្ញាប្រឆាំងអំពើទារុណកម្ម ។

ដូចនឹងគណៈកម្មាធិការពីរដែលបានរៀបរាប់ខាងលើ គណៈកម្មាធិការប្រឆាំងអំពើទារុណកម្មអាចពិចារណាគំនិតរបស់បុគ្គលម្នាក់ៗដែលប្រកាសថាជាជនរងគ្រោះដោយសារការរំលោភបំពានសិទ្ធិដែលមានចែងក្នុងអនុសញ្ញាប្រឆាំងអំពើទារុណកម្ម ។ គណៈកម្មាធិការប្រឆាំងនឹងអំពើទារុណកម្មមិនផ្អែកលើបទចោទប្រកាន់អំពើទារុណកម្មជាប្រព័ន្ធ ឬរឿងក្តីទាំងឡាយរបស់បុគ្គលម្នាក់ៗ ។ ក្រោមមាត្រា២០(១)នៃអនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្ម គណៈកម្មាធិការនេះនឹងចាប់ផ្តើមស៊ើបអង្កេតដោយខ្លួនឯងផ្ទាល់ ប្រសិនបើខ្លួនទទួលបានព័ត៌មានដែលអាចជឿទុកចិត្តបានដែលស្តែងឲ្យឃើញថាមានការប្រព្រឹត្តអំពើទារុណកម្មជាប្រព័ន្ធនៅលើទឹកដីនៃភាគីរដ្ឋជាសមាជិកណាមួយនោះ ។

ម្យ៉ាងវិញទៀត ក្រោមមាត្រា២០(១)នៃអនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្ម រដ្ឋត្រូវ"សហការពិនិត្យព័ត៌មាននិងបញ្ជូនសេចក្តីពន្យល់សង្ខេបព័ត៌មាននេះ" ទៅឲ្យគណៈកម្មាធិការប្រឆាំងនឹងអំពើទារុណកម្ម ។ ទោះបីជាអនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្មបានចែងនូវបទបញ្ញត្តិស្តីអំពីសិទ្ធិទទួលបានសំណងដោយសារការធ្វើទារុណកម្មក៏ដោយ គណៈកម្មាធិការប្រឆាំងនឹងអំពើទារុណកម្មកម្រនឹងមានឱកាសដោះស្រាយបញ្ហាសំណងដែលមាននៅក្នុងពាក្យបណ្តឹងមុនអនុសញ្ញានេះ ។

មានអង្គការកំពូលពីរទៀតរបស់អង្គការសហប្រជាជាតិ គឺអង្គការអប់រំវិទ្យាសាស្ត្រនិងវប្បធម៌របស់អង្គការសហប្រជាជាតិ (យូណេស្កូ) និងអង្គការពលកម្មអន្តរជាតិ ។ អង្គការទាំងពីរនេះមាននាទីដោះស្រាយបញ្ហាការរំលោភបំពានលើសិទ្ធិមនុស្ស ។

**ក៦) អង្គការអប់រំវិទ្យាសាស្ត្រនិងវប្បធម៌របស់អង្គការសហប្រជាជាតិ**

នីតិវិធីច្បាប់ឆ្នាំ១៩៧៨ដែលអនុម័តដោយក្រុមប្រឹក្សាប្រតិបត្តិនៃអង្គការអប់រំវិទ្យាសាស្ត្រនិងវប្បធម៌របស់អង្គការសហប្រជាជាតិនៅក្នុងសេចក្តីសម្រេចរបស់ខ្លួននៅឆ្នាំ១៩៧៨ អនុញ្ញាតឲ្យជនរងគ្រោះឬជនណាម្នាក់ រាប់បញ្ចូលទាំងអង្គការក្រៅរដ្ឋាភិបាលផង បញ្ជូនព័ត៌មានទាក់ទិននឹងរឿងក្តីរំលោភបំពានសិទ្ធិមនុស្សនៅក្នុងដែនសមត្ថកិច្ចរបស់អង្គការអប់រំ វិទ្យាសាស្ត្រនិងវប្បធម៌ ។

គណៈកម្មាធិការប្រឆាំងអំពើទារុណកម្មត្រូវអនុវត្តគំនិតនៅក្នុងអនុសញ្ញានិងអនុសាសន៍ទាំងឡាយ ដោយអនុលោមទៅតាមលក្ខខណ្ឌដែលមានក្នុងសេចក្តីសម្រេចឆ្នាំ១៩៧៨ ។ គណៈកម្មាធិការនេះនឹងផ្ញើរបាយការណ៍សម្ងាត់ដោយភ្ជាប់ជាមួយនូវអនុសាសន៍របស់ខ្លួនទៅឲ្យក្រុមប្រឹក្សាប្រតិបត្តិដើម្បីពិចារណា ។ ក្រុមប្រឹក្សាប្រតិបត្តិនេះត្រូវពិចារណាដោយផ្អែកលើចរិយាធម៌ និងសមត្ថភាពជាក់លាក់លើ"កិច្ចសហប្រតិបត្តិការអន្តរជាតិ ការផ្សះផ្សា និងការយោគយល់គ្នាទៅវិញទៅមក" ។ ហេតុដូចនេះហើយ អង្គការអប់រំវិទ្យាសាស្ត្រនិងវប្បធម៌របស់អង្គការសហប្រជាជាតិមិនអាចដោះស្រាយបញ្ហាសំណងសម្រាប់ជនរងគ្រោះដោយសារការរំលោភលើសិទ្ធិមនុស្សបានទេ ប៉ុន្តែរឿងក្តីរបស់ជនរងគ្រោះទាំងនោះនៅមិនទាន់ឈានទៅដល់សំណងទ្រព្យសម្បត្តិ ឬជំងឺចិត្តនៅឡើយទេ ។ ក៏ប៉ុន្តែការសម្រេចចិត្តបែបនេះគឺឈានដល់កម្រិតនៅក្នុងយន្តការរបស់អង្គការពលកម្មអន្តរជាតិ ។

**ក៧) អង្គការពលកម្មអន្តរជាតិរបស់អង្គការសហប្រជាជាតិ**

ក្រោមច្បាប់រដ្ឋធម្មនុញ្ញនៃអង្គការពលកម្មអន្តរជាតិ យន្តការ

ទទួលពាក្យបណ្តឹងដែលទាក់ទិននឹងការរំលោភលើសិទ្ធិមនុស្សត្រូវបានបង្កើតឡើងក្នុងនីតិវិធីបីខុសៗគ្នា ៖ ការបង្ហាញពីមាត្រា២៤ កាតព្វកិច្ចអនុលោមក្រោមមាត្រា២៦ និងនីតិវិធីពិសេសសម្រាប់ពាក្យបណ្តឹងស្តីអំពីសេរីភាពរបស់សមាគមន៍ដែលត្រូវបានបង្កើតឡើង ដោយកិច្ចព្រមព្រៀងរវាងអង្គការពលកម្មអន្តរជាតិនិងក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមរបស់អង្គការសហប្រជាជាតិ ។ តាមរយៈយន្តការនេះ អង្គការពលកម្មអន្តរជាតិអាចពិនិត្យកិច្ចព្រមព្រៀងរបស់រដ្ឋជាសមាជិកតាមបទដ្ឋានរបស់ខ្លួនក្នុងអនុសញ្ញានិងអនុសាសន៍ទាំងឡាយដែលមាននៅក្នុងអង្គការពលកម្មអន្តរជាតិនេះ ។

ក្នុងចំណោមនីតិវិធីទាំងបីនេះ ពាក្យបណ្តឹងសិទ្ធិមនុស្សភាគច្រើនត្រូវបានរៀបចំឡើងក្រោមនីតិវិធីពិសេសស្តីអំពីសេរីភាពរបស់សមាគមន៍ ដោយរដ្ឋាភិបាលឬអង្គការចាត់តាំងប្រឆាំងនឹងសមាជិកណាមួយនៃអង្គការពលកម្មអន្តរជាតិ ។ មានស្ថាប័នពីរដែលដោះស្រាយលើពាក្យបណ្តឹង គឺគណៈកម្មាធិការស្តីពីសិទ្ធិសេរីភាពរបស់សមាគមន៍នៃអង្គការត្រួតពិនិត្យ និងគណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សាសិទ្ធិសេរីភាពរបស់សមាគមន៍ ។ គណៈកម្មាធិការស្តីពីសិទ្ធិសេរីភាពរបស់សមាគមន៍មានកាតព្វកិច្ចទទួលពាក្យបណ្តឹងដោយផ្ទាល់ពីអង្គការចាត់តាំងបុគ្គលិកនិងកម្មករពីសហជីពពាណិជ្ជកម្ម និងពីរដ្ឋាភិបាល ។ គណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សាសិទ្ធិសេរីភាពរបស់សមាគមន៍មានតួនាទីដោះស្រាយបណ្តឹងដែលនិយាយសំដៅមកលើខ្លួន ដោយគណៈកម្មាធិការស្តីពីសិទ្ធិសេរីភាពរបស់សមាគមន៍មនុស្សអង្គការត្រួតពិនិត្យរដ្ឋាភិបាលណាមួយនិងក្រុមប្រឹក្សាសង្គមនិងសេដ្ឋកិច្ច ។

នៅក្នុងអនុសញ្ញានានានៃអង្គការពលកម្មអន្តរជាតិ មានចែងអំពីពាក្យបណ្តឹងចោទប្រកាន់ការរំលោភបំពានលើសិទ្ធិសេរីភាពរបស់សមាគមន៍ ។ គណៈកម្មាធិការជំនាញស្តីពីការអនុវត្តអនុសញ្ញានិងអនុសាសន៍គឺជាអង្គការត្រួតពិនិត្យលើអនុសញ្ញានៃអង្គការពលកម្មអន្តរជាតិ ។ ប្រសិនបើសិទ្ធិសេរីភាពរបស់សមាគមន៍ត្រូវបានរកឃើញថាមានការរំលោភបំពានមែននោះ គណៈកម្មាធិការជំនាញនេះមានសិទ្ធិសម្រេចលើអនុសាសន៍របស់ភាគីជម្លោះដោយរាប់បញ្ចូលរដ្ឋាភិបាលក្នុងការស្តារស្ថានភាពនេះ ដូចជាការធ្វើវិសោធនកម្មច្បាប់ជាដើម ។

នៅក្នុងខែមីនា ឆ្នាំ១៩៩៣ គណៈកម្មាធិការជំនាញស្តីពីការអនុវត្តន៍អនុសញ្ញានិងអនុសាសន៍បានពិចារណារបាយការណ៍ទាក់ទិននឹងព័ត៌មាននិងការស៊ើបអង្កេតលើការអនុវត្តន៍អនុសញ្ញាលេខ ១១១ពីការរើសអើង (ការជួលនិងការត្រួតពិនិត្យកម្លាំងពលកម្ម) ដោយរដ្ឋាភិបាលរូម៉ានី ។ គណៈកម្មាធិការនេះបានស្នើសុំឲ្យរដ្ឋាភិបាលរូម៉ានីផ្ញើរបាយការណ៍អំពីការចាត់វិធានការក្នុងការធ្វើឲ្យអនុសាសន៍លេខ២០ នៃគណៈកម្មការស៊ើបសួរព័ត៌មានលើ “សំណងចំពោះការរើសអើងដែលទទួលរងដោយសារក្រុមជនជាតិមួយក្តាប់តូចឬដោយសារជនទាំងឡាយណាដែលជាប់ចោទពីរឿងនយោបាយ” ។ ការស្វែងរកសំណងពីការរំលោភបំពានលើសិទ្ធិមនុស្សនៅក្នុងយន្តការរបស់អង្គការពលកម្មអន្តរជាតិ ជាក្តីសង្ឃឹមសំខាន់មួយសម្រាប់ជនរងគ្រោះ ។ ក្រោមច្បាប់រដ្ឋធម្មនុញ្ញនៃអង្គការពលកម្មអន្តរជាតិ រដ្ឋាភិបាលអាចដាក់ពាក្យបណ្តឹងនេះទៅតុលាការយុត្តិធម៌អន្តរជាតិធ្វើប្រសិនបើខ្លួនមិនយល់ព្រមនឹងអនុសាសន៍ទាំងឡាយរបស់គណៈកម្មាធិការស៊ើបសួរព័ត៌មាននោះ ។ ***(នៅមានត)***

**ម៉ាន់ថាន់ ពៅដារ៉ា**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាននិងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ៖

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ,
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: dccam@online.com.kh*

*Home page: www.dccam.org*

# យុត្តិធម៌និងការផ្សះផ្សាបង្រួបបង្រួមនៅប្រទេសកម្ពុជា

**(តពីលេខមុន)**

## ជំពូកទីបី

## យុត្តិធម៌និងការផ្សះផ្សាបង្រួបបង្រួមនៅប្រទេសកម្ពុជា

អត្ថបទនេះចងក្រងឡើងនៅក្នុងខែកក្កដា ឆ្នាំ២០០៣ បន្ទាប់ពីសង្គ្រាមស៊ីវិលរវាងខ្មែរក្រហមនិងរាជរដ្ឋាភិបាលកម្ពុជាបានបញ្ចប់ ជនភៀសខ្លួនរស់នៅតាមព្រំដែនកម្ពុជា-ថៃធ្វើមាតុភូមិនិវត្តន៍មកកាន់ស្រុកកំណើតវិញ និងចំពេលរាជរដ្ឋាភិបាលកម្ពុជាកំពុងតែខ្នះខ្នែងស្វែងរកយុត្តិធម៌ជូនជនរងគ្រោះនៃរបបខ្មែរក្រហមដើម្បីផ្សះផ្សាបង្រួបបង្រួមជាតិឡើងវិញ ។ រដ្ឋាភិបាលកម្ពុជានិងតំណាងអង្គការសហប្រជាជាតិបានចុះហត្ថលេខាលើសេចក្តីព្រាងច្បាប់បង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ហើយក៏បានផ្ញើជូនសភាជាតិដើម្បីអនុម័តរួចហើយដែរ ។

ប្រធានបទរបស់អត្ថបទនេះគឺ "យុត្តិធម៌និងការផ្សះផ្សាបង្រួបបង្រួមនៅប្រទេសកម្ពុជា" ។ ជំពូកទីបីនេះចែកចេញជាបីចំណុច ។ ចំណុចទីមួយៈ សិក្សាអំពីប្រវត្តិដើមនៃសង្គ្រាមនៅប្រទេសកម្ពុជា ។ ចំណុចទីពីរ ៈ បង្ហាញគំនិតខុសៗគ្នារបស់ប្រជាជនកម្ពុជាអំពីតួនាទីរបស់តុលាការក្នុងដំណើរការផ្សះផ្សាបង្រួបបង្រួមជាតិនិងអំពីទំនាក់ទំនងរវាងយុត្តិធម៌ និងការផ្សះផ្សាបង្រួបបង្រួម ។ ចំណុចទីបីនឹងសន្និដ្ឋានថា តុលាការកាត់-ទោសមេដឹកនាំខ្មែរក្រហមក៏មិនខុសពីតុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់ប្រទេសរ៉្វាន់ដាដែរ គឺមិនគ្រប់គ្រាន់សម្រាប់ដំណើរការផ្សះផ្សានិងបង្រួបបង្រួមជាតិឡើយ ។

### ១) ប្រវត្តិសង្គ្រាមនៅប្រទេសកម្ពុជា

បន្ទាប់ពីផ្តួលរំលំរបបលន់នល់ដែលគាំទ្រដោយសហរដ្ឋអាមេរិកនៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានឡើងគ្រប់គ្រងប្រទេសកម្ពុជា ។ រយៈពេលជិត៤ឆ្នាំក្រោមការគ្រប់គ្រងដោយរបបកុម្មុយនិស្តខ្មែរក្រហម ប្រជាជនកម្ពុជាប្រមាណជិតពីរលាននាក់បានស្លាប់បាត់បង់ជីវិតដោយការសម្លាប់បង្អត់អាហារនិងជំងឺ ។ នៅពាក់កណ្តាលឆ្នាំ១៩៧៨ កងទ័ពវៀតណាម រួមជាមួយកម្មាភិបាលផ្តាច់ខ្លួនខ្មែរក្រហមមួយចំនួនតូចបានវាយលុកលុយចូលប្រទេសកម្ពុជាហើយផ្តួលរំលំរបបខ្មែរក្រហមនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។ កងទ័ពខ្មែរក្រហម ដែលនៅសេសសល់បានរត់ទៅជ្រកកោននៅតាមព្រំដែនកម្ពុជា-ថៃនៅភាគខាងលិចប្រទេសដើម្បីគេចពីការតាមវាយប្រហាររបស់ កងទ័ពវៀតណាម ។ សហរដ្ឋអាមេរិក ចិន និងថៃ បានជួយឧបត្ថម្ភកងទ័ព ខ្មែរក្រហមដែលរស់នៅតាមព្រំដែនកម្ពុជា-ថៃ ហើយបន្តធ្វើសង្គ្រាមប្រឆាំងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលដឹកនាំដោយ ហេង សំរិន និង ហ៊ុន សែន និងគាំទ្រដោយប្រទេសវៀតណាម ។

ក្រោមការសម្របសម្រួលរបស់អង្គការសហប្រជាជាតិ រដ្ឋាភិបាលកម្ពុជានិងខ្មែរក្រហមបានជួបចចារជាមួយគ្នាជាច្រើនលើកច្រើនសារ ហើយទីបំផុតបានសម្រេចដល់កិច្ចព្រមព្រៀង


ដូនជីធ្វើទស្សនកិច្ចសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៦

ទីក្រុងប៉ារីសនៅខែតុលាឆ្នាំ១៩៩១ និងការបោះឆ្នោតជាសកលលើកដំបូងនៅខែឧសភាឆ្នាំ១៩៩៣ ។ ខណៈដែលការបោះឆ្នោតខិតជិតមកដល់ខ្មែរក្រហមបានប្រកាសធ្វើពហិការមិនចូលរួមការបោះឆ្នោត ហើយធ្វើសង្គ្រាមប្រឆាំងនឹងរដ្ឋាភិបាលបន្តទៀត ។

ពីឆ្នាំ១៩៩៦ដល់ឆ្នាំ១៩៩៨ មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមចាប់ផ្ដើមខ្វែងគំនិតគ្នាហើយបែកបាក់គ្នាជាបន្តបន្ទាប់រហូតដល់មេដឹកនាំមួយចំនួនសម្រេចចិត្តធ្វើសមាហរណកម្មកម្លាំងជាមួយរាជរដ្ឋាភិបាល ។ អៀង សារី អតីតបងធំទីបី បានចុះចូលជាមួយរដ្ឋាភិបាលនៅខែកញ្ញា ឆ្នាំ១៩៩៦ ។ អៀង សារី និងក្រុមរបស់ខ្លួន ទទួលបានការលើកលែងទោសពីព្រះមហាក្សត្រ ហើយសព្វថ្ងៃកំពុងរស់នៅក្នុងផ្ទះវីឡាដ៏ប្រណីតមួយនៅក្នុងទីក្រុងភ្នំពេញ ។ នួន ជា អតីតបងធំទីពីរ និង ខៀវ សំផន អតីតប្រធានរដ្ឋ បានចុះចូលជាមួយរដ្ឋាភិបាលនៅដើមឆ្នាំ១៩៩៧ ហើយបានទទួលការលើកលែងទោសពីរដ្ឋាភិបាលនៅឆ្នាំ១៩៩៨ ។ សព្វថ្ងៃ នួន ជា និង ខៀវ សំផន កំពុងរស់នៅក្រុងប៉ៃលិន ដែលពីមុនស្ថិតក្រោមការគ្រប់គ្រងគ្រប់គ្រងខ្មែរក្រហម ។

មេដឹកនាំកំពូលរបស់ខ្មែរក្រហមឈ្មោះ ប៉ុល ពត បានស្លាប់ដោយអាថ៌កំបាំងនៅក្នុងព្រៃលើកំពូលភ្នំដងរែកស្ថិតនៅប៉ែកពាយ័ព្យនៃប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩៨ ។ ចំណែក កែ ពក មេបញ្ជាការនិងជាអតីតលេខាភូមិភាគឧត្តរពីឆ្នាំ១៩៧៥ ដល់ ១៩៧៩ បានស្លាប់ដោយជំងឺលើសឈាមកាលពីឆ្នាំ២០០២ ក្នុងអាយុ៧២ឆ្នាំ ។ មេខ្មែរក្រហមល្បីល្បាញម្នាក់ទៀតឈ្មោះ ឈិត ជឿន ហៅ តាម៉ុក ត្រូវកងកម្លាំងរបស់រាជរដ្ឋាភិបាលចាប់ខ្លួននៅឆ្នាំ១៩៩៨ ។ កាំង ហ្គិចអៀវ ហៅ ឌុច អតីតប្រធានមន្ទីរសន្តិសុខដ៏យង់ឃ្នងហៅថា មន្ទីរស-២១ ឬ គុកទួលស្លែង ក៏ត្រូវរាជរដ្ឋាភិបាលចាប់ខ្លួននៅខែឧសភាឆ្នាំ១៩៩៩ ។ សព្វថ្ងៃនេះ តាម៉ុក និង ឌុច កំពុងស្ថិតនៅក្នុងមន្ទីរឃុំឃាំងរបស់រាជរដ្ឋាភិបាលដើម្បីរង់ចាំការជំនុំជម្រះពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលបានប្រព្រឹត្តឡើងក្នុងអំឡុងរបបខ្មែរក្រហមពីឆ្នាំ១៩៧៥ ដល់១៩៧៩ ។

## ៣) គ្មានយុត្តិធម៌ឬការផ្សះផ្សាបង្រួបបង្រួម

ទោះបីជារបបខ្មែរក្រហមបានដួលរលំផុតទៅហើយក្ដី ប្រជាជនកម្ពុជានៅតែមិនអាចបំភ្លេចអតីតកាលដ៏ជូរចត់នេះបានឡើយ ។ មូលហេតុទីមួយដោយសារប្រជាជនមិនទាន់បានដឹងអំពីការពិតដែលកើតឡើងពិតប្រាកដ ។ ទីពីរដោយសារប្រជាជនមិនដែលបានទទួលការសុំទោសពីមេដឹកនាំខ្មែរក្រហម និងទីបីដោយសារប្រជាជននៅមិនទាន់ទទួលបានយុត្តិធម៌ ។ របបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានកាត់ទោសប្រហារជីវិត ប៉ុល ពត និង អៀង សារី ដោយកំបាំងមុខ ក៏ប៉ុន្តែការជំនុំជម្រះនៅពេលនោះមិនត្រូវបានសហគមន៍អន្តរជាតិទទួលស្គាល់ឡើយ ។

ប្រជាជនកម្ពុជាដែលទទួលរងគ្រោះធ្ងន់ធ្ងរឬបាត់បង់សមាជិកគ្រួសារនៅក្នុងរបបខ្មែរក្រហម នៅតែមានកំហឹងនិងមិនចង់ផ្សះផ្សាជាមួយខ្មែរក្រហមឡើយ ។ កំហឹងរបស់ប្រជាជនចំពោះខ្មែរក្រហមមានទំហំធំធេងនិងនៅតែក្ដៅគគុក ដោយសារទីមួយការស្លាប់បាត់បង់ជីវិតប្រជាជនក្រោមរបបខ្មែរក្រហមពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ទីពីរដោយសារការអូសបន្លាយសង្គ្រាមប្រឆាំងនឹងរដ្ឋាភិបាលកម្ពុជាពីឆ្នាំ១៩៧៩ដល់១៩៩៦ និងទីបីគោលនយោបាយចងកំហឹងរបស់រដ្ឋាភិបាលកម្ពុជាចំពោះរបបខ្មែរក្រហមតាមរយៈការអប់រំផ្សព្វផ្សាយ ការកសាងបូជនីយដ្ឋាន និងការប្រារព្ធទិវាចងកំហឹង ។ សព្វថ្ងៃនេះទោះបីជាខ្មែរក្រហមបានចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជាហើយក្ដី ប្រជាជនមួយចំនួននៅតែខឹងនឹងខ្មែរក្រហម ហើយនៅតែមិនអាចអត់ឱនទោសឲ្យជនដៃដល់ថ្នាក់ក្រោមខ្មែរក្រហមបានដោយសារតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមមិនទាន់លេចចេញជារូបរាងច្បាស់លាស់ ។ ដូច្នេះប្រជាជនយល់ថា សិទ្ធិសេរីភាពក្នុងការរស់នៅនិងធ្វើដំណើររបស់ជនដៃដល់គឺជាការប្រមាថចំពោះជនរងគ្រោះដែលបានស្លាប់ទៅហើយ ។

នៅពេលសួរនាំនិងរំឭកអំពីរបបខ្មែរក្រហម ប្រជាជនសម្ដែងការឈឺចាប់ចំពោះខ្មែរក្រហមដែលបានកាប់សម្លាប់ប្រជាជន និងសម្ដែងក្ដីអាណិតអាសូរចំពោះសាច់ញាតិរបស់ខ្លួនដែលបានស្លាប់ទៅ ។ ប្រជាជនកម្ពុជាភាគច្រើនចោទប្រកាន់មេដឹកនាំខ្មែរ-ក្រហម ជាពិសេស ប៉ុល ពត, អៀង សារី និង តាម៉ុក ។ ចំណែកប្រជាជនខ្លះទៀតស្ដីបន្ទោសកម្មាភិបាលនិងកងឈ្លបថ្នាក់ក្រោមដែលបានសម្លាប់ប្រជាជនដោយផ្ទាល់ដៃ ។ កុំ ក្លាយជាស្ត្រី

មេម៉ាយបន្ទាប់ពីប្តីរបស់គាត់ត្រូវខ្មែរក្រហមសម្លាប់ ។ ប្តីរបស់ កុំ ត្រូវកងឈ្លបភូមិខ្មែរក្រហមឈ្មោះ ដុច ចាប់ខ្លួននៅពាក់កណ្តាលអាធ្រាត្រក្នុងឆ្នាំ១៩៧៨ ។ បន្ទាប់ពីប្តីរបស់គាត់បានស្លាប់ទៅ កុំ បានប្រឹងត្រដរស់នៅចិញ្ចឹមបីបាច់កូនទាំង៤នាក់តែម្នាក់ឯង ។ កុំ នៅតែនឹកឃើញហេតុការណ៍ដែលកើតឡើងចំពោះគាត់ ហើយតែងមានអារម្មណ៍ឈឺចាប់ចំពោះ ដុច ។ កុំ និយាយថា "ខ្ញុំមិនអាចបំភ្លេចនិងអត់ទោសឲ្យ ដុច ទេក្នុងជាតិនេះ ។ ខ្ញុំព្រាត់ប្រាសប្តីនិងចិញ្ចឹមកូនតែម្នាក់ឯងយ៉ាងលំបាកលំបិនបំផុត ។ ពេលខ្ញុំឃើញ ដុច ជិះកង់កាត់មុខផ្ទះខ្ញុំម្តងៗ ខ្ញុំខឹងណាស់ ប៉ុន្តែខ្ញុំមិនដឹងធ្វើយ៉ាងម៉េច" ។

អតីតកងឈ្លបថ្នាក់ក្រោមមួយចំនួនចោទប្រកាន់អតីតមេដឹកនាំរបស់ខ្លួនចំពោះការកាប់សម្លាប់ប្រជាជន ។ ដុច និង ខេង គឺជាអតីតកងឈ្លបខ្មែរក្រហមថ្នាក់ក្រោម ។ អ្នកទាំងពីរអះអាងថាការសម្លាប់ប្រជាជនកើតឡើងដោយសារមានបញ្ជាពីមេដឹកនាំថ្នាក់លើ ឈ្លបថ្នាក់ក្រោមពុំបានដឹងអ្វីពិតប្រាកដឡើយ ។ ឈ្លបថ្នាក់ក្រោមគឺជាឧបករណ៍សម្រាប់មេដឹកនាំប្រើប្រាស់ដើម្បីសម្លាប់ប្រជាជននិងទទួលរងទារុណកម្មតែប៉ុណ្ណោះ ។ ខេង ទាមទារឲ្យបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដើម្បីឲ្យប្រជាជនកម្ពុជាទាំងអស់យល់ព្រមផ្សះផ្សានិងបង្រួបបង្រួមគ្នាឡើងវិញ ។ ខេង បញ្ជាក់ថា កងឈ្លបខ្មែរក្រហមថ្នាក់ក្រោមពិតជាមិនហ៊ានកាប់សម្លាប់ប្រជាជនឡើយប្រសិនបើមិនមានបញ្ជាពីថ្នាក់លើជាពិសេសពី "ប៉ុល ពត និង អៀង សារី" ។

ស្ត្រីម្នាក់អាយុ៤៦ឆ្នាំរស់នៅផ្ទះខ្ទមទល់មុខនឹងវីឡារបស់ អៀង សារី ខឹងនឹង អៀង សារី ជាខ្លាំង។ ឪពុកម្តាយរបស់គាត់បានស្លាប់បាត់បង់ជីវិតនៅក្នុងវាលស្រែក្នុងឆ្នាំ១៩៧៧នៅភាគខាងលិចប្រទេសកម្ពុជា ។ មិនខុសប្លែកអំពីជនរងគ្រោះដទៃទៀតឡើយ ស្ត្រីរូបនេះមិនសប្បាយចិត្តចំពោះសិទ្ធិធ្វើដំណើររបស់ អៀង សារី ឡើយ ។ គាត់រៀបរាប់ថា ÷

“ពេលខ្ញុំឃើញគាត់ (អៀង សារី) ដំបូងខ្ញុំឆ្ងល់ ។ ហេតុអ្វីបានជាគាត់មករស់នៅក្នុងភូមិស្រុកជាមួយប្រជាជនវិញ? យើងទទួលរងការលំបាកព្រាត់ប្រាសឪពុកម្តាយអស់ដោយសារគាត់ ឥឡូវគាត់មកជួបយើងទៀត។ ធ្វើបែបនេះដូចជាមិនយុត្តិធម៌ទាល់តែសោះ ។ ដំបូងខ្ញុំថាឲ្យតែបានជួបគឺសម្លាប់គាត់ចោលតែម្តង" ។

សព្វថ្ងៃប្រជាជនកម្ពុជាភាគច្រើន ជាពិសេសជនរងគ្រោះនិងជនភៀសខ្លួនដែលបានឆ្លងកាត់សង្គ្រាមរ៉ាំរ៉ៃនិងការព្រាត់ប្រាស់សាច់ញាតិ ចង់រស់នៅក្នុងសន្តិភាពជួបជុំគ្រួសារដោយសុខសប្បាយ ។ ប្រជាជនទាំងនេះចង់ឲ្យមានការផ្សះផ្សាបង្រួបបង្រួម ហើយអត្ថន័យនៃពាក្យការផ្សះផ្សាបង្រួបបង្រួមចំពោះប្រជាជនទាំងនោះគឺការរស់នៅដោយសុខសប្បាយនិងមានការរាប់អានគ្នា ។



ដូចដែលបានបង្ហាញខាងលើប្រជាជនកម្ពុជាយល់ដឹងនិងទាមទារខុសគ្នាចំពោះដំណើរការផ្សះផ្សា និងបង្រួបបង្រួមជាតិ ។ វគ្គបន្តបន្ទាប់នេះ ខ្ញុំនឹងលើកយកអំពីតួនាទីចំណុចខ្លាំងនិងចំណុចខ្សោយរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមមកពិភាក្សាថាតើតុលាការខ្មែរក្រហមមានតួនាទីបែបណាក្នុងដំណើរការផ្សះផ្សាបង្រួបបង្រួមជាតិនៅប្រទេសកម្ពុជា ។

## ៣) ការជជែកពិភាក្សាអំពីតួនាទីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម

នៅក្នុងខែមិថុនាឆ្នាំ១៩៩៧ រាជរដ្ឋាភិបាលកម្ពុជាបានស្នើឲ្យអង្គការសហប្រជាជាតិឲ្យគាំទ្រនិងចូលរួមនៅក្នុងដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ អង្គការសហប្រជាជាតិបានទទួលយល់ព្រមតាមការស្នើសុំនេះ ។ នៅខែធ្នូ ឆ្នាំ១៩៩៧ ក្រុមប្រឹក្សាអង្គការសហប្រជាជាតិបានអនុម័តគាំទ្រជាឯកឆ័ន្ទ ។ ការចរចារវាង ហេន កូរែល តំណាងពិសេសរបស់លោក



អគ្គលេខាអង្គការសហប្រជាជាតិ និងតំណាងរាជរដ្ឋាភិបាលកម្ពុជាដឹកនាំឯកឧត្តមដោយ សុខ អាន អំពីដំណើរការរបស់តុលាការបានចំណាយពេលអស់៦ឆ្នាំ ។ មូលហេតុសំខាន់នៃការអូសបន្លាយពេលចរចានេះគឺដោយសារភាគីទាំងពីរសុទ្ធតែទាមទារសិទ្ធិគ្រប់គ្រងលើដំណើរការរបស់តុលាការ ។ នៅក្នុងខែកុម្ភៈ ឆ្នាំ២០០២ អង្គការសហប្រជាជាតិប្រកាសដកខ្លួនចេញពីការចរចាដោយមូលហេតុមិនជឿទុកចិត្តថាតុលាការដែលនឹងបង្កើតឡើងមានភាពឯករាជ្យនិងយុត្តិធម៌ ។ ចំណែករាជរដ្ឋាភិបាលកម្ពុជាប្រកាន់ជំហរមិនព្រមឲ្យអង្គការសហប្រជាជាតិគ្រប់គ្រងតុលាការដោយមូលហេតុខ្លាចបាត់បង់អធិបតេយ្យភាពប្រទេសរបស់ខ្លួន ។ ក្រោមសម្ពាធរបស់បណ្តាប្រទេសមហាអំណាចរួមមាន បារាំង, ជប៉ុន និងអាមេរិក ការចរចាបានចាប់ដំណើរការឡើងវិញ ។ កិច្ចពិភាក្សាលើសេចក្តីព្រាងច្បាប់បានបញ្ចប់នៅក្នុងខែមីនា ឆ្នាំ២០០៣ ហើយពិធីចុះហត្ថលេខាជាផ្លូវការបានប្រារព្ធឡើងនៅសាលសន្និសីទចតុមុខនៅទីក្រុងភ្នំពេញក្នុងខែមិថុនា ឆ្នាំ២០០៣ ។

សេចក្តីព្រាងច្បាប់ដែលចុះហត្ថលេខាដោយអង្គការសហ-ប្រជាតិនិងរាជរដ្ឋាភិបាកម្ពុជាសម្រេចបង្កើតតុលាការខ្មែរក្រហមដែលមានសវនាការពីរថ្នាក់ ។ ថ្នាក់ទីមួយគឺតុលាការដំបូង និងថ្នាក់ទីពីរគឺតុលាការខទ្ធរណ៍ឬតុលាការកំពូល ។ តុលាការដំបូងមានចៅក្រមប្រាំរូប (បីរូបជាចៅក្រមកម្ពុជានិងពីររូបជាចៅក្រមបរទេស) តុលាការកំពូលមានចៅក្រមប្រាំពីររូប (បួនរូបជាចៅក្រមកម្ពុជា និងបីរូបជាចៅក្រមបរទេស) ។ ចំណុចសំខាន់នៅក្នុងសេចក្តីព្រាងច្បាប់ដែលគួរចាប់អារម្មណ៍ គឺរាល់ការសម្រេចក្តីនៅក្នុងអង្គជំនុំជម្រះរបស់តុលាការគ្រប់ថ្នាក់ត្រូវតែមានការគាំទ្រយ៉ាងតិចមួយសំឡេងពីសំណាក់ចៅក្រមបរទេស ។

លោក ឆាំង យុ ប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជាដែលប្រមូលឯកសារទាក់ទងរបបខ្មែរក្រហមបានរៀបរាប់ថា ខ្មែរក្រហមទទួលបរាជ័យដោយសារការប្រើប្រាស់អាវុធ មិនមែនដោយសារការប្រើប្រាស់ច្បាប់ឡើយ ។ លោកបញ្ជាក់ថា យុត្តិធម៌តាមផ្លូវតុលាការគឺជាមធ្យោបាយចម្បងបំផុតសម្រាប់ដោះស្រាយកេរដំណែលដែលបន្សល់ទុកពីរបបខ្មែរក្រហមនិងនាំមកនូវការផ្សះផ្សាបង្រួបបង្រួមជាតិ ។ ប្រជាជនកម្ពុជាអាចអត់ឱនទោសឲ្យគ្នាទៅវិញទៅមក ហើយរស់នៅក្នុងសន្តិភាពពិតប្រាកដដរាបណាប្រជាជនបានដឹងអំពីការពិតនិងទទួលបានយុត្តិធម៌ ។ មេដឹកនាំថ្នាក់ខ្ពស់ដូចជា អៀង សារី, ខៀវ សំផន, នួន ជា និង អៀង ធីរិទ្ធ ត្រូវតែទទួលខុសត្រូវនូវអ្វីដែលបានកើតឡើង ។ លោក ឆាំង យុ បន្តថា "ដើម្បីសន្តិភាពការបង្រួបបង្រួមជាតិ និងការអភិវឌ្ឍន៍ពិតប្រាកដប្រជាជនកម្ពុជាត្រូវតែហ៊ានប្រឈមមុខនឹងការពិត... ។

ការប្រឈមមុខនេះនឹងជួយឲ្យប្រជាជនបំភ្លេចអតីតកាល ហើយកសាងអនាគតឲ្យរីកចម្រើនបាន” ។

ប្រជាជនកម្ពុជាក៏ដូចជាអ្នកសង្កេតការណ៍ជាច្រើនរូប សប្បាយចិត្តនិងគាំទ្រសេចក្តីព្រាងច្បាប់បង្កើតតុលាការខ្មែរក្រហម ។ ក៏ប៉ុន្តែ បន្ទាប់ពីសិក្សាលើសេចក្តីព្រាងច្បាប់នោះខ្ញុំយល់ឃើញថា តុលាការខ្មែរក្រហមអាចឃើតយ៉ាវនិងមិនសមស្របតាមបទដ្ឋានអន្តរជាតិឡើយ ។ ជាក់ស្តែង មាត្រា១៥នៃសេចក្តីព្រាងច្បាប់អាចបង្កឲ្យតុលាការខ្វះឯករាជ្យភាព ។ មូលហេតុសំខាន់ក្នុងការបង្កើតតុលាការដោយមានការចូលរួមពីសំណាក់អង្គការសហ-ប្រជាជាតិ គឺដើម្បីបង្កើតតុលាការមួយដែលឯករាជ្យនិងមិនពុករលួយ ។ ផ្ទុយទៅវិញ មាត្រា១៥នៃសេចក្តីព្រាងសរសេរថា “ប្រាក់បៀវត្សរ៍របស់បុគ្គលិកនិងចៅក្រមកម្ពុជាគឺជាការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជា” ។ ទីមួយ ការចំណាយតិចតួចរបស់រាជរដ្ឋាភិបាលកម្ពុជាទៅចៅក្រមកម្ពុជាអាចធ្វើឲ្យចៅក្រមកម្ពុជាខ្វះសុឆន្ទៈក្នុងការបំពេញការងារ ។ ទីពីរ ការចំណាយរបស់រដ្ឋាភិបាលកម្ពុជាអាចធ្វើឲ្យមានអំពើពុករលួយ និងទីបី អាចធ្វើឲ្យតុលាការបាត់បង់ឯករាជ្យភាព ។ មាត្រា១១ដែលពាក់ព័ន្ធដល់ករណី អៀង សារី ដែលជាមេដឹកនាំកំពូលខ្មែរក្រហមម្នាក់ ហើយបានទទួលការលើកលែងទោសពីព្រះមហាក្សត្រ ក៏អាចបង្កការលំបាកដែរ ។ ប្រជាជនកម្ពុជាភាគច្រើនចង់ឲ្យតុលាការកាត់ទោស អៀង សារី ក៏ប៉ុន្តែមាត្រា១៥មិនបាននិយាយច្បាស់អំពីករណីរបស់ អៀង សារី ឡើយ ។ មាត្រានេះ បានទុកករណីរបស់ អៀង សារី ឲ្យចៅក្រមជាអ្នកសម្រេច ។ ដូច្នេះករណី អៀង សារី នៅតែមិនទាន់ច្បាស់លាស់នៅឡើយ ។ នេះបានសេចក្តីថា ករណី អៀង សារី គឺអាស្រ័យទាំងស្រុងលើសុឆន្ទៈរបស់រាជរដ្ឋាភិបាលកម្ពុជា ។



ម្យ៉ាងវិញទៀត សេចក្តីព្រាងច្បាប់ក៏មិនបានចែងច្បាស់អំពីការការពារសិទ្ធិសាក្សីដែរ ។ សាក្សី ដែលនឹងរៀបរាប់ឡើងវិញប្រាប់តុលាការអំពីហេតុការណ៍ដែលបានកើតឡើងចំពោះខ្លួន ត្រូវរំរកនឹករឿងពីអតីតកាលឡើងវិញ ។ ការរំនឹកគិតនេះអាចធ្វើឲ្យសាក្សីមានការឈឺចាប់ម្តងទៀត ហើយសាក្សីក៏អាចប្រឈមមុខនឹងបញ្ហាសន្តិសុខផ្ទាល់ខ្លួនដែរ ។ ដូច្នេះការការពារសាក្សីគឺជាកាតព្វកិច្ច និងជាការចាំបាច់បំផុត ។ ផ្ទុយទៅវិញ សេចក្តីព្រាងច្បាប់ហាក់ពុំបានយកចិត្តទុកដាក់ខ្ពស់ចំពោះករណីនេះឡើយ ។ មាត្រា២៣នៃសេចក្តីព្រាងច្បាប់កំណត់ថា ការការពារសាក្សីគឺជាតួនាទីរបស់សហចៅក្រម ។ សំណួរមួយសួរថា ហេតុអ្វីបានជាអង្គការសហប្រជាជាតិមិនប្រើប្រាស់បុគ្គលិកអង្គការសហប្រជាជាតិដែលមានបទពិសោធន៍ក្នុងកិច្ចការនេះ ហើយបែរជាប្រគល់កិច្ចការនេះឲ្យទៅចៅក្រមជាអ្នកសម្រេចទៅវិញ?

ក្រុមអ្នករិះគន់ជាពិសេសអង្គការលើកលែងទោសអន្តរជាតិ អង្គការឃ្លាំមើលសិទ្ធិមនុស្សនិងសកម្មជនសិទ្ធិមនុស្ស ក្នុងស្រុកក៏បញ្ជាក់ការព្រួយបារម្ភរបស់ខ្លួនដូចចំណុចដែលខ្ញុំលើកឡើងខាងលើដែរ ។ អ្វីដែលប្លែកនោះគឺក្រុមខាងលើហាក់បារម្ភខ្លាំងអំពីថាតើនរណាជាអ្នកគ្រប់គ្រងតុលាការភាពដែលគួរឲ្យទុកចិត្ត

បានរបស់រដ្ឋាភិបាល និងប្រព័ន្ធតុលាការកម្ពុជា ។ អង្គការលើកលែងទោសអន្តរជាតិចាត់ទុកសេចក្ដីព្រាងច្បាប់ថា“មិនល្អគ្រប់គ្រាន់” ដោយសារគ្មានការចូលរួមរបស់ព្រះរាជអាជ្ញាបរទេស ។ អង្គការឃ្លាំមើលសិទ្ធិមនុស្សពិពណ៌នាសេចក្ដីព្រាងច្បាប់ថា “ខ្សោយនិងមិនឆ្លើយតបទៅនឹងកម្រិតអន្តរជាតិ” ។ ប្រធានគណបក្សប្រឆាំង សម រង្ស៊ី បាននិះគន់សហគមន៍អន្តរជាតិដែលធ្វើសម្បទានច្រើនហួសហេតុចំពោះរាជរដ្ឋាភិបាលកម្ពុជារហូតធ្វើឲ្យសេចក្ដីព្រាងច្បាប់មិនគ្រប់តាមមាត្រដ្ឋានអន្តរជាតិ ។ លោក សម រង្ស៊ី បញ្ជាក់ថា “ខ្ញុំប្រាថ្នាចង់ឲ្យមានតុលាការបង្កើតដោយអង្គការសហប្រជាជាតិសម្រាប់ប្រទេសកម្ពុជាដូចនៅទីក្រុងឡាអេដែរ” ។

ហ្រ្គេហ្គោរី ស្តេនតុន ប្រធានអង្គការឃ្លាំមើលអំពើប្រល័យពូជសាសន៍ និង បន ឆរឌីអាវី អ្នកជំនួយការផ្នែកច្បាប់នៃមជ្ឈមណ្ឌលឯកសារកម្ពុជា គាំទ្រសេចក្ដីព្រាងច្បាប់នេះយ៉ាងពេញទំហឹង ។ ឆ្លើយតបចំពោះការបដិសេធមិនទទួលស្គាល់សេចក្ដីព្រាងច្បាប់តុលាការខ្មែរក្រហមរបស់អង្គការលើកលែងទោសអន្តរជាតិ ស្តេនតុន បកស្រាយថា “ការបដិសេធសេចក្ដីព្រាងច្បាប់ដោយបារម្ភខ្លាចតុលាការមិនអាចធ្វើការងារគ្រប់បែបយ៉ាងគឺមិនខុសពីបារម្ភថាតុលាការមិនអាចចាប់ខ្លួនឧក្រិដ្ឋជនមកផ្តន្ទាទោសឡើយ ។ នៅលើលោកយើងនេះគ្មានអ្វីដែលល្អឥតខ្ចោះទេ ។ ភាពឥតខ្ចោះគឺជាសត្រូវដ៏ធំរបស់យុត្តិធម៌” ។ បន ឆរឌីអាវី យល់ថា ការរិះគន់និងការបារម្ភអំពីប្រព័ន្ធតុលាការកម្ពុជា និងថាតើនរណាគួរតែជាអ្នកគ្រប់គ្រងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម គឺជាការបារម្ភដែលសមហេតុផល ។ ក៏ប៉ុន្តែ ឆរឌីអាវី បញ្ជាក់ថា តុលាការខ្មែរក្រហមស្ថាបនាឡើងសម្រាប់ប្រយោជន៍ទាំងបច្ចុប្បន្ននិងអនាគត ។ ឆរឌីអាវី ពន្យល់បន្ថែមថា ÷

គោលបំណងសំខាន់នៃការបង្កើតឲ្យមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម គឺដើម្បីផ្តល់ឱកាសឲ្យរាជរដ្ឋាភិបាលកម្ពុជាពង្រឹងនិងកសាងប្រព័ន្ធច្បាប់នៅប្រទេសកម្ពុជាឡើងវិញ ។ បើតុលាការនេះរៀបចំនិងគ្រប់គ្រងដោយបរទេសកាន់តែច្រើន រាជរដ្ឋាភិបាលកម្ពុជានឹងមានឱកាសកាន់តែតិច ។ ច្បាប់អន្តរជាតិអាចផ្តល់ជោគជ័យធំធេងសម្រាប់អង្គតុលាការ ប៉ុន្តែប្រជាជនកម្ពុជាអាចមានអារម្មណ៍កក់ក្តៅនិងសប្បាយចិត្តជាមួយច្បាប់ក្នុងស្រុកជាងច្បាប់អន្តរជាតិ ។


នៅក្នុងបន្ទប់សវនាការ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៦
ដូនជីកំពុងលើកសំណួរទៅឯកឧត្ដម ស៊ាន វិសុទ្ធ

អតីតកងទ័ពខ្មែរក្រហមជាច្រើនមិនគាំទ្រគំនិតបង្កើតឲ្យមានតុលាការខ្មែរក្រហមឡើយ ។ កងទ័ពខ្មែរក្រហមទាំងនោះយល់ថា សព្វថ្ងៃកងទ័ពខ្មែរក្រហមទាំងអស់បានចុះចូលមករួមរស់ដោយសុខស្រួលជាមួយរាជរដ្ឋាភិបាលកម្ពុជា ។ គំនិតបង្កើតតុលាការអាចបង្កឲ្យមានសង្គ្រាមនិងការកាប់សម្លាប់ជាថ្មីឡើងវិញ ។ សួង ស៊ីគឿន អតីតតំណាងខ្មែរក្រហមម្នាក់ រៀបរាប់ថា ប្រជាជនមួយចំនួននៅក្នុងភូមិរបស់គាត់បានផ្អាកសាងសង់ផ្ទះសម្បែងរបស់ខ្លួនជាបណ្តោះអាសន្ន បន្ទាប់ពីបានដឹងអំពីការបង្កើតតុលាការ ។ មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលនៅរស់រួមមាន ខៀវ សំផន និង នួន ជា ដែលកំពុងរស់នៅទីក្រុងប៉ៃលិន ក៏មិនគាំទ្រដំណើរការតុលាការដែរ ។ ខៀវ សំផន បញ្ចេញយោបល់ថា ការបង្កើតតុលាការគឺជាការបំផ្លាញសន្តិភាពបច្ចុប្បន្ននិងអាចធ្វើឲ្យមានការកាប់សម្លាប់កើតឡើងម្តងទៀត ។ ខៀវ សំផន និង នួន ជា បញ្ជាក់ថា ប្រទេសកម្ពុជាគួរតែបង្កើតឲ្យមានគណៈកម្មការស្វែងរកការពិតដូចនៅប្រទេសអាហ្វ្រិកខាងត្បូងវិញ ។ ខៀវ សំផន សន្យាថា បើមានគណៈកម្មការស្វែងរកការពិត គាត់នឹងប្រាប់ការពិតអំពីហេតុការណ៍និងការសម្លាប់ប្រជាជនដែលកើតឡើងចាប់ពីឆ្នាំ១៩៧៥ដល់១៩៧៩ ។ ខៀវ សំផន បន្ថែមថា ការបង្កើតគណៈកម្មការស្វែងរកការពិតគឺជាវិធីល្អបំផុតសម្រាប់ប្រទេសកម្ពុជា ។ គណៈកម្មការនេះនឹងជួយ“ប្រទេសកម្ពុជាកុំឲ្យមានការកាប់សម្លាប់ជាថ្មីទៀត” ។

មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការស្ទាបស្ទង់មតិប្រជា-ជនអំពីគំនិតផ្សះផ្សានិងបង្រួបបង្រួមជាតិ ។ លទ្ធផលស្ទាបស្ទង់មតិបានបង្ហាញថា ប្រជាជននៅក្នុងទីក្រុងភ្នំពេញប្រមាណ៧០ភាគរយគាំទ្រការបង្កើតឲ្យមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ប៉ុន្តែការគាំទ្ររបស់ប្រជាជននៅតាមជនបទមានត្រឹមតែ៤៥ភាគរយប៉ុណ្ណោះ ។ លទ្ធផលស្ទាបស្ទង់មតិរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមក៏មានលក្ខណៈប្រហាក់ប្រហែលនិងលទ្ធផលនៃការស្ទាបស្ទង់ដែលធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជាដែរ ។ នេះបានសេចក្តីថា ប្រជាជនរស់នៅក្នុងទីក្រុងភាគច្រើនគាំទ្រឲ្យមានតុលាការ ប៉ុន្តែការគាំទ្រថយចុះនៅតាមជនបទ ជាពិសេសនៅភាគខាងលិចប្រទេស គឺនៅអតីតតំបន់ដែលគ្រប់គ្រងដោយខ្មែរក្រហម ។ លោកស្រី ជា វណ្ណាត ប្រធានមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម បញ្ជាក់ថា “ប្រជាជនរស់នៅក្នុងតំបន់ខ្មែរក្រហមមានការបារម្ភទាំងផ្លូវកាយនិងផ្លូវចិត្ត ហើយហាក់មិនទាន់ទុកចិត្តទាំងស្រុងទៅលើសន្តិភាពសព្វថ្ងៃឡើយ ។ ប្រជាជនទាំងនោះនៅតែបារម្ភថាសង្គ្រាមអាចនឹងកើតឡើងជាថ្មីម្តងទៀត” ។ ទោះបីជាយ៉ាងណាអតីតកងទ័ពខ្មែរក្រហមនៅភូមិភាគនិរតីគាំទ្រឲ្យមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ កងទ័ពទាំងនោះរៀបរាប់ថា មេដឹកនាំដែលចេញបញ្ជាឲ្យមានការកាប់សម្លាប់គួរតែប្រឈមមុខនឹងការកាត់ទោសរបស់តុលាការ ។

នៅពេលដែលកងទ័ពខ្មែរក្រហមនិងប្រជាជនមួយចំនួនគាំទ្រតុលាការខ្មែរក្រហម ប្រជាជននិងកងទ័ពខ្មែរក្រហមមួយចំនួនប្រឆាំងនឹងគំនិតបង្កើតតុលាការខ្មែរក្រហម ជាពិសេសប្រជាជនដែលកំពុងតែរស់នៅតាមជនបទដាច់ស្រយាលនិងប្រជាជនដែលរស់នៅតាមព្រំដែនដែលធ្លាប់ទទួលរងនូវការវិនាសព្រាត់ប្រាសដោយសារសង្គ្រាម ។ មុនី ចិន្តា រៀបរាប់ថា “សព្វថ្ងៃប្រជាជនយើងរស់នៅក្នុងខេត្តបាត់ដំបងមានការបារម្ភជាខ្លាំងអំពីបញ្ហាសន្តិសុខ ។ យើងចង់រស់នៅដោយសុខសប្បាយ យើងចង់បំភ្លេចរឿងអតីតកាលឲ្យអស់ ពីព្រោះយើងមិនចង់ឲ្យមានសង្គ្រាមម្តងទៀតឡើយ ។ យើងរស់នៅប្រកបរបររកស៊ីចិញ្ចឹមគ្រួសារយ៉ាងលំបាក ។ សព្វថ្ងៃយើងគិតគូរពីការហូបចុកនិងបីបាច់កូនចៅរបស់យើង ដូច្នេះអ្វីដែលយើងគិតគូររាល់ថ្ងៃគឺបញ្ហាជីវភាពប្រចាំថ្ងៃ ” ។

ប្រទេសកម្ពុជាគឺជាប្រទេសដែលគោរពព្រះពុទ្ធសាសនា ។ ប្រជាជនមួយចំនួនមិនចង់ឲ្យមានតុលាការកាត់ទោសខ្មែរក្រហមដោយសារប្រជាជនជឿលើកម្មផល និងជឿពុទ្ធឱវាទ “ពៀររំងាប់ដោយការមិនចងពៀរ” ។ ព្រះពុទ្ធបានប្រៀនប្រដៅពុទ្ធបរិស័ទថា “បុគ្គលគ្រប់រូបកើតមករមែងមានទុក្ខ ។ ដើម្បីរួចផុតពីទុក្ខលំបាកបុគ្គលគ្រប់រូបត្រូវលះបង់អំពើអាក្រក់ទាំងបី គឺ លោភៈ ទោសៈនិងមោហៈ” ។ សម្តេចព្រះមហាឃោសានន្ទដែលជាបេក្ខជនរង្វាន់ណូបែលសន្តិភាព បានពន្យល់អំពីវិធីសាស្ត្រដោះស្រាយបញ្ហាតាមព្រះធម៌របស់ព្រះពុទ្ធថា “ធ្វើអំពើល្អដើម្បីសងអំពើអាក្រក់ហើយផ្តល់ការស្រឡាញ់តបស្នងការស្អប់” ។ ទាក់ទងដល់ការ

ផ្សះផ្សាបង្រួបបង្រួមជាតិនៅប្រទេសកម្ពុជា សម្តេចព្រះមហាឃោសានន្ទបញ្ជាក់ថា ៖

*អាត្មាមិនមែនចង់ឲ្យប្រជាជនកម្ពុជាស្រឡាញ់អ្នកដែលធ្លាប់ធ្វើបាបជិះជាន់យើងដូចជាខ្មែរក្រហមទេ ពីព្រោះវាជាការលំបាកបំផុត ។ ប៉ុន្តែយើងត្រូវយល់ថា ការគុំកួនសងសឹកគ្នារមែងនាំមកនូវបច្ច័យអាក្រក់កាប់សម្លាប់គ្នាមិនចេះចប់មិនចេះហើយ ។ ការផ្សះផ្សាបង្រួបបង្រួមមិនមែនបានសេចក្តីថាយើងបោះបង់ចោលច្បាប់និងសិទ្ធិរបស់យើងទេ ប៉ុន្តែអាត្មាគ្រាន់តែចង់ឲ្យយើងមានក្តីសន្តោសមេត្តាចំពោះគ្នា ។ យើងត្រូវសន្តោសដល់អ្នកដែលធ្វើខុសដោយសេចក្តីឆោតល្ងង់ ។ យើងក៏ធ្លាប់ប្រព្រឹត្តខុសដោយសេចក្តីឆោតល្ងង់ដែរ ។ ដូច្នេះការសន្តោសមេត្តារបស់យើងចំពោះអំពើឆោតល្ងង់របស់អ្នកដទៃគឺជាអំពើល្អ ហើយអ្នកផងក៏នឹងសន្តោសមេត្តាដល់អំពើឆោតល្ងង់របស់យើងវិញដែរ ។*

សម្តេចព្រះសង្ឃរាជគណៈមហានិកាយ ទេព វង្ស ផ្តល់ពុទ្ធឱវាទមួយបែបទៀតថា "ព្រះពុទ្ធបានប្រៀនប្រដៅមនុស្សគ្រប់រូបឲ្យធ្វើតែអំពើល្អ ពីព្រោះអំពើល្អតែងផ្តល់ផលល្អចំណែកអំពើអាក្រក់រមែងនាំមកនូវផលអាក្រក់" ។ សម្តេចព្រះសង្ឃរាជគាំទ្រឲ្យមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ សម្តេចព្រះសង្ឃរាជបានពន្យល់មូលហេតុនៃការគាំទ្ររបស់ព្រះអង្គថា ព្រះពុទ្ធក៏ធ្លាប់ធ្វើសង្គ្រាមហើយបានសម្លាប់យក្សដើម្បីជួយសង្គ្រោះប្រជាជនដែរ ។ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ទីមួយជួយទប់ស្កាត់មិនឲ្យការកាប់សម្លាប់កើតឡើងម្តងទៀត ទីពីរជួយផ្តល់ការពិតនិងជួយផ្សះផ្សាបង្រួបបង្រួមជាតិឡើងវិញ ក៏ប៉ុន្តែសម្តេចព្រះសង្ឃរាជបន្ថែមថា "តុលាការមិនគួរធ្វើជ្រុលហួសហេតុដូចជាបង្ខិតបង្ខំឬចាប់ខ្លួនជនគ្មានការពាក់ព័ន្ធនឹងអំពើកាប់សម្លាប់ទៅកាត់ទោសឡើយ" ។

បុគ្គលផ្សេងគ្នាមានគំនិតនិងការយល់ឃើញខុសគ្នាចំពោះការផ្សះផ្សាបង្រួបបង្រួមជាតិនៅប្រទេសកម្ពុជា ។ លោកស្រី ជា វណ្ណាត បញ្ជាក់ថា សហគមន៍អន្តរជាតិ ខ្មែរក្រហម និងប្រជាជនសុទ្ធតែយល់ដឹងផ្សេងគ្នាអំពីការពិតដែលកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ ដូច្នេះ "ដើម្បីការផ្សះផ្សាបង្រួបបង្រួមជាតិឡើងវិញដំបូងត្រូវតែស្តាប់និងទទួលស្គាល់ការពិតរបស់គ្រប់ភាគីទាំងអស់និងរកវិធីដោះស្រាយដែលទាំងអស់គ្នាទទួលយកបាន" ។ លោក ឆាំង យុ បន្ថែមថា កេរដំណែលនៃការកាប់សម្លាប់មនុស្សនៅ



ជួនជីនិងជនរងគ្រោះនៃរបបខ្មែរក្រហមជួបសំណេះសំណាលជាមួយឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក
នៅនិវេសនដ្ឋានរបស់លោក ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៦

ក្នុងរបបខ្មែរក្រហមបានក្លាយជាស្រមោលអន្ទោលតាមប្រាណប្រជាជន ។ ដូច្នេះវិធីដោះស្រាយជាមួយកេរដំណែលនេះដាច់ខាតត្រូវតែធ្វើឡើងដោយមានការផ្សះផ្សារបួសផ្លូវចិត្ត និងការអប់រំដល់យុវវ័យអំពីអ្វីដែលបានកើតឡើង ។ ឡាមប៊ួន ឯកភាពតាមយោបល់របស់លោក ឆាំង យុ និងបានបន្ថែមថា "ប្រជាជនកម្ពុជាយល់ឃើញនិងទាមទារខុសៗគ្នា ដូច្នេះការទាមទាររបស់ប្រជាជនគ្រប់រូបគួរតែត្រូវបានយកចិត្តទុកដាក់ទើបអាចដោះស្រាយនិងផ្សះផ្សាបង្រួបបង្រួមគ្នាបានជោគជ័យ" ។

តាមរយៈការបង្ហាញនិងពិភាក្សាខាងលើ យើងឃើញថាប្រជាជនកម្ពុជាត្រូវការវិធីសាស្ត្រផ្សេងៗពីគ្នាដើម្បីដោះស្រាយបញ្ហាដែលបន្សល់ទុកដោយរបបខ្មែរក្រហម ។ ដូច្នេះតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមតែមួយគឺមិនទាន់គ្រប់គ្រាន់សម្រាប់ការផ្សះផ្សាបង្រួបបង្រួមជាតិនៅប្រទេសកម្ពុជាឡើយ ។ ការណ៍នេះរំពុកដល់សម្ដីរបស់ អាសេហ្វ ដែលបានលើកឡើងនៅក្នុងសេចក្ដីផ្ដើមរបស់អត្ថបទនេះថា "យុត្តិធម៌គឺជាការចាំបាច់ ប៉ុន្តែមិនគ្រប់គ្រាន់សម្រាប់ដំណើរការផ្សះផ្សាបង្រួបបង្រួមឡើយ" ។ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលផ្ដល់យុត្តិធម៌និងកសាងមូលដ្ឋានច្បាប់អាចជួយព្យាបាលរបួសផ្លូវចិត្តជនរងគ្រោះនៃរបបខ្មែរក្រហមបាន ។ ក៏ប៉ុន្តែជនរងគ្រោះនៃរបបខ្មែរក្រហមមិនត្រឹមតែទាមទារយុត្តិធម៌ទេ គឺនៅមានការទាមទារផ្សេងទៀត ហើយការទាមទារនោះតុលាការមិនអាចផ្ដល់ជូនបានឡើយ ឧទាហរណ៍ ជនរងគ្រោះដែលមិនសប្បាយចិត្តចំពោះការធ្វើដំណើរដោយសេរីរបស់ជនដៃដល់ថ្នាក់ក្រោមនៅក្នុងភូមិប្រជាជនដែលទាមទាររកការពិតនិងចង់ឲ្យមានការអប់រំអំពីរបបខ្មែរក្រហមដល់យុវវ័យជំនាន់ក្រោយ ជនរងគ្រោះមួយចំនួនទៀត ដែលមានវិបត្តិផ្លូវចិត្តធ្ងន់ធ្ងរដូចជា ភុំ, ជុច និង សំ ។ ការទាមទាររបស់ជនរងគ្រោះខាងលើត្រូវតែយកចិត្តទុកដាក់ និងជួយតាមវិធីផ្សេងៗពីគ្នា ។ វគ្គបន្ទាប់នៃអត្ថបទនេះនឹងពិភាក្សាដោះស្រាយបញ្ហាខាងលើ ។

## ជំពូកទីបួន
## គណៈកម្មការស្វែងរកការពិតសម្រាប់ប្រទេសកម្ពុជា

នៅក្នុងជំពូកមុន ខ្ញុំបានពន្យល់និងពិភាក្សាអំពីតួនាទីរបស់តុលាការក្នុងការដោះស្រាយបញ្ហាខ្មែរក្រហមនិងជំរុញដំណើរការផ្សះផ្សាបង្រួបបង្រួមជាតិ ហើយខ្ញុំក៏បានបញ្ជាក់ប្រាប់អំពីផល-វិបាករបស់តុលាការដែរ ។ សរុបមកបានសេចក្ដីថា តុលាការខ្មែរក្រហមតែមួយមិនគ្រប់គ្រាន់សម្រាប់ការផ្សះផ្សាបង្រួបបង្រួម



ជនរងគ្រោះនៅរបបខ្មែរក្រហមជួបសំណេះសំណាលជាមួយឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក នៅនិវេសដ្ឋានរបស់លោក ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៦

ជាតិនៅប្រទេសកម្ពុជានៅឡើយ ។ គណៈកម្មការស្វែងរកការពិតសម្រាប់ប្រទេសកម្ពុជានិងកម្មវិធីទ្រទ្រង់សំខាន់ផ្សេងទៀតត្រូវតែបង្កើតឡើង ហើយធ្វើប្រតិបត្តិការជាជំនួយបន្ថែមដល់ដំណើរការរបស់តុលាការ ទើបអាចជំរុញឲ្យការផ្សះផ្សារបង្រួបបង្រួមជាតិនៅប្រទេសកម្ពុជាស្ថិតស្ថេរយូរអង្វែង ។

## ១) អ្វីទៅជាគណៈកម្មការស្វែងរកការពិត?

នៅក្នុងជំពូកទីពីរ ខ្ញុំបានបង្ហាញអំពីចំណុចខ្សោយរបស់តុលាការរួមមាន ១) ការសួរនាំដេញដោលនៅក្នុងពេលជំនុំជម្រះអាចធ្វើឲ្យប្រជាជនឈឺចាប់ម្តងទៀត ។ ២) ការកាត់ទោសត្រឹមតែមេដឹកនាំបួនឬប្រាំនាក់គឺជាការផ្តល់យុត្តិធម៌មិនពេញលេញជូនជនរងគ្រោះ ។ ៣) ការចំណាយថវិកាដ៏ច្រើនសន្ធឹកសន្ធាប់លើតុលាការគឺជាការចំណាយឥតប្រយោជន៍ពីព្រោះជនរងគ្រោះមិនបានទទួលការជួយឧបត្ថម្ភ ។

ទិសដៅរបស់គណៈកម្មការស្វែងរកការពិតគឺដោះស្រាយបញ្ហាដែលបន្សល់ទុកពីអតីតកាលដូចទិសដៅរបស់តុលាការដែរ ប៉ុន្តែវិធីដោះស្រាយរបស់គណៈកម្មការស្វែងរកការពិតមានលក្ខណៈខុសពីវិធីដោះស្រាយរបស់តុលាការ ។ គណៈកម្មការស្វែងរកការពិតធ្វើការយ៉ាងពេញលេញជាមួយជនរងគ្រោះ ដើម្បីស្វែងរកមូលហេតុដែលនាំឲ្យមានការកាប់សម្លាប់និងដាក់ទោសចំពោះឧក្រិដ្ឋជន ។ ការដាក់ទោសរបស់គណៈកម្មការស្វែងរកការពិតគឺផ្តល់ឱកាសឲ្យឧក្រិដ្ឋជនរៀបរាប់ការពិត សុំទោសចំពោះការប្រព្រឹត្តិខុសរបស់ខ្លួន ហើយកែខ្លួននិងកសាងទំនាក់ទំនងថ្មីជាមួយប្រជាជន ។

នាពេលបច្ចុប្បន្ននេះ ប្រទេសជាច្រើនបានប្រើប្រាស់ទាំងតុលាការនិងគណៈកម្មការស្វែងរកការពិតដើម្បីដោះស្រាយបញ្ហាបន្សល់ទុកពីអតីតកាល ។ ជាក់ស្តែងដូចជាប្រទេសរ៉ាន់ដា ប្រទេសសៀរ៉ាឡេអូន និងប្រទេសទីម័រខាងកើតជាដើម ។ ប្រទេសរ៉ាន់ដាបានប្រើប្រាស់តុលាការព្រហ្មទណ្ឌអន្តរជាតិនិងតុលាការកាឆាឆា ។ ដូចគ្នានេះដែរ ប្រទេសសៀរ៉ាឡេអូនបានប្រើប្រាស់រួមគ្នារវាងតុលាការចម្រុះរវាងអន្តរជាតិនិងតុលាការក្នុងស្រុករួមជាមួយគណៈកម្មការស្វែងរកការពិត ។ ថ្មីៗនេះប្រទេសទីម័រខាងកើតក៏បានប្រើប្រាស់តុលាការរួមនឹងគណៈកម្មការស្វែងរកការពិតដើម្បីដោះស្រាយបញ្ហាដែលបន្សល់ទុកពីអតីតកាលនៅក្នុងប្រទេសរបស់ខ្លួនដែរ ។

ប្រព័ន្ធតុលាការកាឆាឆាត្រូវបានប្រើប្រាស់នៅក្នុងប្រទេសរ៉ាន់ដាក្នុងពាក់កណ្តាលឆ្នាំ២០០៣ដើម្បីជាជំនួយបន្ថែមដល់ដំណើរការតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ ដូចបានបង្ហាញក្នុងជំពូកទីពីរ តុលាការកាឆាឆាមិនត្រឹមតែជាយុទ្ធសាស្ត្រដោះស្រាយបញ្ហាអ្នកទោសដ៏ច្រើនសន្ធឹកសន្ធាប់ដែលជាប់នៅក្នុងមន្ទីរឃុំឃាំងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាយុទ្ធសាស្ត្រជំរុញឲ្យមានការផ្សះផ្សារបង្រួបបង្រួមគ្នាឡើងវិញរវាងជនជាតិហ៊ូទូនិងជនជាតិទុតស៊ីទៀតផង ។ លក្ខណៈពិសេសរបស់តុលាការកាឆាឆាគឺការចូលរួមរបស់ប្រជាជនក្នុងការស្វែងរកការពិត ការជំរុញឲ្យមានដំណើរការសុំទោសនិងលើកលែងទោស ។ ទោះជាយ៉ាងណាក្តី ប្រជាជនរ៉ាន់ដាមួយចំនួនមិនគាំទ្រដំណើរការរបស់តុលាការកាឆាឆា ដើម្បីកាត់ទោសឧក្រិដ្ឋជនប្រល័យពូជសាសន៍នោះទេ ហើយថែមទាំងបានចាត់ទុកតុលាការប្រជាជនគឺជាវិធីនិងជាគំនិតបង្កើតឡើងដោយជនជាតិហ៊ូទូដើម្បីដោះលែងឧក្រិដ្ឋជនហ៊ូទូឲ្យមានសេរីភាពឡើងវិញ ។

គណៈកម្មការស្វែងរកការពិតសម្រាប់ប្រទេសសៀរ៉ាឡេអូននិងប្រទេសទីម័រខាងកើតក៏ជួបប្រទះការប្រឆាំងនិងការគាំទ្រដូចករណីនៅប្រទេសរ៉ាន់ដាដែរ ។ នេះបានសេចក្តីថា ប្រជាជនមួយចំនួនពេញចិត្តនិងគាំទ្រគណៈកម្មការស្វែងរកការពិត ចំណែកឯប្រជាជនមួយចំនួនទៀតមិនពេញចិត្តនិងប្រឆាំងយ៉ាងដាច់ខាត ។ មូលហេតុដែលនាំឲ្យប្រជាជនគាំទ្រគណៈកម្មការស្វែងរកការពិតដោយសារ ទីមួយ ៖ គណៈកម្មការនេះមានទិសដៅធំធេងនិងច្បាស់លាស់ជាងតុលាការ ។ គណៈកម្មការស្វែងរកការពិតបំពេញបេសកម្មស្វែងរកមូលហេតុនៃការកាប់សម្លាប់ និងផលវិបាកនានារបស់ប្រជាជនដែលបន្សល់ទុកដោយការកាប់សម្លាប់ដើម្បីដោះស្រាយ ។ ទីពីរ៖ គណៈកម្មការស្វែងរកការពិតមានកាតព្វកិច្ចស្វែងរកការពិតដោយយល់ព្រមលើកលែងទោសចំពោះឧក្រិដ្ឋជនដែលសារភាពការពិតហើយសុំការលើកលែងទោស ។ គណៈកម្មការស្វែងរកការពិតមិនមែនជាតុលាការកាត់ទោសហើយក៏គ្មានអំណាចកាត់ទោសឧក្រិដ្ឋជនដែរ ។ ប្រជាជនដែលគាំទ្រគណៈកម្មការស្វែងរកការពិតយល់ថា រាល់ចំណុចរៀបរាប់ខាងលើនេះ

អាចធ្វើឲ្យប្រជាជនបង្រួបបង្រួមគ្នាឡើងវិញបន្ទាប់ពីបានដឹងអំពីការពិតនិងបានឮការសារភាពកំហុសនិងការសុំអភ័យទោសពីឧក្រិដ្ឋជន ។

មូលហេតុសំខាន់ចុងក្រោយដែលនាំឲ្យប្រជាជនគាំទ្រគណៈកម្មការស្វែងរកការពិត គឺដោយសារប្រជាជនធុញទ្រាន់នឹងសង្គ្រាមនិងការកាប់សម្លាប់ ។ ប្រជាជនចង់រស់នៅក្នុងសន្តិភាពនិងបង្រួបបង្រួមគ្នាឡើងវិញ ហើយប្រជាជនគិតថា ការបង្កើតតុលាការកាត់ទោសជនដែលបានប្រព្រឹត្តអំពើខុសឆ្គងក្នុងអតីតកាលអាចនាំឲ្យកើតមានសង្គ្រាមសាជាថ្មីម្តងទៀត ។ ការដឹងអំពីការពិតគឺជាកាសំខាន់ដូចប្រសាសន៍របស់ យូហ្កាយ៉ាន ថា “ខ្ញុំត្រៀមខ្លួនជាស្រេចដើម្បីអភ័យទោសឲ្យជនដែលប្រព្រឹត្តខុស ប៉ុន្តែខ្ញុំគ្រាន់តែចង់ដឹងថានរណាជាក្រិដ្ឋជន ហើយឧក្រិដ្ឋជននោះបានប្រព្រឹត្តអ្វីខុស” ។

ដូចបានរៀបរាប់ខាងលើ ប្រជាជនមួយចំនួនមិនគាំទ្រការបង្កើតគណៈកម្មការស្វែងរកការពិតឡើយ ។ មូលហេតុដែលប្រជាជនទាំងនោះមិនគាំទ្រឬប្រឆាំងនឹងគំនិតបង្កើតឲ្យមានគណៈកម្មការស្វែងរកការពិត ដោយសារ ទីមួយ ៖ គណៈកម្មការនេះគ្មានសិទ្ធិអំណាចដាក់ទោសឧក្រិដ្ឋជន ។ ប្រជាជនគិតថា ប្រទេសដែលទើបឆ្លងផុតពីសង្គ្រាមនិងការកាប់សម្លាប់ត្រូវតែពង្រឹងមូលដ្ឋានច្បាប់ឡើងវិញ ហើយការមិនដាក់ទោសឧក្រិដ្ឋជនគឺជាការជាន់ពន្លិចវិស័យច្បាប់ ហើយលើកទឹកចិត្តឲ្យមានអំពើកាប់សម្លាប់បន្តទៀតនៅថ្ងៃអនាគត ។ ទីពីរ ដោយសារប្រជាជនយល់ថាការពិតដែលគណៈកម្មការស្វែងរកការពិតទទួលបានមិនប្រាកដថាសំខាន់ហើយជាការពិតមួយរយភាគរយឡើយ ។ ប្រជាជនមួយចំនួនទៀតរិះគន់ការលើកលែងទោសដល់ឧក្រិដ្ឋជននិងការបង្ខំជនរងគ្រោះឲ្យយល់ព្រមលើកលែងទោសដល់ឧក្រិដ្ឋជន ។

## ៣) ករណីប្រទេសកម្ពុជា

មានចំណុចសំខាន់បីដែលទាក់ទងនឹងករណីប្រទេសកម្ពុជា ។ ទីមួយ ៖ រដ្ឋាភិបាលកម្ពុជាបច្ចុប្បន្នបានផ្តួលរំលំរបបខ្មែរក្រហមដោយសារគោលនយោបាយឈ្នះឈ្នះ ដែលផ្តល់ការលើកលែងទោសដល់ខ្មែរក្រហមជាការផ្លាស់ប្តូរនិងការទម្លាក់អាវុធ និងការចុះចូលមករួមរស់ជាមួយរដ្ឋាភិបាល ។ ទីពីរ ៖ ប្រជាជនកម្ពុជាភាគច្រើនរស់នៅក្នុងស្ថានភាពលំបាកនិងមានការចេះដឹងតិចតួច ។ ទីបី ៖ ប្រជាជនកម្ពុជាគោរពព្រះពុទ្ធសាសនា ។ ពុទ្ធឱវាទគឺអំពើល្អតែងឈ្នះអំពើអាក្រក់ ហើយវិធីសាស្ត្រដោះស្រាយបញ្ហាគឺយកឈ្នះអំពើអកុសលដោយកុសល និងយកឈ្នះសេចក្តីស្អប់ដោយសេចក្តីស្រលាញ់ ។ តើប្រទេសកម្ពុជាអាចផ្សះផ្សាបង្រួបបង្រួមជាតិឡើងវិញដោយបែបណា? តើកម្មវិធីទ្រទ្រង់ណាខ្លះដែលមានប្រយោជន៍ជួយដល់ប្រជាជនកម្ពុជានិងជនរងគ្រោះនៃរបបខ្មែរក្រហម? តើត្រូវរកការពិតតាមវិធីណា ហើយការអប់រំអំពីរបបខ្មែរក្រហមចំពោះយុវវ័យជំនាន់ក្រោយមានសារសំខាន់យ៉ាងណាដែរ?

គ្មានដំណោះស្រាយងាយស្រួលសម្រាប់បញ្ហាខាងលើ ហើយក៏គ្មានដំណោះស្រាយណាមួយដែលអាចតម្រូវចិត្តប្រជាជនកម្ពុជាគ្រប់រូបដែរ ។ លោក កៅ គីមហួន ប្រធានវិទ្យាស្ថានដើម្បីសហប្រតិបត្តិការនិងសន្តិភាពពន្យល់ថា ៖

បញ្ហាដែលបន្សល់ទុកពីរបបខ្មែរក្រហមគឺជាបញ្ហាដែលពិបាកដោះស្រាយបំផុត ។ ពេលនិយាយដល់របបខ្មែរក្រហមប្រជាជនគ្រប់រូបមានការឈឺចាប់ ។ ប្រវត្តិសាស្ត្រគឺមិនអាចលុបឬបន្ថែមបានឡើយ ។ ការសរសេរចងក្រងអំពីប្រវត្តិសាស្ត្រគឺជាការសំខាន់ ហើយការចងក្រងប្រវត្តិសាស្ត្រគឺដើម្បីអប់រំមនុស្សជំនាន់ក្រោយឲ្យរិះគិតពិចារណាមុននឹងសម្រេចធ្វើអ្វីមួយ ហើយយើងត្រូវតែរកវិធីដោះស្រាយបញ្ហាខ្មែរក្រហមដោយប្រុងប្រយ័ត្ន ។

ខ្ញុំឯកភាពនឹងគំនិតរបស់លោក កៅ គីមហួន ដែលថាយើងត្រូវតែពិចារណារកវិធីដោះស្រាយបញ្ហាដែលបន្សល់ទុកពីរបបខ្មែរក្រហមដោយប្រុងប្រយ័ត្ន ។ ជាមួយគ្នានេះ ខ្ញុំបន្ថែមថាវិធីដោះស្រាយជាមួយបញ្ហាដែលបន្សល់ទុកពីរបបខ្មែរក្រហមត្រូវតែផ្អែកលើសាសនាទំនៀមទម្លាប់និងប្រពៃណីខ្មែរ ។ ការប្រើប្រាស់វិធីសាស្ត្រដោយផ្អែកលើសាសនាប្រពៃណីអាចទាក់ទាញឲ្យប្រជាជនចូលរួម ។ ការចូលរួមរបស់ប្រជាជនកាន់តែច្រើននឹងជួយធ្វើឲ្យវិធីសាស្ត្រដោះស្រាយទទួលបានប្រសិទ្ធភាពកាន់តែខ្ពស់ ។ **(នៅមានត)**

**អៀ ម៉េងទ្រី**

# ការបែងចែកអំណាចនិងសារសំខាន់នៃឯករាជ្យភាពរបស់តុលាការ

ឯករាជ្យភាពនៃតុលាការគឺសំខាន់បំផុតក្នុងការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន និងក្នុងការបង្កើតរដ្ឋសេរីមួយដែលលើកកម្ពស់ដល់នីតិរដ្ឋ ។

យើងអាចជំទាស់ តាមឥរិយាបថរបស់រដ្ឋធម្មនុញ្ញប្រជាធិបតេយ្យអំណាចធំបំផុតរបស់រដ្ឋគឺស្ថិតនៅលើប្រជាពលរដ្ឋ ។ លក្ខណៈសំខាន់នៃរដ្ឋធម្មនុញ្ញប្រជាធិបតេយ្យគឺ រដ្ឋាភិបាលត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងឆន្ទៈរបស់ប្រជាពលរដ្ឋ មានន័យថា "រដ្ឋាភិបាលគឺជារបស់ប្រជាជនបង្កើតឡើង ដោយប្រជាជន និងធ្វើការបម្រើប្រយោជន៍ប្រជាជន" ។ នៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣នៃព្រះរាជាណាចក្រកម្ពុជាចែងថា "យើងជាប្រជាពលរដ្ឋនៃព្រះរាជាណាចក្រកម្ពុជាព្រមព្រៀងតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ថាប្រទេសកម្ពុជាបន្តមានព្រះមហាក្សត្រប្រកាន់របបសេរីនិយមនិងពហុបក្ស" ។

យោងតាមច្បាប់រដ្ឋធម្មនុញ្ញអំណាចកំពូលរបស់ប្រជាពលរដ្ឋត្រូវបានបង្ហាញនិងប្រើប្រាស់ តាមរយៈអ្នកតំណាងឬអ្នកបង្កើតច្បាប់ ដែលប្រជាជនបោះឆ្នោតជ្រើសរើស ក៏ប៉ុន្តែអ្នកតំណាងទាំងនោះបានលើកតម្កើងឋានៈរបស់ខ្លួនហួសពីទ្រឹស្តីរបស់រដ្ឋធម្មនុញ្ញបែបប្រជាធិបតេយ្យ ។

ចុះចំណែកតុលាការវិញយ៉ាងដូចម្តេចដែរ? អំណាចតុលាការកាន់តែឆ្ងាយហួសពីសេចក្តីសម្រេចរបស់ប្រជាជនទៅទៀត បើទោះជាប្រជាជនគ្រប់រូបជាសមាសភាពសំខាន់នៃរដ្ឋធម្មនុញ្ញប្រជាធិបតេយ្យក៏ដោយ ។ នៅប្រទេសកម្ពុជានិងនៅប្រទេសមួយចំនួនទៀត អំណាចតុលាការ មិនមែនមានកំណើតមកពីអង្គការតំណាងអ្នកច្បាប់ដែលប្រជាជនបោះឆ្នោតជ្រើសរើសទេ ហើយក៏មិនមែនមានប្រភពមកពីអំណាចដែលប្រើប្រាស់ហួសពីដែនសមត្ថភាពកិច្ចយុត្តាធិការ សេចក្តីសម្រេចចិត្ត ការត្រួតពិនិត្យនិងគំនិតរបស់ប្រជាជនដែរ ។ តាមច្បាប់រដ្ឋធម្មនុញ្ញ ប្រជាជនមិនត្រូវបាន អនុញ្ញាតឲ្យចូលរួមនៅក្នុងការជ្រើសរើសចៅក្រមនិងព្រះរាជអាជ្ញាទេ ដោយសារប្រជាជនមិន មែនជាអ្នកចូលរួមបោះឆ្នោតជ្រើសរើសតុលាការទេ ។ ប៉ុន្តែតុលាការត្រូវបានតែងតាំងដោយអង្គការ ដែលនៅក្នុងប្រទេសកម្ពុជាហៅថា ÷ "ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម" ដែលអះអាងថាជាស្ថាប័នឯករាជ្យទទួលខុសត្រូវក្នុងការជ្រើសរើស តម្លើងតំណែង ផ្លាស់ប្តូរ និងត្រួតពិនិត្យវិន័យលើសកម្មភាព ប៉ុន្តែឯករាជ្យភាពរបស់ស្ថាប័ននេះស្ថិតនៅចោទជាសំណួរនៅឡើយ ។ តិចឬច្រើន សមាសភាពនៃស្ថាបន័នេះផ្សំឡើងដោយអ្នកដែលចាត់តាំងពីបក្សនយោបាយ ។ បុគ្គលមួយដែលសម្គាល់ពីការគោរពចំពោះឯករាជ្យភាពរបស់តុលាការគឺព្រះមហាក្សត្រ ដែលជាប្រមុខនៃស្ថាប័ននេះ ។ ចាប់តាំងពីស្ថាបន័នេះកកើតឡើង ព្រះមហាក្សត្រមិនបានចូលរួមជាអធិបតីភាពនៅក្នុងអង្គប្រជុំ (ពេលដែលព្រះបាទនរោត្តម



នៅវាលពិឃាតបឹងដើងឯក

សីហនុ សោយរាជ្យ) ។ ព្រះអង្គចាត់តាំងប្រធានព្រឹទ្ធសភាឲ្យជំនួសវត្តមានរបស់ព្រះអង្គ ។ នេះបង្ហាញឲ្យឃើញច្បាស់ថា ការចាត់តាំងប្រធានព្រឹទ្ធសភាឲ្យដឹកនាំអង្គប្រជុំនេះគឺផ្ទុយស្រឡះពីគោលការណ៍នៃការបែងចែកអំណាចនិងតុល្យភាពអំណាច ឬការត្រួតពិនិត្យអំណាច ។ ហេតុនេះហើយ យើងអាចនិយាយបានថាតុលាការមិនបានឆ្លុះបញ្ចាំងពីឆន្ទៈរបស់ប្រជាជនឡើយ ។

ឯករាជ្យភាពរបស់តុលាការអាចនឹងត្រូវបានធានាតែក្នុងករណីដែលមានវត្តមាននៃរដ្ឋាភិបាលដែលបង្កើតឡើងដោយប្រជាជន ដារបស់ប្រជាជន និងធ្វើការបម្រើផលប្រយោជន៍ប្រជាជន ។ លក្ខណៈពិសេសមួយដែលត្រូវគេរកឃើញថាជាឧបករណ៍មួយសម្រាប់ធានានូវឯករាជ្យភាពនៃតុលាការ គឺការបែកអំណាចជាបី ÷ អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។ ប្រព័ន្ធតុល្យភាពអំណាចមួយត្រូវបានបង្កើតឡើង ។ ជាក់ស្តែង ការបែងចែកអំណាច និងតុល្យភាពអំណាចបានចែងយ៉ាងច្បាស់នៅក្នុងរដ្ឋធម្មនុញ្ញ ប៉ុន្តែនៅក្នុងការអនុវត្តន៍ជាក់ស្តែងអ្វីដែលមានចែងមិនបានយកមកប្រើប្រាស់ឡើយ ។

មានករណីជាច្រើន ដែលស្ថាប័ននីតិប្រតិបត្តិរំលោភលើអំណាចនិងឯករាជ្យភាពនៃតុលាការដោយបំពានសាលក្រមរបស់តុលាការ តួយ៉ាងដូចជាបញ្ជាឲ្យចាប់ខ្លួនជនជាប់ចោទ ដែលតុលាការបានសម្រេចដោះលែងរួចហើយ ឬក៏បញ្ជាឲ្យតុលាការដោះលែងជនសង្ស័យដែលបានចាប់ខ្លួនតាមដីការរបស់តុលាការជាដើម ។ នេះគួសបង្ហាញឲ្យឃើញច្បាស់ថា អំណាចនីតិប្រតិបត្តិដើរតួនាទីពីរគឺជាចៅក្រមផងជាព្រះរាជអាជ្ញាផងនៅពេលទន្ទឹមគ្នា ។

ការអះអាងមួយទៀតបានលើកឡើងថា ប្រទេសកម្ពុជាមិនបានគ្រប់គ្រងតាមឆន្ទៈរបស់ច្បាប់ដែលស្ថាបន័នីតិបញ្ញតិបានអនុម័តនោះទេ តែមានដំណើរការដោយអនុក្រឹត្យទៅវិញ ។ ច្បាប់ភាគច្រើនដែលសភាជាតិអនុម័តត្រូវពឹងផ្អែកទៅលើអនុក្រឹត្យដែលចេញដោយរដ្ឋាភិបាល (គណៈរដ្ឋមន្ត្រី) មុនពេលដែលច្បាប់នោះអាចអនុម័តឲ្យប្រើប្រាស់ជាផ្លូវការណ៍បាន ។ តាមការអនុវត្តន៍ជាក់ស្តែង អនុក្រឹត្យមិនដែលត្រូវបានជំទាស់ឬពិនិត្យធម្មនុញ្ញភាពឡើយ ច្បាប់ដែលបង្កើតដោយសភាជាតិទាមទារឲ្យមានការផ្តល់យោបល់ពីព្រឹទ្ធសភា ការត្រួតពិនិត្យធម្មនុញ្ញភាពដោយក្រុមប្រឹក្សាធម្មនុញ្ញ ។

ដោយហេតុនេះហើយ យើងចាំបាច់ត្រូវយល់ពីឆន្ទៈពិតប្រាកដនៃឯករាជ្យភាពរបស់វិស័យតុលាការ ។ ឆន្ទៈនេះគឺចង់ប្រមានការគោរពឯករាជ្យភាពរបស់តុលាការ ហើយការគោរពនេះគឺតម្រូវឲ្យបញ្ឈប់ទំនោរបំពារបំពានតុលាការឬចៅក្រមនៅពេលមានការខ្វែងគំនិតគ្នា ។ យើងមិនគួរភ្លេចថា នៅក្នុងចំនួនលើសលប់នៃករណីនានាមុនដំណើរការតុលាការរដ្ឋាភិបាលគឺជាភាគីមួយក្នុងចំណោមនោះ ។

ម្យ៉ាងវិញទៀត ចៅក្រម គួរតែមិនលម្អៀងនិងបង្ហាញអំពីសុក្រិតភាពនេះដែរ ។ ដូច្នេះ លើកឡើងថាប្រសិនបើផ្តល់អំណាចឥតព្រំដែនដល់ស្ថាប័ននីតិប្រតិបត្តិឬក៏ស្ថាប័ននយោបាយដើម្បីជ្រើសរើសមនុស្សនិងតែងតាំងជាចៅក្រមនៃតុលាការកំពូលអំណាចនោះ គឺនាំមកនូវសកម្មភាពប៉ះពាល់អាក្រក់ដល់ឯករាជ្យភាពរបស់វិស័យតុលាការ ។ ឯករាជ្យភាពនៃតុលាការអាចកើតមានឡើងដរាបណាការតែងតាំងចៅក្រមមិនចំណុះអ្នកនយោបាយ ។ ហេតុនេះ ហើយគោលការណ៍នេះគួរតែលើកឡើងពីរបៀបជ្រើសរើសចៅក្រមដែលអាចការពារមិនឲ្យការតែងតាំងចៅក្រមដោយហេតុផលមិនសមរម្យណាមួយ ។ បុគ្គលដែលត្រូវបានជ្រើសរើសសម្រាប់តំណែងក្នុងវិស័យតុលាការត្រូវតែជាបុគ្គលដែលមានភាពស្មោះត្រង់ គុណសម្បត្តិ សមត្ថភាពរួមផ្សំនឹងការហ្វឹកហ្វឺន និងចំណេះដឹងផ្នែកច្បាប់ ។ ដូចនេះហើយដំណើរការជ្រើសរើសចៅក្រមណាមួយពឹងផ្អែកលើសកម្មភាពទាក់ទងនឹងនយោបាយ ឬក៏ភាពស្មោះត្រង់ចំពោះនយោបាយគួរតែធ្វើការរឹតបន្តឹង ។

ដើម្បីធ្វើឲ្យគោលគំនិតនៃឯករាជ្យភាពរបស់តុលាការក្លាយជាការពិត តុលាការជាន់ខ្ពស់មានអភ័យឯកសិទ្ធិចៀសផុតពីការជ្រៀតជ្រែករបស់អង្គការនីតិប្រតិបត្តិ ។ មិនត្រូវឲ្យមានការជ្រៀតជ្រែកមិនសមរម្យឬគ្មានភ័ស្តុតាងច្បាស់លាស់នៅក្នុងនីតិវិធីរបស់តុលាការឡើយ ប្រសិនបើសាលក្រមរបស់តុលាការបដិសេធការសុំពិនិត្យសើរើឡើងវិញនោះ ។ គោលការណ៍នេះត្រូវតែយកមកអនុវត្តដោយមិនលម្អៀងលើការពិនិត្យសើរើ

របស់តុលាការ និងលើការបន្ថយបន្ថយរបស់រដ្ឋអំណាចឬការផ្លាស់ប្តូរលើការកាត់ទោសដែលដាក់ជូនដោយតុលាការឡើយ ។

កត្តាសំខាន់ដែលជួយឲ្យតុលាការមានឯករាជ្យភាពគឺបញ្ហាប្រាក់បៀវត្សរ៍ ។ ចៅក្រមគួរតែមានភាពម៉ឺងម៉ាត់នឹងមុខតំណែងសង្គម និងមានភាពថ្លៃថ្នូរ ដោយទទួលប្រាក់បៀវត្សរ៍ក្នុងកម្រិតសមរម្យ ។ ម្យ៉ាងវិញទៀត ច្បាប់គួរតែធានាឲ្យបាននូវអាយុនិងប្រាក់សោធននិវត្តន៍ឲ្យបានសមរម្យ ។ ចំពោះបញ្ហានេះរដ្ឋាភិបាលគួរតែពិចារណាត្រួតពិនិត្យឡើងវិញ នូវបំណែងចែកថវិកាឲ្យទៅក្រសួងយុត្តិធម៌និងប្រៀបធៀបថវិកានោះទៅនឹងសមាជិកសភានិងព្រឹទ្ធសភា ។ បើអាចទៅរួច ថវិកាស្វ័យតគួរតែបង្កើតឡើងសម្រាប់ដំណើរការតុលាការដើម្បីដាក់ខ្លួនឲ្យឆ្ងាយពីក្រសួងយុត្តិធម៌ ។

តាមរយៈការវាយតម្លៃដ៏ហ្មត់ចត់ខាងលើស្តីពីឯករាជ្យភាពរបស់តុលាការ និងការពិភាក្សារកដំណោះស្រាយពីបទល្មើសនៅក្នុងតុលាការ យើងបានសេចក្តីសន្និដ្ឋានមួយថា ឯករាជ្យភាពរបស់តុលាការគឺមានសារសំខាន់នៅក្នុងប្រធានបទធានាការពារសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋានដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញក៏ដូចជានៅក្នុងបរិបទសិទ្ធិមនុស្សដែលទទួលស្គាល់ជាអន្តរជាតិ ។ គ្មានកំណែទម្រង់ណាមួយសំខាន់ដល់ការរីកចម្រើនជឿនលឿនជាយូរអង្វែងខាងផ្នែកសិទ្ធិមនុស្សនៅកម្ពុជាជាងកំណែទម្រង់ប្រព័ន្ធតុលាការទេ ។ ជាការពិត គ្រប់ផ្នែកទាំងអស់នៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមនៅកម្ពុជាសុទ្ធតែទទួលការប៉ះពាល់ពីកង្វះខាតនៃប្រព័ន្ធ



តុលាការបច្ចុប្បន្ន ហើយការប៉ះពាល់នេះបានបង្កើតជាឧបសគ្គមួយចំពោះដំណើរការនេះ ។ មានតែតុលាការដែលមានជំហរឯករាជមាំទាំនិងប្រព័ន្ធតុលាការមួយដែលមានប្រសិទ្ធភាពប៉ុណ្ណោះដែលអាចបញ្ចប់និរទណ្ឌភាពនៅកម្ពុជាព្រមទាំងផ្តល់ឲ្យសាធារណជននូវជម្រើសផ្សេងក្រៅពីហិង្សាក្នុងការដោះស្រាយទំនាស់ ។ ប្រសិនបើប្រព័ន្ធយុត្តិធម៌មិនមានឯករាជ្យពីស្ថាប័ននីតិប្រតិបត្តិ ច្បាប់មិនអាចត្រូវបង្ខំឲ្យធ្វើអ្វីៗដើម្បីរដ្ឋាភិបាលនិងមន្ត្រីរបស់រដ្ឋាភិបាលឡើយ ។

ខណៈដែលឯករាជ្យភាពរបស់តុលាការសាបរលាប ហើយចៅក្រមដែលមានសម្បជញ្ញៈមិនប្រកាន់ប្រជាត្រូវបានតែងតាំង នោះភាពអនាធិបតេយ្យនិងការជ្រួលច្របល់ក្នុងស្ថាប័នច្បាប់ពិតជាកើតឡើងមិនខាន ។ នៅពេលដែលចៅក្រមដែលមានសម្បជញ្ញៈបត់បែនមិនច្បាស់លាស់និងស្ថិតនៅក្រោមបង្គាប់របស់ក្រុមអ្នកនយោបាយណាមួយ ឯករាជ្យភាពរបស់តុលាការនឹងអន់ខ្សោយ ហើយយុត្តិធម៌សង្គមនិងច្បាប់ទម្លាប់ផ្សេងៗនឹងក្លាយជាឥតបានការ ។

សមភាពនៃសិទ្ធិនិងការទទួលបានការការពារស្មើគ្នានៅចំពោះមុខច្បាប់គឺជាធាតុមួយក្នុងចំណោមធាតុសំខាន់បំផុតនៃសិទ្ធមនុស្ស និងអាចចាត់ទុកថាជាធាតុដែលដែលមានសារសំខាន់សម្រាប់ការអភិវឌ្ឍន៍ការគោរពសិទ្ធិជាក់លាក់ផ្សេងទៀត របស់មនុស្ស ។ ពេលដែលគោលការណ៍នេះត្រូវបានដកហូត ឬផ្តល់អាទិភាពចំពោះតែថ្នាក់លើឬអ្នកមានបុព្វសិទ្ធិ នោះសិទ្ធិស្របច្បាប់របស់មនុស្សនឹងត្រូវបានបំបាត់ទាំងស្រុង ហើយយើងគ្មានថ្ងៃទទួលបានយុត្តិធម៌ឡើយ ។

ប្រសិនបើយុត្តិធម៌សង្គមមិនអាចរកបាន មូលដ្ឋានសិទ្ធិមនុស្សនិងសេរីភាពមួយចំនួនដូចជាសិទ្ធិទទួលបានសន្តិសុខផ្នែករាងកាយនិងអាយុជីវិត សេរីភាពក្នុងការបញ្ចេញមតិយោបល់ការនិយាយស្តី ការបង្កើតសមាគមន៍ និងការផ្សព្វផ្សាយ មិនត្រូវបានធានាឡើយ ហើយច្បាប់ទម្លាប់ក៏មិនមានវត្តមាននៅក្នុងសង្គមដែរប្រសិនបើយើងមិនរឹតបន្តឹងនិងធានាឲ្យមានឯករាជ្យភាពរបស់តុលាការ ។

**មុត ចាន់ថា**

# លោក កូហ្វី អាណាន់ តែងតាំងចៅក្រមអន្តរជាតិ សម្រាប់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា

អ្នកនាំពាក្យរបស់អង្គការសហប្រជាជាតិបានប្រកាសថា នៅថ្ងៃ៨ ខែមីនា ឆ្នាំ២០០៦ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ បានផ្ញើជូននាយករដ្ឋមន្ត្រីកម្ពុជានូវបញ្ជីឈ្មោះចៅក្រមអន្តរជាតិនិងអ្នកជំនាញផ្នែកច្បាប់ដែលនឹងត្រូវតែងតាំងឲ្យបម្រើការនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលកើតឡើងនៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៧០ ។

នៅក្នុងលិខិតផ្ញើជូនសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន លោក កូហ្វី អាណាន់ បានណែនាំអ្នកជំនាញផ្នែកច្បាប់ចំនួន១២រូប រួមទាំងបេក្ខជន៧រូបសម្រាប់តំណែងចៅក្រមអន្តរជាតិ នៅក្នុងអង្គជំនុំជម្រះសាមញ្ញនៅក្នុងតុលាការកម្ពុជា ។

កិច្ចព្រមព្រៀងឆ្នាំ២០០៣រវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាមានចែងអំពីអង្គជំនុំជម្រះនៅសាលាដំបូងដែលមានសមាសភាពចៅក្រមកម្ពុជា៣រូបនិងចៅក្រមអន្តរជាតិ២រូប និងអង្គជំនុំជម្រះនៅសាលាកំពូលដែលមានចៅក្រមកម្ពុជា៤រូប និងចៅក្រមអន្តរជាតិ៣រូប ។ កិច្ចព្រមព្រៀងបានស្នើឲ្យលោកអគ្គលេខាធិការផ្តល់បញ្ជីឈ្មោះបេក្ខជនច្រើនជាង៧រូប ។

កិច្ចព្រមព្រៀងបានចែងថា ចៅក្រមអន្តរជាតិទាំងប្រាំរូបនឹងត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៃកម្ពុជា ។ បន្ថែមពីលើនេះ នៅក្នុងលិខិតរបស់លោក អាណាន់ លោកបានស្នើឲ្យសម្តេចនាយករដ្ឋមន្ត្រីបញ្ជូនបញ្ជីឈ្មោះនេះទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

នៅក្នុងកិច្ចព្រមព្រៀងដែលចុះហត្ថលេខាដោយអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា សាលាដំបូងនិងតុលាការកំពូលនៅក្នុងប្រព័ន្ធច្បាប់កម្ពុជានិងធ្វើការស៊ើបអង្កេតលើជនទទួលខុសត្រូវខ្ពស់បំផុតនៅក្នុងឧក្រិដ្ឋកម្ម និងការរំលោភច្បាប់ជាតិនិងអន្តរជាតិនៅអំឡុងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។

ថវិកាសម្រាប់ដំណើរការអង្គជំនុំជម្រះវិសាមញ្ញនេះរយៈពេលបីឆ្នាំមានទឹកប្រាក់ប្រមាណ៥៦,៣លានដុល្លារសហរដ្ឋអាមេរិក ក្នុងនោះ៤៣លានជាថវិកាចំណាយដោយអង្គការសហប្រជាជាតិ និង១៣,៣លានជាការផ្តត់ផ្គង់របស់រាជរដ្ឋាភិបាលកម្ពុជា ។

នៅក្នុងសន្និសីទរបស់អង្គការសហប្រជាជាតិគាំទ្រវត្តមានអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាដែលប្រព្រឹត្តទៅកាលពីឆ្នាំមុន លោក កូហ្វី អាណាន់ បានថ្លែងថា ឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម "មានចរិតលក្ខណៈនិងវិសាលភាពស៊ើរតែពិបាកនឹងយល់" ។ លោក អាណាន់ បានបន្ថែមទៀតថា "ជនរងគ្រោះនៃឧក្រិដ្ឋកម្មដ៏ព្រៃផ្សៃនេះបានរង់ចាំយុត្តិធម៌អស់រយៈពេលយ៉ាងយូរ" ។



ជនរងគ្រោះនៅរបបខ្មែរក្រហមជួបសំណេះសំណាលជាមួយឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកនៅនិវេសដ្ឋានរបស់លោក ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៦

# ជំនួយរបស់អង្គការសហប្រជាជាតិសម្រាប់ការជំនុំជម្រះក្តីវិសាមញ្ញនៅក្នុងតុលាការកម្ពុជា

កាលពីថ្ងៃទី៨ ខែមីនា ឆ្នាំ២០០៦ អគ្គលេខាធិការអង្គការសហប្រជាជាតិ បានផ្ញើលិខិតជូនសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន អំពីបេក្ខជនសម្រាប់តំណែងជាចៅក្រមអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សហព្រះរាជអាជ្ញាអន្តរជាតិ និងចៅក្រមសម្រាប់អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា សម្រាប់ការកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

នៅក្នុងឆ្នាំ២០០៣ រាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិបានឈានដល់កិច្ចព្រមព្រៀងរួមគ្នាមួយ ។ ក្នុងកិច្ចព្រមព្រៀងនេះ តុលាការមានពីរថ្នាក់ គឺ សាលាដំបូង និងសាលាកំពូល ។ សាលាដំបូងមានចៅក្រម៥រូប គឺចៅក្រមកម្ពុជា៣រូប និងចៅក្រមអន្តរជាតិ២រូប ។ សាលាកំពូលមានចៅក្រម៧រូប គឺចៅក្រមកម្ពុជា៤រូប និងចៅក្រមអន្តរជាតិ៣រូប ។ ក្នុងកិច្ចព្រមព្រៀងនេះដែរ ចៅក្រមអន្តរជាតិទាំង៥រូបត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជាចេញពីបញ្ជីបេក្ខជនចៅ-ក្រមអន្តរជាតិដែលមានឈ្មោះបេក្ខជនយ៉ាងតិច៧រូបដែលអគ្គលេខាធិការអង្គការសហប្រជាជាតិបានប្រគល់ជូន ។

អគ្គលេខាធិការអង្គការសហប្រជាជាតិបានផ្ញើបញ្ជីឈ្មោះបេក្ខជនជាចៅក្រមអន្តរជាតិចំនួន៧រូប ដូចខាងក្រោមនេះ ÷

- ◆ លោកស្រី ស៊ីលវៀ ខាតរ៉ាយ (ប្រទេសញូវហ្សេឡែន)
- ◆ លោកស្រី ក្លូឌៀ ហ្វេន្ស (ប្រទេសអូទ្រីស)
- ◆ លោក ចាន់ដ្រា នីហាល ចាយ៉ាស៊ីងហ្គេ (ប្រទេសស្រីលង្កា)
- ◆ លោក ម៉ាទីន ការ៉ុបឃីន (សហរដ្ឋអាមេរិក)
- ◆ លោកស្រី អែកនីសស្កា ក្លូណូវិកកា មីឡាត (ប្រទេសប៉ូឡូញ)
- ◆ លោក ហ្សង់ ម៉ាក ឡាវែរញ (ប្រទេសបារាំង)
- ◆ លោក ម៉ូតូ ណូហ៊ីជី (ប្រទេសជប៉ុន)

តាមកិច្ចព្រមព្រៀងនេះ ចៅក្រមស៊ើបអង្កេតកម្ពុជា១រូប និងចៅក្រមស៊ើបអង្កេតអន្តរជាតិ១រូបនឹងបម្រើការជាសហចៅក្រមស៊ើបអង្កេត ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ១រូបត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជាចេញពីបញ្ជីឈ្មោះបេក្ខជនជាចៅក្រមស៊ើបអង្កេតអន្តរជាតិចំនួន២រូប ដែលអគ្គលេខាធិការអង្គការសហប្រជាជាតិប្រគល់ជូន ។ បេក្ខជនជាចៅក្រមស៊ើបអង្កេតអន្តរជាតិ១រូបទៀតត្រូវតែងតាំងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ។

កាលពីថ្ងៃទី៧ ខែមីនា ឆ្នាំ២០០៦ដែរ អគ្គលេខាធិការអង្គការសហប្រជាជាតិបានបញ្ជូនឈ្មោះបេក្ខជនសហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលមានឈ្មោះដូចក្រោមនេះ ÷

- ◆ លោក ម៉ាកសែល ឡឺម៉ុង (ប្រទេសបារាំង)

អគ្គលេខាធិការអង្គការសហប្រជាជាតិបានសន្យាថានឹងបញ្ជូនឈ្មោះបេក្ខជនសហចៅក្រមស៊ើបអង្កេតបម្រុងនៅពេលក្រោយ ។

បន្ថែមពីនេះទៀត កិច្ចព្រមព្រៀងបានចែងអំពីព្រះរាជអាជ្ញាកម្ពុជា១រូបនិងព្រះរាជអាជ្ញាអន្តរជាតិ១រូប ដែលនឹងបម្រើការជាសហព្រះរាជអាជ្ញា ។ សហព្រះរាជអាជ្ញាអន្តរជាតិ១រូបត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជាចេញពីបញ្ជីឈ្មោះបេក្ខជនព្រះរាជអាជ្ញាអន្តរជាតិ២រូបដែលអគ្គលេខាធិការអង្គការសហប្រជាជាតិបានបញ្ជូនមក ។ សហព្រះរាជអាជ្ញាអន្តរជាតិ១រូបទៀតនឹងត្រូវជ្រើសតាំងជាសហព្រះរាជអាជ្ញាអន្តរជាតិបម្រុង ។

អគ្គលេខាធិការអង្គការសហប្រជាជាតិបានផ្ញើបញ្ជីឈ្មោះបេក្ខជនជាសហព្រះរាជអាជ្ញាអន្តរជាតិដូចខាងក្រោមនេះ ÷

- ◆ លោក ដូល ខូហ៊ី (សហរដ្ឋអាមេរិក)
- ◆ លោក រ៉ូបឺត ពីទីត (ប្រទេសកាណាដា)

ជាចុងក្រោយ កិច្ចព្រមព្រៀងដដែលនេះចែងអំពីចៅក្រម៥រូបសម្រាប់អង្គបុរេជំនុំជម្រះ ។ ចៅក្រម៣រូបនឹងត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ហើយចៅក្រម២រូបទៀតនឹងត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបន្ទាប់ពីមានការតែងតាំងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

អគ្គលេខាធិការអង្គការសហប្រជាជាតិបានបញ្ជូនបញ្ជី

ឈ្មោះបេក្ខជនពីររូបសម្រាប់តំណែងចៅក្រមនៃអង្គបុរេជំនុំជម្រះដូចខាងក្រោមនេះ ÷

◆ លោក រ៉ូវ៉េន ដោនណើង (ប្រទេសអូស្ត្រាលី)

◆ លោកស្រី ខាទិនកា ឡាហ៊ុល (ប្រទេសហូឡង់)

អគ្គលេខាធិការអង្គការសហប្រជាជាតិបានស្នើសុំឲ្យសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បញ្ជូនបញ្ជីឈ្មោះបេក្ខជនជាចៅក្រមសហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាកម្ពុជា ជូនទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជា ។

រហូតដល់មកពេលនេះពុំទាន់មានសញ្ញាណាមួយអំពីពេលវេលាដែលឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជានឹងប្រកាសអំពីបេក្ខជនដែលត្រូវតែងតាំងជាចៅក្រម សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា នៅឡើយទេ ។ **បាន ចំរើន**

# ការិយាល័យព័ត៌មានសាធារណៈ

“ការិយាល័យព័ត៌មានសាធារណៈ” នៃមជ្ឈមណ្ឌលឯកសារកម្ពុជាឥឡូវនេះបានចាប់ផ្តើមបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបស់របបកម្ពុជាប្រជាធិបតេយ្យនិងព្រឹត្តិការណ៍វិវត្តន៍នៃអង្គជំនុំជម្រះវិសាមញ្ញដែលនឹងត្រូវបង្កើតឡើងនៅពេលខាងមុខឆាប់ៗនេះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាមជ្ឈមណ្ឌលដែលប្រមូលផ្តុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារទាំងនេះរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

“ការិយាល័យព័ត៌មានសាធារណៈ” មានផ្តល់ជូននូវសេវា៤យ៉ាង ៖

**១) បណ្ណាល័យ** ៖ នៅក្នុងបណ្ណាល័យរបស់យើង សាធារណជនអាចអានឯកសារ សៀវភៅ និងទស្សនាវដ្តី ស្តាប់កាសែតសំឡេង ទស្សនាខ្សែភាពយន្តឯកសារ និងមើលរូបថតដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារដ្ឋានជាតិកម្ពុជា និងពីប្រភពផ្សេងៗទៀត ។

**២) មជ្ឈមណ្ឌលអប់រំ** ៖ មជ្ឈមណ្ឌលនេះមានបញ្ចាំងជូននូវខ្សែភាពយន្តឯកសារ និងបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជា-ធិបតេយ្យ ប្រធានបទទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ និងប្រធានបទដទៃៗទៀត ។ ភាពយន្តឯកសារអំពីខ្មែរក្រហមមានបញ្ចាំងជូនទស្សនានៅរៀងរាល់ថ្ងៃអង្គារនិងថ្ងៃព្រហស្បតិ៍ នៅវេលាម៉ោង៩ព្រឹកនិង៣រសៀល ។

**៣) ក្រុមការងារផ្នែកតុលាការ** ៖ ទីប្រឹក្សាផ្នែកឯកសារនិងផ្នែកច្បាប់របស់យើងនឹងផ្តល់ជំនួយផ្នែកស្រាវជ្រាវដល់អ្នកជំនាញផ្នែកច្បាប់កម្ពុជានិងអង្គការសហប្រជាជាតិដែលធ្វើការងារផ្នែកតុលាការ ក៏ដូចជាដល់សាធារណជនទូទៅដែរ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង អែម សុខឃីម តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។







# បទសុន្ទរកថាថ្លែងដោយឯកឧត្តម ស៊ាន វិសុទ្ធ
## ប្រធានការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា

## នៅក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងបន្ថែមចំនួនពីរ រវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ស្តីអំពីការកាត់សេចក្តី ក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាល នៃកម្ពុជាប្រជាធិបតេយ្យ

## ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦
## អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា

*សូមគោរពឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលសម្រាប់ការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម!*

*សូមគោរពឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិ អស់លោក លោកស្រី បងប្អូន ក្មួយៗនិស្សិតជាទីស្នេហា!*

*យើងទាំងអស់គ្នាមកជួបជុំគ្នានៅក្នុងបន្ទប់សវនាការនៅថ្ងៃនេះដើម្បីប្រារព្ធពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងបន្ថែមចំនួនពីររវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ។ បើទោះបីជាព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រថ្ងៃនេះមិនអាចប្រៀបប្រដូចទៅនឹងព្រឹត្តិការណ៍នៃការបង្កើតតុលាការជំនុំជម្រះក្តីក៏ដោយ ក៏ព្រឹត្តិការណ៍ក្នុងថ្ងៃនេះបានបង្ហាញពីសារសំខាន់ប្រហាក់ប្រហែលគ្នាក្នុងការបញ្ចប់ ក្របខណ្ឌច្បាប់សម្រាប់ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ៊ីស៊ីស៊ីស៊ី) ។*

*នាថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ កិច្ចព្រមព្រៀងរួមគ្នាមួយត្រូវបានចុះហត្ថលេខាដោយ ឯកឧត្តម ហេន ខូវែល និងឯកឧត្តម សុខ អាន ។ កិច្ចព្រមព្រៀងនេះបានបញ្ជាក់យ៉ាងច្បាស់ថា កិច្ចព្រមព្រៀងបន្ថែមចំនួនពីរនឹងត្រូវចុះហត្ថលេខាដើម្បីពន្យល់លម្អិតអំពីសិទ្ធិនិងកាតព្វកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ទាក់ទងនឹងបញ្ហាសន្តិសុខនិងសុវត្ថិភាព និងទាក់ទងនឹងបញ្ហាមួយចំនួនទៀត ដូចជា ការរៀបចំប្រព័ន្ធទឹកភ្លើង ការរៀបចំអគារ និងសេវាកម្មផ្សេងៗ ។ ចំណុចលម្អិតជាក់លាក់ដែលមានចែងក្នុងកិច្ចព្រមព្រៀងបន្ថែមទាំងពីរនេះត្រូវមានការព្រមព្រៀងគ្នាពីភាគីទាំងសងខាងជាមុនសិនមុនពេលនឹងអង្គជំនុំជម្រះវិសាមញ្ញដំណើរការ ។*

*ក្នុងរយៈកាលអន្តរាគមន៍ មានកិច្ចការក្រៅឆាកមួយចំនួនទៀតក៏ត្រូវបានធ្វើទាំងនៅទីក្រុងភ្នំពេញ និងនៅទីក្រុងញូវយ៉កសហរដ្ឋអាមេរិក ។ ជាការពិត ការងារសំខាន់គឺការខិតខំប្រឹងប្រែងក្នុងការធានា ដល់ផ្នែកហិរញ្ញវត្ថុសម្រាប់ការដំណើរការនៃអង្គជំនុំជម្រះវិសាមញ្ញនេះ ។ ក៏ប៉ុន្តែ ស្របពេលជាមួយនឹងការខិតខំប្រឹងប្រែងស្វែងរកថវិកា ក្រុមការងារដំបូងរបស់រាជរដ្ឋាភិបាលនិងអង្គការសហប្រជាជាតិត្រូវតែកំណត់តម្រូវការសម្រាប់អង្គជំនុំជម្រះវិសាមញ្ញជាមុនសិន ដូចជា ការផ្ទេរអគារពីអគ្គបញ្ជាការដ្ឋាន ការសាងសង់អគារបន្ថែមការិយាល័យអង្គជំនុំជម្រះវិសាមញ្ញ ការតែងតាំងបុគ្គលិកនិងមន្ត្រីខ្មែរនិងបរទេស និងការតាក់តែងរូបសញ្ញារបស់អង្គជំនុំជម្រះវិសាមញ្ញដោយនិមិត្តរូបយុត្តិធម៌កម្ពុជានាសម័យបុរាណរួមជាមួយនឹងមែកអូលីវតំណាងឲ្យសន្តិភាពរបស់អង្គការសហប្រជាជាតិ ។*

*ខ្ញុំសូមឆ្លៀតឱកាសនេះជម្រាបជូនថា ទោះបីជាទីតាំងអគារមានលក្ខណៈសមស្របសម្រាប់តុលាការហើយក៏ដោយ ក៏យើងនៅតែត្រូវការសាងសង់បន្ថែមដើម្បីបំពេញតម្រូវការអង្គជំនុំជម្រះ*

វិសាមញ្ញ ។ ដូចក្នុងថ្ងៃនេះ យើងបានដំឡើងកន្លាបណ្តោះអាសន្ន ដោយសារថាយើងនៅពុំទាន់មានថវិកាគ្រប់គ្រាន់សម្រាប់ការដំឡើងប្រព័ន្ធម៉ាស៊ីនត្រជាក់ ។ ទន្ទឹមនឹងនេះ ការសាងសង់របងខណ្ឌផ្តាច់អគារអង្គជំនុំជម្រះវិសាមញ្ញពីអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ការសាងសង់មន្ទីរឃុំឃាំង ការសាងសង់ផ្ទះសុវត្ថិភាពសម្រាប់សាក្សី ការធ្វើផ្លូវថ្នល់ ប៉ុស្តិ៍យាម និងទីកន្លែងសម្រាប់ចតយានជំនិះ ក៏ទន្ទឹងរង់ចាំជោគជ័យនៃការស្វែងរកថវិការបស់យើងដែរ ។

ខ្ញុំសូមអនុញ្ញាតយកឱកាសនេះសង្ខេបខ្លឹមសារនៃកិច្ចព្រមព្រៀងបន្ថែមពីរនេះ ។ កិច្ចព្រមព្រៀងបន្ថែមទីមួយគឺស្តីអំពីសន្តិសុខនិងសុវត្ថិភាពដែលនឹងត្រូវចុះហត្ថលេខាដោយអនុប្រធានការិយាល័យរដ្ឋបាល លោកស្រី មីសែល លី ជាតំណាងអង្គការសហប្រជាជាតិ និងឯកឧត្តម អែម សំអាន រដ្ឋលេខាធិការក្រសួងមហាផ្ទៃនិងជាប្រធានគណៈកម្មការសន្តិសុខសម្រាប់អង្គ







ជំនុំជម្រះវិសាមញ្ញជាតំណាងរាជរដ្ឋាភិបាលគូសបញ្ជាក់ថា ការទទួលខុសត្រូវដែលមាននៅក្នុងកិច្ចព្រមព្រៀងទៅលើបញ្ហាសន្តិសុខសុវត្ថិភាពនិងការការពារបុគ្គលិកទាំងអស់គឺជាភារៈរបស់រាជរដ្ឋាភិបាលកម្ពុជា (មាត្រា២៨) ។ កិច្ចព្រមព្រៀងបន្ថែមនេះនឹងបែងចែកការទទួលខុសត្រូវលើកិច្ចប្រតិបត្តិការបន្តបន្ទាប់រវាងអង្គការសហប្រជាជាតិ (លើបញ្ហាសន្តិសុខក្នុងបន្ទប់និងអគារសវនាការ) និងរាជរដ្ឋាភិបាលកម្ពុជា (លើបញ្ហាសន្តិសុខទូទៅនៅខាងក្រៅបរិវេណអង្គជំនុំជម្រះវិសាមញ្ញ) ។ កិច្ចព្រមព្រៀងនេះក៏ចែងអំពីសិទ្ធិនិងការទទួលខុសត្រូវរបស់មន្ត្រីសន្តិសុខទាំងសម្រាប់ភាគីកម្ពុជានិងអង្គការសហប្រជាជាតិ ដោយរាប់បញ្ចូលសិទ្ធិរបស់បុគ្គលិកអង្គការសហប្រជាជាតិក្នុងការនាំចូលឯកសណ្ឋាននិងកាន់អាវុធក្នុងពេលបំពេញភារកិច្ច ។

កិច្ចព្រមព្រៀងបន្ថែមទីពីរគឺស្តីអំពីការរៀបចំប្រព័ន្ធទឹកភ្លើង ការរៀបចំទីតាំងអគារ និងសេវាកម្មផ្សេងៗ ដែលចុះហត្ថលេខាដោយអនុប្រធានការិយាល័យរដ្ឋបាល លោកស្រី មីសែល លី ជាតំណាងអង្គការសហប្រជាជាតិ និងរូបខ្ញុំផ្ទាល់ ជាតំណាងរាជរដ្ឋាភិបាលកម្ពុជា គូសបញ្ជាក់ថា ការទទួលខុសត្រូវគឺស្ថិតនៅក្រោមកិច្ចព្រមព្រៀងរួម ក៏ប៉ុន្តែបានសង្កត់ធ្ងន់និងសង្ខេបលម្អិតថាតើភាគីណាមួយទទួលខុសត្រូវលើមុខចំណាយអ្វី ។ ខាងអង្គការសហប្រជាជាតិចំណាយទៅលើគ្រឿងបរិក្ខារ យានជំនិះ កុំព្យូទ័រនិងគ្រឿងបន្លាស់ (Hardware) និងកម្មវិធីកុំព្យូទ័រ (Software) ការចំណាយលើការប្រើប្រាស់ប្រព័ន្ធទូរគមនាគមន៍ ការសិក្សាបណ្តុះបណ្តាល ការការពារចុងចោទនិងសាក្សីនិងជនរងគ្រោះ ។ ខាងរាជរដ្ឋាភិបាលកម្ពុជាទទួលខុសត្រូវលើការផ្តល់ទីតាំងអគារសម្រាប់តុលាការ អគារការិយាល័យរដ្ឋបាល មន្ទីរឃុំខ្លួនចុងចោទ និងផ្ទះសុវត្ថិភាពសម្រាប់សាក្សី ទឹកភ្លើង និងសេវាកម្មទូរគមនាគមន៍ ។

ពិតណាស់ ការបែងចែកច្បាស់លាស់នូវការទទួលខុសត្រូវរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិគឺជាតម្រូវការដ៏ចាំបាច់ក្នុងការពង្រឹងការងាររបស់យើងក្នុងអំឡុងពេលប៉ុន្មានឆ្នាំខាងមុខនេះ ។ សេចក្តីព្រាងនៃកិច្ចព្រមព្រៀងបន្ថែមទាំងពីរត្រូវបានព្រមព្រៀងគ្នារួចរាល់កាលពីខែធ្នូឆ្នាំ២០០៥កន្លងទៅ ហើយឥឡូវនេះកិច្ចព្រមព្រៀងនេះត្រូវបានយកពិនិត្យនិងអនុម័ត ដោយរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ដើម្បីប្រគល់អំណាចទៅឲ្យអ្នកដែលនឹងចុះហត្ថលេខាលើឯកសារនេះនៅក្នុងថ្ងៃនេះ ។

ខ្ញុំសូមប្រគល់ជូនអនុប្រធានការិយាល័យរដ្ឋបាល លោកស្រី មីសែល លី ដែលជាតំណាងរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

# បទសុន្ទរកថាថ្លែងដោយលោកស្រី មីសែល លី

## អនុប្រធានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងជាអ្នកសម្របសម្រួលជំនួយរបស់អង្គការសហប្រជាជាតិ សម្រាប់អង្គជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម ហៅកាត់ថា UNAKRT

## ក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងបន្ថែមស្តីអំពីអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា នៅថ្ងៃអង្គារ ទី១៤ ខែមីនា ឆ្នាំ២០០៦ អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា

សូមគោរពឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលសម្រាប់ការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម ភ្ញៀវអន្តរជាតិ និងសហគមន៍ជាកិត្តិយស អ្នកតំណាងអង្គការក្រៅរដ្ឋាភិបាល អ្នកសារព័ត៌មាន សហការីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងអស់លោក លោកស្រី អ្នកនាងកញ្ញា ជាទីគោរព!

ថ្ងៃនេះគឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដ៏តូចមួយនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ នៅពេលបន្តិចទៀតនេះ យើងទាំងអស់គ្នានឹងធ្វើជាសាក្សីក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងបន្ថែមចុងក្រោយរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ដើម្បីចាប់ផ្តើមការងារក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ ។ ថ្ងៃនេះក៏ជាព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រមួយទៀតដែរ ។ ប្រមាណពីរបីថ្ងៃមុននេះ កៅអីនៅក្នុងបន្ទប់សវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញនេះនៅហ៊ុមព័ទ្ធទៅដោយថង់ផ្លាស្ទិកនៅឡើយ គ្មានប្រព័ន្ធទឹកភ្លើង ពោលគឺគ្រាន់តែជាបន្ទប់ទទេមួយតែប៉ុណ្ណោះ ។ យើងទាំងអស់គ្នាគឺអ្នកទីមួយដែលបានមកអង្គុយនៅក្នុងបន្ទប់សវនាការនេះ ។

ក្នុងពេលបន្តិចទៀត អគារនេះនឹងមានការផ្លាស់ប្តូរ ពីព្រោះចៅក្រមនឹងកាត់សេចក្តីលើគ្រប់សំណុំរឿងនៅទីនេះ ។ បន្ទាប់មកអ្នកបកប្រែនឹងត្រូវបកប្រែជាបីភាសា គឺភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង ។ បន្ទាប់ពីការកាត់សេចក្តីរបស់ចៅក្រម មណ្ឌលព័ត៌មាននឹងថតនិងផ្សព្វផ្សាយអំពីដំណើរការរបស់អង្គសវនាការដើម្បីឲ្យពិភពលោកបានដឹងឮ ។ កៅអីដែលឯកឧត្តម អន្តរជាតិ ភ្ញៀវកិត្តិយស អ្នកតំណាង សហការី អស់លោកនិងលោកស្រីកំពុងតែអង្គុយនេះ ប្រជាជនកម្ពុជានឹងមកអង្គុយធ្វើជាសាក្សីនៅក្នុងដំណើរការកាត់សេចក្តីមេដឹកនាំខ្មែរក្រហមដែលប្រជាជនកម្ពុជាទន្ទឹងរង់ចាំជាយូរមកហើយ ។

ព្រឹត្តិការណ៍ថ្ងៃនេះគឺជាលទ្ធផលដែលបានមកពីការគាំទ្រការខិតខំប្រឹងប្រែង និងការប្តេជ្ញាចិត្តពីប្រជាជន ។ ជាពិសេសខ្ញុំសូមកោតសរសើរចំពោះឯកឧត្តម ស៊ាន វិសុទ្ធ និងសហការីរបស់ឯកឧត្តម ដែលទទួលខុសត្រូវតាមជំនាញរបស់ខ្លួនក្នុងរយៈកាលនៃការរៀបចំដីសែនលំបាកនេះ ។ ការរៀបចំការិយាល័យមួយនេះពុំមែនការងាយស្រួលឡើយ ក៏ប៉ុន្តែជាសំណាងដែលយើងបានជ្រើសរើសក្រុមការងារដែលមានសមត្ថភាពល្អៗក្នុងការបំពេញកិច្ចការជាមួយយើង ហើយខ្ញុំមានជំនឿទុកចិត្តថាយើងនឹងនៅតែបន្តទំនាក់ទំនងក្នុងការងារដែលកំពុងតែលេចចេញជាផ្លែផ្កានេះ ។

ជាចុងបញ្ចប់ ខ្ញុំសូមឆ្លៀតក្នុងឱកាសនេះសូមថ្លែងអំណរគុណដល់អស់លោកលោកស្រីដែលបានចូលរួមក្នុងព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនៅក្នុងថ្ងៃនេះ ហើយការចូលរួមដ៏មានសារសំខាន់ពីសំណាក់សហគមន៍អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងអ្នកយកព័ត៌មាន គឺជាឧទាហរណ៍មួយដែលបង្ហាញឲ្យឃើញអំពីជោគជ័យនៃការងាររបស់យើងទាំងអស់គ្នា ។ ប៉ុន្មានខែខាងមុខនេះគឺជារយៈពេលដែលយើងទាំងអស់គ្នាត្រូវខិតខំប្រឹងប្រែងឲ្យអស់ពីសមត្ថភាពក្នុងការបំពេញកិច្ចការងាររបស់យើងទាំងអស់គ្នានៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ។ យើងកំពុងតែបន្តដំណើរការទៅមុខហើយ ក៏ប៉ុន្តែយើងនៅមានកិច្ចការដែលសេសសល់ជាច្រើនទៀតដែលត្រូវធ្វើ ។

ខ្ញុំដឹងហើយថា ដោយមានការគាំទ្រពីសំណាក់ឯកឧត្តម លោកជំទាវ អន្តរជាតិ តំណាងអង្គការក្រៅរដ្ឋាភិបាល អ្នកសារព័ត៌មាន អស់លោកនិងលោកស្រី អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានតួនាទីយ៉ាងសំខាន់ក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការសម្រេចបាននូវយុត្តិធម៌ ។

សូមអរគុណ ។

# បទសុន្ទរកថាថ្លែងដោយឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលសម្រាប់កិច្ចសហប្រតិបត្តិការ ជាមួយអ្នកជំនាញច្បាប់បរទេសនិងការរៀបចំដំណើរការការកាត់សេចក្តីមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់

## ក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងបន្ថែមចំនួនពីរ រវាងរាជរដ្ឋាភិបាលកម្ពុជានិង អង្គការសហប្រជាជាតិ ស្តីអំពីការកាត់សេចក្តីក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជា ប្រជាធិបតេយ្យ

## នាថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦
## អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា

ថ្ងៃនេះ ជាមួយនឹងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងបន្ថែមចំនួនពីរ យើងធ្វើសេចក្តីសម្រេចលើក្របខ័ណ្ឌច្បាប់សម្រាប់ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ៊ីស៊ីស៊ីស៊ី) ។

ទន្ទឹមនឹងនេះដែរ យើងអាចនិយាយបានថា យើងកំពុងតែស្ថិតនៅលើដំណើរដ៏ល្អមួយក្នុងការធ្វើសេចក្តីសម្រេចលើការរៀបចំថវិកា ហើយការរៀបចំស្ថាប័នថ្មីដែលមិនធ្លាប់មានពីមុនមកនោះក៏កំពុងតែដំណើរការដែរ ។

ជំហានដំបូង យើងទទួលបានអគារដ៏ល្អស្អាតមួយសម្រាប់សវនាការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម ដូចដែរអស់លោក លោកស្រីមើលឃើញផ្ទាល់នឹងភ្នែកហើយ ។ សាលសវនាការដ៏ថ្មីទំនើបនេះអាចផ្ទុកមនុស្សបានចំនួនជាង៥០០នាក់ឲ្យចូលរួមអង្កេតមើលដំណើរការ កាត់សេចក្តីនេះ ព្រមទាំងមានបន្ទប់ធំទូលាយសម្រាប់ធ្វើជាមណ្ឌលព័ត៌មានបន្ទប់ការិយាល័យធំទូលាយដែលអាចផ្ទុកបុគ្គលិកធ្វើការបាន៣០០នាក់ និងមានបរិវេណធំល្មមគ្រប់គ្រាន់ដែលអាចសាងសង់មន្ទីរឃុំឃាំង ផ្ទះសុវត្ថិភាពទុកសម្រាប់សាក្សីនិងជនរងគ្រោះដែលនឹងមកធ្វើជាកសិណសាក្សី និងទីកន្លែងចតយានជំនិះធំទូលាយទុកសម្រាប់អ្នកយកព័ត៌មាន និងសាធារណជន ។

ជំហានទីពីរ ទាំងភាគីកម្ពុជានិងអង្គការសហប្រជាជាតិចាប់ផ្តើមដំណើរការតែងតាំងបេក្ខជនដែលមានជំនាញនិងសមត្ថភាពខ្ពស់សម្រាប់តួនាទីនៅក្នុងការិយាល័យរដ្ឋបាលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ខ្ញុំសូមយកឱកាសនេះជម្រាបជូនឯកឧត្តមប្រធានការិយាល័យរដ្ឋបាល (ឯកឧត្តម ស៊ាន វិសុទ្ធ) និងលោកស្រីអនុប្រធានការិយាល័យរដ្ឋបាល (លោកស្រី មីសែល លី) ដែលបានសហការគ្នាអស់រយៈពេលមួយខែកន្លងមកនេះ ក្នុងស្មារតីស្និទ្ធស្នាលគ្នានិងសហប្រតិបត្តិការជាវិជ្ជមានក្នុងការជ្រើសរើសបុគ្គលិកសម្រាប់ការរៀបចំទាំងបួនផ្នែកនៃការិយាល័យរដ្ឋបាល ។

ជំហានទីបី លោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានផ្ញើបញ្ជីឈ្មោះបេក្ខជនសម្រាប់តួនាទីជាចៅក្រម សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ព្រមទាំងចៅក្រមបម្រុង ជូនរាជរដ្ឋាភិបាលកម្ពុជាពិនិត្យសម្រេច ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ និងរដ្ឋជាសមាជិកដែលបានស្នើបញ្ជូនបុគ្គលិកដែលមានសមត្ថភាព និងបទពិសោធន៍ខ្ពស់មកពីគ្រប់ទិសទីនៃពិភពលោក ។ ឥឡូវនេះដែរ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមក៏កំពុងតែជ្រើសរើសបេក្ខជនចេញពីបញ្ជីឈ្មោះ ហើយនឹងប្រកាសឈ្មោះចៅក្រម សហចៅក្រមស៊ើបអង្កេត និងព្រះរាជអាជ្ញាកម្ពុជានិងអន្តរជាតិក្នុងពេលឆាប់ៗនេះ ។ ខ្ញុំមានជំនឿយ៉ាងមុតមាំថា ចៅក្រមនិងព្រះរាជអាជ្ញា ដែលមានឈ្មោះល្បីៗទាំងនេះនឹងធ្វើការជាមួយគ្នាបានយ៉ាងល្អក្នុងការកសាងស្ថាប័នមួយដែលពុំធ្លាប់មានពីមុនមកនៅក្នុងប្រទេសកម្ពុជា ព្រោះថាអង្គជំនុំជម្រះវិសាមញ្ញនេះគឺជាតុលាការជាតិថ្មីមួយដែលមានលក្ខណៈជាអន្តរជាតិ ។ ប្រសិនបើយើងសម្រេច ជោគជ័យក្នុងកិច្ចខិតខំ

ប្រើនប្រែងធ្វើឲ្យលេចចេញនូវរូបរាងតុលាការដែលមានអំណាចឯករាជ្យ និងមានសមត្ថភាពសមត្ថភាព ដែលយើងគិតក្នុងចិត្តយើងទាំងអស់គ្នានឹងមិនគ្រាន់តែបង្កើតតុលាការគំរូមួយសម្រាប់ជាបទពិសោធន៍ដល់កម្ពុជាប៉ុណ្ណោះទេ ថែមទាំងនឹងបង្កើតនូវគំរូយុត្តិធម៌អន្តរជាតិថ្មីមួយជាប្រវត្តិសាស្ត្រ ។

ខ្ញុំសូមឆ្លៀតយកឱកាសនេះថ្លែងអំណរគុណចំពោះបុគ្គលិកទាំងអស់នៃលេខាធិការដ្ឋានអង្គការសហប្រជាជាតិមានលោក ហេន ខូវែល អ្នកបន្តពីលោកដែលជាទីប្រឹក្សាច្បាប់ គឺលោក នីកូឡា មីសែ្សល និងក្រុមការងារនៃការិយាល័យកិច្ចការច្បាប់ក្រសួងកិច្ចការនយោបាយ ការិយាល័យក្រុមអ្នកត្រួតពិនិត្យ និងតំណាងអង្គការសហប្រជាជាតិប្រចាំនៅទីក្រុងភ្នំពេញ ។

ខ្ញុំសូមសម្តែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិដែលបន្តផ្តល់ជំនឿទុកចិត្ត







និងការប្តេជ្ញាចិត្តចំពោះដំណើរការនេះ ។ ប្រសិនបើគ្មានការចូលរួមចំណែកពីរដ្ឋជាសមាជិកទាំងនេះទេ យើងក៏ពុំមានពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងបន្ថែមនេះនៅក្នុងថ្ងៃនេះដែរ ។ ដូចនេះ យើងសូមសម្តែងការកោតសរសើរចំពោះការគាំទ្រនិងការផ្តល់មតិយោបល់ពីប្រទេសទាំងអស់ដែលមានចំណាប់អារម្មណ៍ (GIS) ។ នៅក្នុងរយៈពេលប៉ុន្មានខែថ្មីៗនេះ រដ្ឋដែលរួមវិភាគទានដល់ប្រទេសកម្ពុជាមាន ប្រទេសជប៉ុន ឥណ្ឌា បារាំង អាល្លឺម៉ង់ ចក្រភពអង់គ្លេស អូស្ត្រាលី ហូល្លង់ កាណាដា សហភាពអឺរ៉ុប ន័រវ៉េ អូទ្រីស ដាណឺម៉ាក ប៊ែលហ្សិក អៀរឡង់ ស៊ុីស សាធារណរដ្ឋកូរ៉េ លុចសំបួរ ថៃ អារម៉េនី និងណាមីប៊ី ។

ខ្ញុំមានសេចក្តីរំភើបរីករាយយ៉ាងខ្លាំងដែលបានដឹងថាមានការចូលរួមវិភាគទានពិសេសចំនួនពីរទៀត ។ យើងខ្ញុំយល់យ៉ាងច្បាស់អំពីសារសំខាន់នៃការផ្តល់ថវិកាចំនួន ១,០០០ដុល្លារអាមេរិកពីប្រទេសអារម៉េនី និង៥០០ដុល្លារអាមេរិកពីប្រទេសណាមីប៊ី ព្រោះយើងបានដឹងហើយថាប្រទេសទាំងពីរនេះមានរឿងឈឺចាប់ច្រើនប៉ុនណា ។ ការរួមវិភាគទានរបស់ប្រទេសទាំងពីរនេះគឺកើតចេញពីទឹកចិត្តរបស់ខ្លួនក្នុងការជួយជំរុញឲ្យប្រទេសកម្ពុជាដើរនៅលើផ្លូវដ៏ត្រឹមត្រូវក្នុងការកែតម្រូវកំហុសប្រវត្តិសាស្ត្ររបស់កម្ពុជា ព្រោះប្រទេសទាំងពីរក៏កំពុងតែធ្វើកំណែតម្រូវកំហុសប្រវត្តិសាស្ត្ររបស់ខ្លួនដែរ ។

យើងចំណាយពេលអស់យ៉ាងយូរទើបឈានមកដល់ដំណាក់កាលនេះ ក៏ប៉ុន្តែពេលនេះយើងខិតជិតទៅដល់ការបង្កើតចុងក្រោយនូវនីតិវិធីតុលាការដែលទទួលស្គាល់ជាអន្តរជាតិ ក្នុងការដោះស្រាយបញ្ហាឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងប្រទេសកម្ពុជាចន្លោះឆ្នាំ១៩៧៥-១៩៧៩ ។ ខ្ញុំសូមសម្តែងការគាំទ្រចំពោះបុគ្គលិកទាំងអស់ដែលកំពុងតែបំពេញការងារនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលខំលះបង់អស់ពីកាយចិត្តក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនេះ ។ ខ្ញុំសូមអំពាវនាវដល់បុគ្គលិកទាំងអស់ដែលកំពុងអង្កេតកិច្ចការអង្គជំនុំជម្រះវិសាមញ្ញទាំងនៅក្នុងនិងក្រៅប្រទេស មិនថាអ្នកសារព័ត៌មាន អង្គការក្រៅរដ្ឋាភិបាល រដ្ឋាភិបាល និងសហគមន៍ ជួយពង្រឹងការគាំទ្រឧបត្ថម្ភអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងបណ្តាឆ្នាំខាងមុខនេះ ដើម្បីយើងអាចមានលទ្ធភាពបំពេញកាតព្វកិច្ចជាប្រវត្តិសាស្ត្ររបស់យើងជូនដល់ជនរងគ្រោះដោយសារឧក្រិដ្ឋកម្ម ។

សូមថ្លែងអរគុណចំពោះការចូលរួមក្នុងពិធីចុះហត្ថលេខានេះ

# ឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមនិងតម្រូវការយុត្តិធម៌

## សុន្ទរកថារបស់លោកឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ចូសេហ្វ មូស្សូមេលី នៅក្នុងឱកាសជួបសំណេះសំណាលជាមួយនឹងជនរងគ្រោះដោយរបបខ្មែរក្រហម នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៦

ឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មដ៏ធំបំផុតប្រចាំសតវត្សរ៍ទី២០ បានកន្លងទៅដោយមិនមានការដាក់ទណ្ឌកម្មរហូតដល់៣០ ឆ្នាំ ។ ដូចដែលលោក-លោកស្រីបានជ្រាបហើយក្នុងចន្លោះពីថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៨ មករា ឆ្នាំ១៩៧៩ គឺក្នុងរយៈពេលតែជិតបួនឆ្នាំប៉ុណ្ណោះ របបខ្មែរក្រហមបានធ្វើទារុណកម្ម បង្អត់អាហារ និងសម្លាប់ (“កម្ទេច” គឺជាពាក្យដែលខ្មែរក្រហមចូលចិត្តប្រើ) ប្រជាជនកម្ពុជាអស់២,២លាននាក់ ។ ចំនួននេះស្មើនឹងចន្លោះពីមួយភាគបួនទៅមួយភាគបីនៃចំនួនប្រជាជនទាំងអស់ ។ គ្មាននរណាម្នាក់បានរួចខ្លួនពី“អ្នករំដោះប្រជាជន” ទាំងអស់នេះទេ ។ បញ្ជីរាយនាមសត្រូវរបស់ខ្មែរក្រហមវែងណាស់ រួមមានជនជាតិអ៊ីស្លាម ជនជាតិភាគតិចវៀតណាម ព្រះសង្ឃ អ្នកទីក្រុង អ្នកដែលមានសញ្ញាប័ត្រ អ្នកពាក់វ៉ែនតា ជាពិសេសកម្មាភិបាលខ្មែរក្រហមខ្លួនឯងដែលត្រូវអង្គការសង្ស័យថាក្បត់ដែរ ។ ក្រុមទាំងនេះនិងអ្នកដទៃជាច្រើនទៀត រួមមាន ភរិយា ស្វាមី និងកូន ត្រូវបានកម្ចាត់ទាំងបុសនៅក្នុងរបបប្រល័យពូជសាសន៍ដែលសាហាវបំផុតមិនធ្លាប់មានពីមុនមក ។

ហេតុអ្វីបានជាខ្ញុំនិយាយថា “ជារបបប្រល័យពូជសាសន៍ដែលមិនធ្លាប់មាន” នៅពេលដែលពិភពលោកមានការប្រកួតប្រជែងយ៉ាងតឹងតែងហើយដែលជួនកាលហាក់ដូចជាបាត់បង់អស់នូវគុណធម៌និងសេចក្តីអាណិតអាសូរចំពោះអ្នកដទៃដូច្នេះ? ពីព្រោះនេះជារបបប្រល័យពូជសាសន៍តែមួយគត់ដែលមិនបាននាំអ្នកជាប់ទោសចំពោះបទក្រិដ្ឋនេះមកទទួលខុសត្រូវចំពោះមុខច្បាប់ឡើយ ។ ក្នុងករណីអំពើប្រល័យពូជសាសន៍នៅ បូស្នៀ ស៊ែបប៊ីលីបេរី អេត្យូពី និង រ៉្វាន់ដា ជនរងគ្រោះ ក្រុមគ្រួសាររបស់ជនរងគ្រោះ និងសហគមន៍អន្តរជាតិ សុទ្ធតែបានទទួលយុត្តិធម៌និងបានសងសឹកនៅក្នុងកម្រិតណាមួយតាមរយៈសាលាក្តីនូរីមប៊ឺកនិងសវនាការថ្នាក់ជាតិ និងអន្តរជាតិក្រោយៗទៀត ប៉ុន្តែករណីដូចគ្នានេះមិនបានកើតឡើងនៅប្រទេសកម្ពុជាទេ ។



ជនរងគ្រោះនៅរបបខ្មែរក្រហមជួបសំណេះសំណាលជាមួយលោកឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកនៅនិវេសនដ្ឋានរបស់លោក ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៦

ថ្មីៗនេះ យើងបានឃើញមានការរីកចម្រើនខ្លះក្នុងការបង្កើតសាលាក្តីខ្មែរក្រហម ដោយមានកិច្ចសហការជាមួយអង្គការសហប្រជាជាតិ ប៉ុន្តែយើងមានពេលវេលាកាន់តែតិចទៅៗ ដោយសារឃាតកទាំងនោះមានវ័យកាន់តែចាស់ និងស្លាប់ជាបណ្តើរៗ ប៉ុន្តែការឈឺចាប់

និងរន្ធត់ដែលខ្មែរក្រហមបង្កឡើងមិនគួរនឹងបណ្តោយឲ្យបាត់បង់ទៅមិនគួរបណ្តោយឲ្យរលុបបាត់ឡើយ ។

តើតុលាការនេះមានប្រយោជន៍អ្វី? អ្នកខ្លះនិយាយថា ការចំណាយថវិកាដែលមានតិចតួចទៅលើឧក្រិដ្ឋកម្មដែលមានចំណាស់៣០ឆ្នាំទៅហើយ ក្នុងខណៈពេលដែលប្រទេសកម្ពុជាទទួលរងនូវបញ្ហាបន្ទាន់ផ្សេងទៀតជាច្រើននោះ ជារឿងមួយដែលមិនស័ក្តិសម ។ ខ្ញុំសង្ឃឹមថា ប្រជាជនកម្ពុជាភាគច្រើនមិនយល់ស្របនឹងការអះអាងទេ ។ ក្នុងប្រទេសកម្ពុជា ប្រជាជនកម្ពុជាភាគច្រើនមិនយល់ស្របនឹងការអះអាងនេះទេ ។ ក្នុងប្រទេសកម្ពុជា អ្នកដែលបានប្រព្រឹត្តបទឧក្រិដ្ឋប្រល័យពូជសាសន៍ទាំងនោះភាគច្រើនរស់នៅយ៉ាងសុខសាន្តមានសេរីភាព ថែមទាំងហ៊ឺហាទៀតផង ជាមួយនឹងជនរងគ្រោះដែលខ្លួនបានធ្វើបាប ។ មិនមានគ្រួសារណាមួយក្នុងប្រទេសកម្ពុជា ដែលមិនរងគ្រោះពីរបបប្រល័យពូជសាសន៍នោះឡើយ ។ អ្នករាល់គ្នាដែលមានជីវិតនៅថ្ងៃនេះ សុទ្ធតែមាន ឪពុក ម្តាយ បងប្អូន មីង និងពូ បានស្លាប់នៅក្នុងការសម្លាប់រង្គាលនោះ ។



លោកឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ចូសេហ្វ មូស្សូមេលី

ខ្មែរក្រហមបានប្រកាសថា ខ្លួននឹងនាំប្រទេសកម្ពុជាទៅកាន់ “ឆ្នាំសូន្យ” ។ ខ្មែរក្រហមបានរក្សាពាក្យសន្យារបស់ខ្លួនបានយ៉ាងល្អ ហើយនៅពេលនោះគឺ៣០ឆ្នាំក្រោយមកប្រទេសនេះនៅតែបាត់បង់និងបាក់បែកនៅឡើយ ។ ការបែកបាក់របស់ប្រទេសកម្ពុជាមិនមែនដោយសារតែនយោបាយនិងសេដ្ឋកិច្ចប៉ុណ្ណោះទេ វាជាការបែកបាក់នូវប្រព័ន្ធច្បាប់ផ្លូវចិត្តនិងស្មារតី ។ រាល់កំហុសឆ្គងទាំងឡាយក្នុងសង្គមកម្ពុជាបច្ចុប្បន្នរួមមានការជួញដូរមនុស្ស ការជួញដូរថ្នាំញៀន ការលួចបន្លំធនធាននិងវប្បធម៌ និងអំពើពុករលួយដែលជ្រៀតចូលទៅគ្រប់ស្រទាប់រដ្ឋាភិបាល ទាំងអស់នេះសុទ្ធតែត្រូវបានធ្វើឲ្យកាន់តែធ្ងន់ធ្ងរឡើងដោយសារបរាជ័យរបស់សហគមន៍អន្តរជាតិក្នុងការនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោសចំពោះមុខច្បាប់ ។

វប្បធម៌និទណ្ឌភាពដែលយើងឃើញនៅក្នុងសង្គមកម្ពុជាសព្វថ្ងៃបានចាក់ឫសយ៉ាងជ្រៅទៅក្នុងជំនឿដែលមិនអាចប្រកែកបានរបស់ប្រជាជនកម្ពុជាដែលជឿថា គ្មានបទល្មើសណាដែលធំរហូតដល់ថ្នាក់ចាំបាច់ត្រូវតែទទួលទណ្ឌកម្មនោះទេ ហើយថា ទោះជាប្រជាជនកម្ពុជាណាម្នាក់ធ្វើអ្វីក៏ដោយ ក៏មិនមានបញ្ហាអ្វីដែរ ពីព្រោះវាមិនមានអ្វីដែលអាក្រក់ជាងអ្វីដែលខ្មែរក្រហមធ្វើនោះទេ ។ សាលាក្តីខ្មែរក្រហមជាជំហានចាំបាច់ដំបូងដើម្បីព្យាបាលរបួសដែលមានចំណាស់៣ ទសវត្សរ៍ ដែលនៅមិនទាន់ជាសះស្បើយនៅឡើយ ។ ការរាំងស្ទះដល់ការរីកចម្រើននិងកំណែទម្រង់របស់ប្រទេសកម្ពុជានឹងនៅតែមានលុះត្រាណាតែយុត្តិធម៌ក្នុងកម្រិតណាមួយត្រូវបានរកឃើញ ។ អ្នកទាំងឡាយដែលបានស្លាប់និងទទួលរងគ្រោះមរណភាពនិងការឈឺចាប់របស់គាត់ត្រូវតែបានទទួលស្គាល់ថាជាការពិតនិងត្រូវតែបានគោរពបូជា ។ ជនរងគ្រោះនៃរបបខ្មែរក្រហមសមនឹងទទួលបាននូវយុត្តិធម៌ ។ ជនរងគ្រោះនៃរបបប្រល័យពូជសាសន៍ទាមទារឲ្យមានយុត្តិធម៌ ។ វាជាសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានយុត្តិធម៌ ហើយវាជាកាតព្វកិច្ចរបស់យើងក្នុងការធានាឲ្យមានយុត្តិធម៌ ។

# ដំណើរស្វែងរកកូនស្រី

បុរសវ័យចំណាស់ម្នាក់ឈ្មោះ ជន់ សែម អាយុ៨៤ឆ្នាំ រួមជាមួយជន្ទងនិងកូនប្រសាស្រីរបស់គាត់ កាន់ទស្សនាវដ្តីស្វែងរកការពិតលេខ៦៨និងប្រវត្តិរូបរបស់កូនស្រីរបស់គាត់មកដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយជំនឿចិត្តយ៉ាងមុតមាំថារូបថតនៅលើក្របទស្សនាវដ្តីដែលគាត់កំពុងតែកាន់គឺជារូបកូនស្រីរបស់គាត់ដែលបែកគ្នាហើយ បាត់ដំណឹងតាំងពីឆ្នាំ១៩៧៣ ។ បន្ទាប់ពីបានដឹងថារូបនោះមិនមែនជាកូនស្រីរបស់គាត់ អ៊ំសែម ធ្លាក់ទឹកមុខបង្ហាញពីអារម្មណ៍អស់សង្ឃឹមជាខ្លាំង ។

អ៊ំសែម មានស្រុកកំណើតនៅភូមិញ្ញោ ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ សព្វថ្ងៃគាត់រស់នៅស្រុកអង្គស្នួល ខេត្តកណ្តាល ។ កូនស្រីដែល អ៊ំសែម កំពុងតែស្វះស្វែងរកគឺកូនស្រីទី២ឈ្មោះ ជន់ អូន ។ ជន់ អូន បានចេញពីផ្ទះទៅបម្រើបដិវត្តន៍នៅឆ្នាំ១៩៧៣ ។ កាលណោះកងទ័ពខ្មែរក្រហមបានវាយប្រហារភូមិរបស់ អ៊ំសែម ហើយបំផ្លាញរោងចក្រស្ករសដែលនៅជិតផ្ទះរបស់គាត់ ។ ក្រុមគ្រួសាររបស់គាត់បាននាំគ្នាទៅរស់នៅភូមិទួលល្ពៅ ។ ជន់ អូន ដែលមានអាយុ២០ឆ្នាំ និងចេះអានអក្សរខ្លះៗ ត្រូវបានខ្មែរក្រហមជ្រើសរើសឲ្យធ្វើជាប្រធានកងកុមារ ។ អូន ត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅតំបន់១៥ហើយ បែកពីក្រុមគ្រួសាររហូត ។

នៅឆ្នាំ១៩៧៥ ក្រុមគ្រួសារ អ៊ំសែម បានវិលត្រឡប់ទៅរស់នៅភូមិញ្ញោវិញ ប៉ុន្តែរស់នៅក្នុងភូមិបានរយៈពេលខ្លីប៉ុណ្ណោះ គាត់ត្រូវជម្លៀសចេញពីភូមិនិងបញ្ជូនឲ្យទៅរស់នៅជាច្រើនកន្លែង និងធ្វើការងារលំបាកៗ ដែលធ្វើឲ្យគាត់មិនអាចនឹកនានិងមិនមានលទ្ធភាពស្វែងរកកូនស្រីដែលបែកទៅ ។ អ៊ំសែម រំឭកថា “ខ្មែរក្រហមឲ្យខ្ញុំទៅរស់នៅតំបន់៥៥ ខេត្តតាកែវ ជាកន្លែងដែលលំបាកវេទនាណាស់ ។ ខ្ញុំចាស់ហើយ ខ្មែរក្រហមឲ្យខ្ញុំរែកទឹករាប់រយអម្រែកក្នុងមួយថ្ងៃ ហើយហូបបបររាវដែលមានអង្ករតែ៤កំប៉ុងសម្រាប់មនុស្ស៤០នាក់ ជួនកាលបបរលាយខ្ទិត ។ ការងារលំបាកហើយមានកូនច្រើនទៀត ខ្ញុំមិនបានស្វែងរកកូនដែលបាត់នោះសោះ” ។

អូន ត្រូវអង្គការបញ្ជូនទៅធ្វើការនៅរោងចក្រតម្បាញក្នុងទីក្រុងភ្នំពេញតាំងពីឆ្នាំ១៩៧៥ ។ អូន ធ្លាប់បានទៅរកឪពុកនៅភូមិឫស្សីស្រុកដែរ ប៉ុន្តែមិនបានជួប ព្រោះ អ៊ំសែម ត្រូវអង្គការជម្លៀសទៅរស់នៅតំបន់៥៥ ។ នៅឆ្នាំ១៩៧៧ អូន បានរៀបការ


ជន់ សែម

ជាមួយឈ្មោះ ទ្រី ។ ក្រោយ មក ទ្រី ត្រូវបានចាត់តាំងឲ្យធ្វើជាគណៈឃុំមួយនៅក្នុងខេត្តបាត់ដំបង ។ អ្នកទាំងពីរក៏ទៅរស់នៅខេត្តបាត់ដំបងជាមួយគ្នា ។ មិនយូរប៉ុន្មាន ទ្រី ត្រូវខ្មែរក្រហមចោទថា ក្បត់បដិវត្តន៍និងត្រូវបាញ់សម្លាប់ ។ បន្ទាប់ពីការស្លាប់របស់ ទ្រី, អូន ត្រូវអង្គការបញ្ជូនមកទីក្រុងភ្នំពេញហើយបាត់ដំណឹងរហូត ។

ក្រោយឆ្នាំ១៩៧៩ កូនប្រសាស្រីរបស់ អ៊ំសែម ឈ្មោះ នឿន ដែលកាលពីនៅក្នុងរបបខ្មែរក្រហមរស់នៅក្បែរ អូន បានប្រាប់ អ៊ំសែម អំពីរឿងរ៉ាវទាំងនេះ ។

អ៊ំសែម បន្ថែមថា “ខ្ញុំមិនបានទទួលដំណឹងពីកូនស្រីខ្ញុំសោះតាំងពីពេលវាចេញពីផ្ទះ រហូតដល់បែកខ្មែរក្រហមទើបកូនប្រសាស្រីប្រាប់ខ្ញុំអំពីរឿងកូនស្រីខ្ញុំ ។ ដល់ពេលដែលមនុស្សពីមជ្ឈមណ្ឌលឯកសារយកប្រវត្តិរូបកូនខ្ញុំមកឲ្យខ្ញុំ ខ្ញុំស្មានថាកូនស្រីខ្ញុំប្រើគេនាំដំណឹងមកប្រាប់ ទើបខ្ញុំខ្ញុំរួតរះមកទីនេះ ។ ខ្ញុំហាក់ដូចជាស្រមៃថាវានៅរស់ ។ អារម្មណ៍របស់ខ្ញុំនៅនឹកគិតដល់កូនស្រីខ្ញុំ

ជានិច្ច ។

ក្រៅពី ជន់ អូន អ៊ឹសែម មានកូនពីរនាក់ទៀតដែលចូលបម្រើបដិវត្តន៍ដែរ ។ កូនប្រុសម្នាក់ចូលបម្រើកងទ័ពខ្មែរក្រហម ប៉ុន្តែបានវិលត្រឡប់មកជួបជុំគ្រួសារវិញ ។ កូនស្រីបន្ទាប់ឈ្មោះ ជន់ អុន ដែលបានទៅធ្វើការនៅខេត្តបាត់ដំបងបានស្លាប់ដោយសារជំងឺអាសន្នរោគនៅឆ្នាំ១៩៨៨ ។ ដោយឡែក ជន់ អូន បាត់ខ្លួនមិនឃើញត្រឡប់មកផ្ទះវិញ ។ សែម និយាយថា "ខ្ញុំឆ្ងល់ណាស់ កូនស្រីរបស់អ្នកភូមិដែលបាត់ទៅគេបានវិលត្រឡប់មកផ្ទះវិញហើយ នៅតែកូនស្រីទីពីររបស់ខ្ញុំមិនដឹងយ៉ាងណាទេ" ។

បន្ទាប់ពីរៀបរាប់រឿងរ៉ាវកូនស្រីរបស់គាត់រួចហើយ អ៊ឹសែម មានអារម្មណ៍ធូរស្រាលបន្តិចនិងមានទឹកមុខស្រស់ស្រាយជាងមុន ។ គាត់និយាយថា "ទោះជារកកូនស្រីខ្ញុំមិនឃើញក៏ពិតមែន ប៉ុន្តែពេលនេះខ្ញុំបានភ្លឺច្បាស់ក្នុងចិត្ត ហើយខ្ញុំក៏មិនអស់សង្ឃឹមដែរ ខ្ញុំនឹងខំប្រឹងស្វែងរកកូនស្រីខ្ញុំបន្តទៀត ។ ខ្ញុំនៅតែសង្ឃឹមថា កូនស្រីរបស់ខ្ញុំនឹងវិលត្រឡប់មករកខ្ញុំនៅថ្ងៃណាមួយ" ។

**សុ ហ្វារីណា**

# រឿងពិតមិនការឡៃ

ឆ្នាំ១៩៧៤នៅស្រុកចំការលើៈ ត្រើងជាតំបន់កាន់កាប់ដោយទាហានលន់នល់ បុសខ្នុរជាតំបន់រំដោះរបស់ខ្មែរក្រហម ។

ពេលមួយនោះ ខ្ញុំបានរែកសណ្តែកបាយនិងផ្លែចេកទុំទៅលក់នៅត្រើង ។ ខណៈនោះទាហានលន់នល់ ស្រែកគំហកថា "ឈប់សិន! មើលអីវ៉ាន់មានស្អីខ្លះ?" ពេលឆែកឆេររួច ខ្ញុំក៏រែកទៅមុខទៀតដើម្បីយកអីវ៉ាន់ទៅលក់ដូរ ។

លុះត្រឡប់មកវិញ ខ្ញុំបានទិញនំប័ុង ទឹកត្រី និងផ្លែឈើមួយចំនួនផង ។ មកដល់ព្រំប្រទល់ដីរំដោះ ខ្ញុំឮសំឡេងស្រែកចេញពីគុម្ពោតព្រៃមកថា ៈ ឈប់ៗ! អញពិនិត្យមើលសិន តិចមានគ្រាប់បែកគ្រាប់កាំភ្លើង ។ ខ្ញុំឆ្លើយថា "បាទមិត្តបង! គ្មានទេ មានតែនំចំណីបន្តិចបន្តួចតែប៉ុណ្ណោះ" ។ ភ្លាមនោះខ្មែរក្រហមម្នាក់ស្ទុះមកស្ទាបខ្ញុំពីជង្គង់រហូតដល់ចុងជើង ហើយនិយាយថា "គ្មានអីទេ ទៅចុះ" ។

កាលណោះនៅតំបន់ត្រើងតាមផ្លូវជាតិលេខ៧មានប្រជាជនអ៊ូរអររាល់ថ្ងៃ រថយន្តម៉ូតូទៅមកកត្រើកកគ្រេងពុំសូវដាច់ ប៉ុន្តែចាប់ពីព្រំប្រទល់ត្រើងមកបុសខ្នុរ (តំបន់ខ្មែរក្រហម) ស្ងាត់ជ្រងំ ។ ផ្លូវលេខ២១ (បច្ចុប្បន្នផ្លូវលេខ៧១) ត្រូវកាត់ផ្តាច់ដោយអន្ទើ ឯប្រជាជនលួចធ្វើដំណើរមកត្រើងម្តងៗ ដោយធ្វើដំណើរតាមផ្លូវកាត់ក្នុងព្រៃរបោះ ។

ធ្នូចបើកៗ ឆ្នាំ១៩៧៥ បានឈានមកដល់ឃុំបុសខ្នុរ មានប្រជាជនច្រើនគួរសមដែរ ក្នុងនោះមាន១០ឃុំគឺ ភូមិសារ៉ាយថ្មី សារ៉ាយចាស់ ភូមិប្រសើរ ភូមិបុសខ្នុរ ភូមិ១០មករា ភូមិសាមគ្គី ភូមិចិន ភូមិប្រសើរ ភូមិច្រណោម និងភូមិដូនធី ។

ភូមិចិននៅក្បែរជើងភ្នំទៃតសម្រាប់ឲ្យប្រជាជនចិនរស់នៅ ។ ភូមិសារ៉ាយថ្មីសម្រាប់ដាក់អ្នកមកពីភ្នំពេញ (១៧មេសា) ។ ភូមិផ្សេងៗទៀត គឺមានប្រជាជនចាស់រស់នៅលាយឡំជាមួយប្រជាជនថ្មី ។

ភូមិសារ៉ាយចាស់ជាភូមិដែលខ្ញុំនិងគ្រួសារព្រមទាំងឪពុកម្តាយបងប្អូនធ្លាប់រស់នៅ ក្រុមគ្រួសារខ្ញុំគឺជាប្រជាជនចាស់ ប៉ុន្តែរបបខ្មែរក្រហមវាយតម្លៃក្រុមគ្រួសារខ្ញុំថាជាវណ្ណៈអនុធនព្រោះយើងធ្វើនំលក់ ឬលក់ដូរកំប៉ិកកំប៉ុក ។

នៅឆ្នាំដំបូង ខ្មែរក្រហមបានជំរុញប្រជាជនឲ្យតាំងទីលំនៅក្នុងព្រៃឆ្ងាយពីថ្នល់ជាតិ ដោយយកលេសថាខ្លាចយន្តហោះទម្លាក់គ្រាប់បែកតាមផ្លូវជាតិនោះ ។

ខ្មែរក្រហមចាប់ផ្តើមឲ្យប្រជាជនធ្វើស្រែប្រវាស់ដៃ បន្តមកឲ្យធ្វើការរួមប្រមូលផលដាក់រួម ចម្ការដាំ សណ្តែកពោតក៏ដាក់រួមដែរ ។ ប្រជាជនត្រូវបែងចែកឲ្យធ្វើការតាមកម្លាំងពេញ កម្លាំងខ្សោយ និងកុមារ ។ តាយាយត្រូវអង្គការចាត់តាំងឲ្យក្រងព្រួល

ត្បាញល្អី ឃ្វាលគោក្របី ។ល ។ យុវជន-យុវនារីឲ្យទៅលើកទំនប់ជីកប្រឡាយនៅទីឆ្ងាយៗ ឬឲ្យទៅធ្វើកងទ័ពបុកឈ្លប ។ កុមារប្រមូលជីលាមកសត្វនិងរៀនខ្លះៗ ។

ខ្ញុំទៅធ្វើពលកម្មជារៀងរាល់ថ្ងៃ ក្រោយមកខ្ញុំធ្លាក់ខ្លួនឈឺធ្ងន់អស់រយៈពេលកន្លះខែ ។ បន្ទាប់ពីបានជាសះស្បើយប្រធានភូមិឈ្មោះ អឿន ហៅ រ៉ៃ (សព្វថ្ងៃរស់នៅភ្នំពេញ) បានប្រើខ្ញុំឲ្យនាំយុវជន៥នាក់ទៅយាមចម្ការពោតនៅឯដំណាក់អ្ជូក ។ ១៥ថ្ងៃក្រោយមក ខ្ញុំមកផ្ទះដើម្បីរកថ្នាំសង្កូវទុកលេប ស្រាប់តែប្រធានរោងបាយនិយាយថាបើគ្មានសំបុត្របញ្ជាក់ពីមេក្រុមចាំចម្ការពោតទេ មកផ្ទះគ្មានរបបទទួលទានឡើយ ។ ខ្ញុំឈឺចាប់ឥតឧបមា ពេល ឮសម្តីនេះ ខ្ញុំក៏ត្រឡប់មកផ្ទះយកអង្ករដែលខ្ញុំលាក់ទុកក្នុងពាងក្រោមដីដាំបាយហូប ។ ៥ថ្ងៃបន្ទាប់មក ខ្ញុំចាប់ផ្តើមឈឺគ្រុនញាក់ ហើយបានទៅសម្រាកព្យាបាលនៅពេទ្យឃុំបុសខ្នុរ ។ ប្រធានពេទ្យបុសខ្នុរយកថ្នាំអាចម៍ទន្សាយបួនដប់គ្រាប់ឲ្យខ្ញុំលេប រួចយកថ្នាំដបទឹកក្រូចចាក់ឲ្យខ្ញុំពីរម្ជុល ។ ខ្ញុំស្រែកថា ឈឺណាស់ ។ ប្រធានពេទ្យនោះគំរាមថា ទុកក៏មិនចំណេញដកចេញក៏មិនខាត ប្រយ័ត្នឲ្យមែនទែន ។ ពីរសប្តាហ៍ក្រោយមក ជំងឺរបស់ខ្ញុំបានធូរស្បើយ ។












ថ្ងៃមួយ ប្រធានកងប្រាប់ខ្ញុំថា "មិត្តឯងទៅភ្ជួរស្រែនៅមុខមន្ទីរភូមិឮទេ?" ខ្ញុំទៅតាមបញ្ជាភ្លាម ។ ទើបតែភ្ជួរបានមួយព្រឹក ខ្ញុំធ្វើឲ្យបាក់ផ្លៀងនង្គ័ល ។ ឃើញសភាពបែបនោះ លឹម ប្រធានភូមិសារ៉ាយចាស់ដែលទើបតែងតាំងថ្មីបានបញ្ជាឲ្យខ្ញុំទៅបាចត្រីនៅល្ពាក ឃុំទ្រា ក្នុងស្រុកកំពង់សៀម ។ ប្រធានក្រុមបានប្រាប់ថា "ពួកយើងខិតខំឲ្យមែនទែន ។ ត្រីធំៗទុកជូនសមមិត្តបង ឯត្រីចង្វា កំពិស ខ្សង ខ្ជៅ ក្តាម គឺសម្រាប់យើង ចូរចាំទាំងអស់គ្នាណា៎?"

បីខែដូចបីឆ្នាំ សុខភាពរបស់ខ្ញុំចុះទ្រុឌទ្រោម ។ ខ្ញុំខស្សាហ៍គ្រុនញាក់ណាស់ ។ ខ្ញុំសុំប្រធានកងមកផ្ទះដើម្បីព្យាបាលជំងឺ ប៉ុន្តែមិនបានមួយសប្តាហ៍ផង សមមិត្តលឹម ចាត់តាំងខ្ញុំឲ្យទៅលើទំនប់១មករា (កំពង់ថ្ម) ចំនួន៨ខែទៀត ។ នៅទំនប់១មករា មេកងហៅប្រជុំជីវភាពរាល់ល្ងាច ដែលគ្មានអ្វីនិយាយក្រៅពី "យើងត្រូវប្រឹងលើកទំនប់នេះឲ្យបានលឿនតាមមាគ៌ាមហាលោតផ្លោះមហាអស្ចារ្យ... បើអ្នកណាឈឺល្ហមៗប្រឹងលេបថ្នាំព្យាបាល កុំទម្រន់ កុំធ្វើពុតជាគ្រុនញាក់ គ្រុនញ័រ គ្រុនត្រាក់ទ័រ គ្រុនឡាន គ្រុនបាយបាន គ្រុនសតិអារម្មណ៍ ។ ទីនោះជាកន្លែងរែងអង្ករ ហើយ គេយកអង្ករដើម អង្ករចុងគេមិនយកទេ ។ បើជីកស្មៅត្រូវជីកទាំងឫស កុំឲ្យសល់ឲ្យសោះ" ។ ឮបែបនេះម្នាក់ៗខំប្រឹងលើកទំនប់ រែកដី សែងថ្ម គ្មានទំនេរទេ ទោះជាឈឺល្ហមៗក៏មិនហ៊ានឈប់ដែរ មានអ្នកខ្លះខំធ្វើការរហូតដល់សន្លប់ ខ្លះខ្យល់គ ខ្លះ

គ្រាំគ្រាដេកស្លាប់ក្នុងអន្រ្ទីងក៏មាន ។

រាល់ថ្ងៃនៅការដ្ឋានទំនប់១មករា ខ្មែរក្រហមបានចាក់ចម្រៀងបដិវត្តន៍លាន់ទ្រហឹងនិយាយតែពីរឿងជីកទំនប់ប្រឡាយសន្ទុំសចៃ ធ្វើស្រែឲ្យបានបីដងក្នុងមួយឆ្នាំ ។ មើលចុះ! ផ្នែកនារីលើកដីកាប់ដីនៅម្ខាង រីឯយុវជនពលកម្មម្ខាងទៀតឆ្ងាយពីគ្នា ។ រោងសម្រាកប្រក់ធាងដូង នៅវាលស្រែគ្មានម្លប់ឈើ ។

រាល់យប់ កងឈ្លបមកលបចាំស្តាប់ក្រែងមានអ្នកណាថ្ងូរថាពិបាកឬយ៉ាប់យ៉ឺនទ្រាលនឹងរាយការណ៍ទៅអង្គការថ្នាក់លើ ។ បើយុវជននិងយុវនារីនិយាយឆ្លើយឆ្លងគ្នាគេចោទថាខុសសីលធម៌ ហើយឈ្លបចាប់អ្នកទាំងពីរយកទៅសម្លាប់ភ្លាម មិនទុកយូររកខុសត្រូវឡើយ ។ មនុស្សក្នុងកងចេះតែបាត់ខ្លួនជាបណ្តើរៗ ។ ឃើញដូចនេះម្នាក់ៗខំធ្វើការមិនដែលហ៊ានត្អូញត្អែរ ។

ខ្ញុំធ្វើការដូចជាទាសករ វែកដីគ្មានទំនេរ យើងបានសម្រាកតែពេលថ្ងៃត្រង់ប៉ុណ្ណោះ ។ ពេលម៉ោងបីទៀបភ្លឺ មេកងស្ទុះទៅវាយជួងដាស់ពលករឲ្យក្រោកឡើងដើម្បីចេញដំណើរទៅលើកទំនប់ទៀត ។

រយៈពេលប្រហែល៨ខែ ទំនប់បានលេចរូបរាងត្រដែតពេលនោះខ្ញុំនិងអ្នកដទៃទៀតនៅឃុំ បុសខ្នុរត្រូវបានដូរមកផ្ទះវិញ ហើយយកអ្នកថ្មីទៅម្តង ។

រំលងបានមួយខែ មិត្តលឹម ជាប្រធានភូមិ ចាត់តាំងខ្ញុំឲ្យទៅធ្វើការនៅឡក្បឿងនៅភូមិអូរនន់ក្នុងឃុំស្ពឺ ។ ម្តងនេះខ្មែរក្រហមយករទេះមកដឹកប្រជាជនទៅទាំងគ្រួសារៗ ដោយកុហកថាទៅមួយរយៈសិនសឹមវិលមកភូមិវិញ ។ អ្នកភូមិសារ៉ាយត្រូវអង្គការចាត់តាំងឲ្យទៅនៅឡក្បឿងតែបីគ្រួសារទេ ។ រទេះគោបានដឹកគ្រួសារខ្ញុំនិងអីវ៉ាន់បន្តិចបន្តួចទៅជាមួយដែរ ។ អ្នកស្រុកខ្សឹបខ្សៀវថា ទៅអូរនន់ប្រាកដជាយកទៅសម្លាប់ចោលហើយ ព្រោះម្នាក់ៗតែចេញពីភូមិ ហើយកម្របានមកវិញណាស់ ។ ឪពុកម្តាយ ក្មេកខ្ញុំដែលរស់នៅឃុំស្វាយទាប ឮដំណឹងនេះភ្លាមគាត់យំសោកសង្រេង ពីព្រោះនៅកន្លែងដទៃទៀតក៏មានរឿងដូចគ្នានេះដែរ ។

យើងជិះរទេះគោតាំងពីព្រឹករហូតថ្ងៃត្រង់ ទើបទៅដល់អូរនន់ ជាតំបន់ចាញ់នៅក្នុងព្រៃរបោះស្ងាត់ជ្រងំគ្មានផ្ទះគ្មានភូមិអ្នកស្រុក ។ មេកងបានរៀបចំចាត់ចែងធ្វើរោងឲ្យប្រជាជនថ្មីស្នាក់នៅ ។

មួយអាទិត្យកន្លងទៅ មេកងបានបញ្ជាឲ្យខ្ញុំនិងយុវជនដែលពេញកម្លាំងទៅកាប់ដីនិងជាន់ក្បឿង ម្នាក់ៗឲ្យបានក្បឿង៤០០សន្លឹកក្នុងមួយថ្ងៃ បើធ្វើមិនបានទេប្រធានកងនឹងសួរមូលហេតុអ្វី?

ខ្ញុំពិបាកចិត្តណាស់ព្រោះមិនដែលចេះធ្វើក្បឿង ។ ពេលដំបូង ប្រធានកងបានបង្រៀនឲ្យចេះគ្រប់ៗគ្នា ។ ថ្ងៃទីមួយ ខ្ញុំកាប់ដីផងជាន់ក្បឿងផង រួចយកក្បឿងដែលជាន់បានទៅតម្រៀបហាលទៀត ។ ខ្ញុំជាន់បានតែ២៥០សន្លឹកប៉ុណ្ណោះក្នុងមួយថ្ងៃ ។ ប្រធានកងរអ៊ូខ្សឹបៗថា ពួកនេះសុទ្ធតែពួកអនុធនប្រតិកិរិយា ។ ពេលនោះទើបខ្ញុំដឹងខ្លួនអង្គការយកខ្ញុំមកលត់ដំទេតើ ។

រំលងបានមួយខែ ខ្ញុំនិងពីរគ្រួសារទៀតខិតខំព្យាយាមធ្វើការនេះទាល់តែបានស្ទាត់ជំនាញ និងជាន់ក្បឿងបានពី៤០០ទៅ៥០០សន្លឹកក្នុងមួយថ្ងៃ ។ យើងត្រូវតែខំធ្វើការដោយពុំខ្វាចនឿយហត់ ទោះបីអុជចង្កៀងប្រចន្ទុះបំភ្លឺជាន់ក្បឿងពេលយប់ក៏ដោយ គឺនៅតែប្រឹងឲ្យគ្រប់ផែនការរបស់អង្គការ ។

ពេលវេលាកន្លងទៅប្រាំពីរខែ (ជិតចូលដល់ឆ្នាំ១៩៧៩) សភាពការណ៍ហាក់ដូចជាប្លែកៗ ។ មេកងនិងកម្មាភិបាលគ្រប់គ្រង បានបាត់ខ្លួនមួយថ្ងៃម្នាក់ឬពីរនាក់ពុំដឹងទៅណា នៅសល់តែតាចាស់មេការម្នាក់អាយុ៦០ឆ្នាំ ដែលពីមុនធ្លាប់តែមានអត្តចរិតក្រអឺត ឥឡូវបែរជាស្លូតបូតវិញ ។

ថ្ងៃមួយ ខ្ញុំលួចស្តាប់វិទ្យុរបស់មេការនោះ បានឮថាទីក្រុងភ្នំពេញបានរំដោះហើយ ។ យើងនាំគ្នាឈប់ធ្វើក្បឿងម្ទីម្ទាប្រមូលរបស់របរចានឆ្នាំងនិងអីវ៉ាន់វែកត្រឡប់ទៅខ្ទមវិញ ។ យើងធ្វើដំណើរមកដល់វាលស្រែខាងលិចឃុំស្ពឺស្រាប់តែមេកងដែលទើបមកថ្មីគំហកថា ៖ "ពួកមឹងត្រឡប់ទៅវិញភ្លាម បើមិនប្រញាប់ទៅទេប្រយ័ត្នស្លាប់ទាំងអស់គ្នា" ។ គំរាមហើយមេកងនោះក៏ជិះកង់យ៉ាងលឿនទៅបាត់ ។

ខ្ញុំនិងភរិយាព្រមទាំងកូនតូចៗខំស្រូតមកលំនៅឋាននៅឯភូមិបុសខ្នុរហើយបានរួចពីគុកឥតជញ្ជាំងរហូតដល់សព្វថ្ងៃនេះ ។

**កែវ សុមេធ**

# សូមសងជីតាខ្ញុំវិញ

ខ្ញុំបាទឈ្មោះ ស៊ុន សារឿន ជានិស្សិតសាកលវិទ្យាល័យ វេនឡេន ។ សូមផ្ញើសារជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ខ្ញុំបាទ នៅភូមិត្រពាំងព្រីង ឃុំព្រៃអំពក ស្រុកគិរីវង្ស ខេត្តតាកែវ ។

ខ្ញុំបាទសូមផ្ញើសារប្តឹងទៅមជ្ឈមណ្ឌលឯកសារកម្ពុជាថា នៅក្នុងរបបខ្មែរក្រហមហៅថា កម្ពុជាប្រជាធិបតេយ្យក្នុងឆ្នាំ ១៩៧៥-១៩៧៩ មេដឹកនាំរបបនេះបានសម្លាប់ជីតារបស់ខ្ញុំ ឈ្មោះ គឹម វីង នាឆ្នាំ១៩៧៥ នៅភ្នំវល្លិ៍ ខេត្តកំពត ។ គាត់មាន តួនាទីជាឧត្តមសេនីយ៍របស់កងទ័ពចលនារំដោះជាតិសម្តេចឪ ។ ខ្ញុំសូមប្តឹងទៅតុលាការដែលកាត់ទោសមេដឹកនាំខ្មែរក្រហមដែលធ្វើ ឡើងដោយអង្គការសហប្រជាជាតិ សូមឲ្យខ្មែរក្រហមសងជីតា បង្កើតរបស់ខ្ញុំវិញ ។ យើងកំព្រាជីតាតាំងតែពីខ្ញុំកើតបានអាយុ ៧ឆ្នាំ មកម្ល៉េះ ធ្វើឲ្យគ្រួសារខ្ញុំបែកបាក់គ្នា កំព្រា មេម៉ាយ ក្រលំបាក គោកយ៉ាកវេទនាគ្មានពេលល្ហែ ។ យើងក៏ជាខ្មែរដែរ មានជាតិ កំណើតពូជសាសន៍មានមនសិការចំពោះជាតិមាតុភូមិដែរ ហេតុអ្វី ត្រូវខ្មែរក្រហមសម្លាប់ចោលយ៉ាងព្រៃផ្សៃបំផុត?

ក្នុងចំណោមគ្រួសារយើងនៅមានឪពុកធំម្នាក់និងឪពុកមា ពីរនាក់ទៀតជាពលទាហាននៃរបបសាធារណរដ្ឋខ្មែរ ត្រូវខ្មែរ ក្រហមសម្លាប់នៅពេលដែលទទួលជ័យជម្នះ តើគាត់ទាំងបីមាន ទោសអ្វី? សូមមេដឹកនាំខ្មែរក្រហមមាន ខៀវ សំផន, នួន ជា, អៀង សារី និងអ្នកពាក់ព័ន្ធដទៃទៀត សងក្រុមគ្រួសារយើងមក វិញ ។ ខ្ញុំយល់ឃើញថាអ្នករងគ្រោះក្នុងរបបខ្មែរក្រហមមាន ច្រើនលាននាក់ ក៏ប៉ុន្តែមានតិចណាស់ដែលបានសរសេរលិខិតទៅ ជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ។ នៅខាងក្រោមនេះខ្ញុំសូមរៀប រាប់ខ្លះៗអំពីរបបនេះ ។

នៅក្នុងឆ្នាំ១៩៧៥ របបសាធារណរដ្ឋខ្មែរដែលដឹកនាំដោយ សេនាប្រមុខលន់នល់ត្រូវបានចលនាខ្មែរក្រហមវាយរុញច្រានចូល ដល់ខេត្តក្រុង ។ របបនេះត្រូវដួលរលំ មេដឹកនាំខ្មែរក្រហមដែលបាន ឡើងកាន់អំណាចមាន ប៉ុល ពត, អៀង សារី, ខៀវ សំផន, នួន ជា, សុន សេន និង តាម៉ុក ជាដើម ។ល ។ ក្តាប់អំណាចពេញដៃ ហើយ ជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ទៅជនបទឆ្ងាយៗពីខេត្ត មួយទៅខេត្តមួយ ធ្វើឲ្យប្រជាជនបែកបាក់ព្រាត់ប្រាសនិរាសវេទនា រកទីបំផុតគ្មាន ។ ប្រជាជននៅឯជនបទក៏បានឃើញមនុស្សម្នាច្រើន ពពាក់ពពូន ខ្លះយួរ ខ្លះរែកពុន ខ្លះបររទេះគោក្របី ។ ប្រជាជនខ្លះ ទៀតឈប់សម្រាកនៅតាមចិញ្ចើមថ្នល់ ខ្លះឈប់សម្រាកដាំបាយ ទឹកហូបសិន ខ្លះដល់ភូមិឋានរបស់គេនាំគ្នាចូលផ្ទះ ខ្លះមានផ្ទះនៅឆ្ងាយ រាប់រយគីឡូម៉ែត្រ ក៏បន្តដំណើរទៅមុខទៀត ដោយមានកងទ័ព អាវខ្មៅក្ឈង់កាំភ្លើងពីមុខពីក្រោយបាញ់បោះយ៉ាងសាហាវបំផុត ។

កាលនោះខ្ញុំមានអាយុ៧ឆ្នាំ ។ ក្រុមគ្រួសារខ្ញុំដែលភៀសខ្លួន ទៅខេត្តកំពតក្នុងអំឡុងពេលសង្គ្រាមបានវិលត្រឡប់មកផ្ទះនៅ ខេត្តតាកែវវិញក្រោយពេលខ្មែរក្រហមទទួលជ័យជម្នះ ។ មក ដល់ផ្ទះ យើងរង់ចាំមើលផ្លូវជីតាដែលទៅធ្វើការក្នុងចលនា រំដោះជាតិសម្តេចឪ និងរង់ចាំឪពុកមាពីរនាក់ទៀតដែលជា កងទ័ពសាធារណរដ្ឋខ្មែរ ប៉ុន្តែចាំបាត់ៗគ្មានដំណឹង ។ បងប្អូនក្រុម គ្រួសារទាំងប៉ុន្មានដែលមកជុំគ្នានោះត្រូវជម្លៀសបែកខ្ញែកគ្នា អស់ និងត្រូវបង្ខំឲ្យធ្វើការជាទម្ងន់ បង្អត់អាហារ សម្លាប់ចោល ធ្វើទារុណកម្ម និងជំងឺគ្មានថ្នាំព្យាបាល ។ លើសពីនេះគឺការរំលាយ ព្រះពុទ្ធរូប ការរុះរើវត្តអារាមជាទីសក្ការបូជា ការចោទព្រះសង្ឃ ថាជាពួកសក្តមនិងជាជនបញ្ញើក្អែក ការបិទសាលារៀន មន្ទីរ ពេទ្យ ការបិទសិទ្ធិសេរីភាពក្នុងការនិយាយស្តីនិងក្នុងការធ្វើ ដំណើរ ការផ្តាច់ទំនាក់ទំនងក្នុងគ្រួសារ និងការបំបាក់ស្មារតី ។

យើងសូមប្តឹងទៅតុលាការរៀបចំកាត់ទោសមេដឹកនាំខ្មែរ ក្រហមឲ្យកាត់ទោសនិងអ្នកពាក់ព័ន្ធទៀត ។ ខ្មែរក្រហមសាហាវ ណាស់ ប្រល័យពូជសាសន៍ផ្តាច់ការបំផុត បើទោះបីជាខ្លួន បរាជ័យហើយក៏នៅតែតស៊ូបង្ហូរឈាមជាក្រុមឧទ្ទាមនៅក្នុងព្រៃ អស់រយៈពេលពីរបីទសវត្សរ៍ ដើម្បីបន្តការប្រល័យពូជសាសន៍ ទៀត ។ យើងសូមឲ្យសហគមន៍អន្តរជាតិយកចិត្តទុកដាក់ធ្វើការ នេះឲ្យបានល្អបំផុត និងឲ្យបានជោគជ័យខ្ពស់ ។

**ស៊ុន សារឿន**

# សេចក្ដីប្រកាសរកក្មួយឈ្មោះ សេង វុទ្ធី

នាងខ្ញុំឈ្មោះ ស៊ូ កាន់យ៉ា អាយុ៥៧ឆ្នាំ បច្ចុប្បន្នរស់នៅ ភូមិថ្កូវក្រៅ ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ សូមប្រកាសរកក្មួយឈ្មោះ សេង វុទ្ធី (ម្ដាយឈ្មោះ សេង វ៉ាន់ដេន) យុទ្ធជននៅមន្ទីរកាណូតយន្តនៅក្នុងរបបខ្មែរក្រហម ។ វុទ្ធី បានបាត់ខ្លួនតាំងពីពេលរត់ទៅជាមួយឈ្មោះ ភាព គណៈតំបន់៥០៥ ក្នុងពេលផ្ទុះឃ្លាំងគ្រាប់ ។

ប្រសិនបើក្មួយ សេង វុទ្ធី បានឃើញសេចក្ដីប្រកាសនេះ ឬញាតិមិត្តបានស្គាល់ឈ្មោះខាងលើនេះ សូមទាក់ទងមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានផ្ទះលេខ ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ ។ សូមអរគុណ ។

# សេចក្ដីប្រកាសរកកូនពីរនាក់និងចៅពីរនាក់

នាងខ្ញុំឈ្មោះ ហ៊ុយ វិទ្យាលីន ហៅ ថុន អាយុ៧២ឆ្នាំ បច្ចុប្បន្នរស់នៅភូមិចាបក្រសាំង ឃុំវត្តគរ ស្រុកបាត់ដំបង ខេត្តបាត់ដំបង សូមប្រកាសសួររកកូនបីនាក់និងចៅពីរនាក់ ៖ ១) អៀម លីឡា (កូនស្រី) , ២) អៀម សូលីណា (កូនប្រុស) , ៣) អៀម រិទ្ធា (កូនប្រុស) , ៤) ពេជ្រ ណារិទ្ធ (ចៅប្រុស-ម្ដាយឈ្មោះ អៀម ម៉ារីយ៉ា) , ៥) ពេជ្រ ម៉ារីយ៉េត (ចៅស្រី-ម្ដាយឈ្មោះ អៀម ម៉ារីយ៉ា) ។

ឈ្មោះទាំងអស់នេះបានបែកគ្នានៅឆ្នាំ១៩៧៥ នៅពេលដែលម្ដាយទៅលេងផ្ទះកូនច្បងនៅឯខេត្តបាត់ដំបង ។ តាមការអះអាងពីឪពុកមារបស់កូន គាត់បានឃើញកូនៗចេញដំណើរទៅខាងច្បារអំពៅ ។ ដូច្នេះប្រសិនបើកូនៗនិងចៅបានទទួលដំណឹងនេះ សូមមករកម្ដាយនិងជីដូន ឬញាតិមិត្តណាបានឃើញឬស្គាល់ឈ្មោះនេះសូមជួយផ្ដល់ដំណឹងមកនាងខ្ញុំតាមទូរស័ព្ទលេខ ០៩២ ៨០៩ ៥១៨ ឬតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាអាសយដ្ឋានផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ ។

# សេចក្ដីប្រកាសរកប្អូន៥នាក់

នាងខ្ញុំឈ្មោះ នៅ សន អាយុ៥៦ឆ្នាំ រស់នៅភូមិព្រៃកំដួល ឃុំបរសេដ្ឋ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ សូមសួររកប្អូនប្រាំនាក់ ៖

១) នៅ សុំ (ស្រី)

២) នៅ ធាន (ប្រុស)

៣) នៅ ទឹម (ប្រុស)

៤) នៅ សុខឿន (ប្រុស)

៥) ម៉ៅ នឹម (ប្រុស)

អ្នកទាំងប្រាំបាត់ខ្លួននៅឆ្នាំ១៩៧៩ ។ ប្រសិនបើសាមីខ្លួនទាំងប្រាំនាក់បានឮ ឬញាតិមិត្តណាបានស្គាល់ឈ្មោះទាំងប្រាំនេះ សូមផ្ដល់ព័ត៌មានមកនាងខ្ញុំតាមទូរស័ព្ទលេខ ០១១ ២៩១ ៥៩៨ ឬតាមរយៈមជ្ឈមណ្ឌលកម្ពុជា អាសយដ្ឋានផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ ។ សូមអរគុណ ។




ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុយអែត និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជាប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 75, March 2006 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Royal Government of Cambodia, Prakas No.0291 P.M/99, 2 August 1999.